## គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្ម ខ្នាតតូច តំបន់ទន្លេសាប ( TSSD )

# ផែនការសកម្មភាព និង ថវិកាឆ្នាំ 2014

MAFF/NCDDS

ខែ មករា ឆ្នាំ 2014

# ពាក្យបំព្រួញ

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AEA | Agro-ecosystems Analysis | ការវិភាគប្រព័ន្ធកសិ្យត្រ-បរិស្ថាន |
| AWPB | Annual Work Plan and Budget | ផែនការសកម្មភាព និងថវិកាឆ្នាំ |
| BMC | Banteay Meanchey province | ខេត្តបន្ទាយមានជ័យ |
| CAA | Commune Administrative Assistant | ជំនួយការរដ្ឋបាលឃុំ សង្កាត់ |
| CEW | Commune Extension Worker | អ្នកផ្សព្វផ្សាយឃុំ សង្កាត់ |
| CARD | Council for Agriculture and Rural Development | ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងអភិវឌ្ឍន៍ជនបទ |
| CC | Commune Council | ក្រុមប្រឹក្សាឃុំ សង្កាត់ |
| CDF | Commune Development Fund | មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ |
| CIP | Commune Investment Program | កម្មវិធីវិនិយោគឃុំ សង្កាត់ |
| CMA | Commune Mobile Access | ការផ្តល់ព័ត៌មានចល័តថ្នាក់ឃុំ សង្កាត់ |
| DCU | Development Coordination Unit | អង្គភាពសម្របសម្រួលការអភិវឌ្ឍ |
| DFT | District Facilitation Team | ក្រុមសម្របសម្រួលក្រុង ស្រុក |
| DoA | District Office of Agriculture | ការិយាល័យកសិកម្មក្រុង ស្រុក |
| DST | District Support Team | ក្រុមគាំទ្រថ្នាក់ក្រុង ស្រុក (កសិកម្ម) |
| DTL | Deputy Team Leader | អនុប្រធាន(ក្រុមទីប្រឹក្សា) |
| EA | Executing Agency | ភ្នាក់ងារ/ស្ថាប័នប្រតិបត្តិ |
| ECCE | Environmental and Climate Change Expert | ទីប្រឹក្សាផ្នែកបរិស្ថាន និងប្រែប្រួលអាកាសធាតុ |
| GAP | Good Agricultural Practice | ការអនុវត្តកសិកម្មល្អ |
| GDA | General Directorate of Agriculture | អគ្គនាយកដ្ឋានកសិកម្ម |
| GnAP | Gender Action Plan | ផែនការសកម្មភាពយេនឌ័រ |
| GoF | Government of Finland | រដ្ឋាភិបាលប្រទេសហ្វាំងឡង់ |
| IA | Implementing Agency | ភ្នាក់ងារ/ស្ថាប័នអនុវត្ត |
| IFAD | International Fund for Agriculture Development | មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម |
| KPC | Kampong Cham province | ខេត្តកំពង់ចាម |
| KPT | Kampong Thom province | ខេត្តកំពង់ធំ |
| LIG | Livelihood Improvement Group | ក្រុមកែលម្អជីវភាព |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ |
| M & E | Monitoring and Evaluation | ការត្រួតពិនិត្យ និង វាយតម្លៃ |
| NCDD-S | The National Committee for Sub-National Democratic Development Secretariat | លេខាធិការដ្ឋាន គ.ជ.អ.ប |
| NGO | Non-Government Organisation | អង្គការមិនមែនរដ្ឋាភិបាល |
| NiDA | National Information, Communication and Technology Development Authority | អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា ព័ត៌មាន គមនាគមន៍ (ណែដា) |

| | | |
|---|---|---|
| PAC | Provincial Agriculture Coordinator | មន្ត្រីសម្របសម្រួលកសិកម្មខេត្ត |
| PIC | Project Implementation Consultants | ទីប្រឹក្សាអនុវត្តគម្រោង |
| PID | Planning and Investment Division | ទីចាត់ការផែនការ និងវិនិយោគខេត្ត |
| PPMS | Project Performance and Monitoring System | ប្រព័ន្ធពិនិត្យតាមដានវឌ្ឍនភាពគុណផលអនុវត្តគម្រោង |
| PFT | Provincial Facilitation Team | ក្រុមសម្របសម្រួលខេត្ត |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| RS | Research Station | ស្ថានីយកសិកម្ម |
| SRP | Siem Reap province | ខេត្តសៀមរាប |
| SSP | Specialised Service Provider | អ្នកផ្តល់សេវាកម្មជំនាញឯកទេស |
| TA | Technical Assistance | ជំនួយបច្ចេកទេស |
| ToT | Training of Trainers | បណ្តុះបណ្តាលគ្រូបង្គោល |
| TL | Team Leader | ប្រធានក្រុម (ទីប្រឹក្សា) |
| TSSD | Tonle Sap Poverty Reduction and Smallholder Development Project | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច តំបន់ទន្លេសាប |
| TSTD | Tonle Sap Technology Development and Productivity Enhancement | គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិភាព តំបន់ទន្លេសាប |

# A. សង្ខេប និង ទិន្នន័យគោលស្តីពីគម្រោង

| | |
|---|---|
| លេខគម្រោងកម្ចី/ឥតសំណង **ADB** | L 2599 - CAM (SF); G0186 - CAM (SF) |
| ឈ្មោះគម្រោង | គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច តំបន់ទន្លេសាប (TSSD) |
| អ្នកខ្ចី | រាជរដ្ឋាភិបាលកម្ពុជា |
| ភ្នាក់ងារប្រតិបត្តិ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (MAFF) - សមាសភាគទី 2 & 3<br>លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន គ.ជ.អ.ប - NCDDS) - សមាសភាគទី 1 & 3 |
| ភ្នាក់ងារអនុវត្ត | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ - អគ្គនាយកដ្ឋានកសិកម្ម (GDA)<br>លេខាធិការដ្ឋាន គ.ជ.អ.ប (NCDDS)<br>អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA) |
| គណៈកម្មការតម្រង់ទិសគម្រោង | ដឹកនាំដោយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) |
| ថវិកាចំណាយសរុបរបស់គម្រោង **(ដុល្លារសហរដ្ឋអាមេរិក)** | 55,56 លាន (បូករួមទាំង ពន្ធ និងអាករ មានទឹកប្រាក់សរុប 5 លានដុល្លារ) |
| ហិរញ្ញប្បទានគម្រោង **(លាន ដុល្លារសហរដ្ឋអាមេរិក)** | **ADB (អេឌីប៊ី)** ឥតសំណង 27,32 កម្ចី 3,41<br>**IFAD (អ៊ីហ្វាត)** ឥតសំណង 6,80 កម្ចី 6,80<br>**GoF (រដ្ឋាភិបាលហ្វាំងឡង់)** ឥតសំណង 5,75<br>**RGC (រដ្ឋាភិបាលកម្ពុជា)** 5,50 |
| កាលបរិច្ឆេទយល់ព្រមកម្ចី/ជំនួយឥតសំណង ដោយ អេឌីប៊ី **ADB** | ថ្ងៃទី 8 ខែធ្នូ ឆ្នាំ 2009 |
| កាលបរិច្ឆេទចុះហត្ថលេខាកិច្ចព្រមព្រៀងកម្ចី/ជំនួយឥតសំណង | អេឌីប៊ី និង រាជរដ្ឋាភិបាលកម្ពុជា **ADB / RGC** ថ្ងៃទី 27 ខែធ្នូ ឆ្នាំ 2009<br>អ៊ីហ្វាត និង រាជរដ្ឋាភិបាលកម្ពុជា **IFAD / RGC** ថ្ងៃទី 15 ខែកុម្ភៈ ឆ្នាំ 2010<br>រដ្ឋាភិបាលហ្វាំងឡង់ និង រាជរដ្ឋាភិបាលកម្ពុជា **GoF/RGC** ថ្ងៃទី 20 ខែកញ្ញា ឆ្នាំ 2010 |
| កាលបរិច្ឆេទមានប្រសិទ្ធភាពចាប់ផ្តើមកម្ចី/ជំនួយឥតសំណង **ADB** | ថ្ងៃទី 31 ខែមីនា ឆ្នាំ 2010 |
| កាលបរិច្ឆេទបិទកម្ចី/ជំនួយឥតសំណង **ADB** | ថ្ងៃទី 28 ខែកុម្ភៈ ឆ្នាំ 2018 |
| កាលបរិច្ឆេទបេសកកម្មពិនិត្យវឌ្ឍនភាពចុងក្រោយរបស់ **ADB** | ថ្ងៃទី 21 ខែ ឧសភាព សីហា / ថ្ងៃទី 14 ខែ មិថុនា ឆ្នាំ 2013 |
| ផលប៉ះពាល់របស់គម្រោង | កម្រិតជីវភាពកសិករប្រមាណ 630.000 គ្រួសារ ក្នុងខេត្តបួន (កំពង់ចាម កំពង់ធំ សៀមរាប និង បន្ទាយមានជ័យ) ក្នុងតំបន់អាងបឹងទន្លេសាប ត្រូវបានកែលម្អឲ្យប្រសើរឡើងនៅឆ្នាំ 2020។ |
| ផលប្រែប្រួលរបស់គម្រោង | បង្កើនផលិតភាពកសិកម្ម និង កែលម្អលទ្ធភាពរកទីផ្សារលក់កសិផល ក្នុងតំបន់គោលដៅរបស់គម្រោង |
| សមាសភាគ | 1. **ការអភិវឌ្ឍឃុំ-សង្កាត់ តាមរយៈ មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់**<br>• កែលម្អហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់ផលិតភាពកសិកម្ម<br>• ពង្រឹងសមត្ថភាពក្រុមកសិករខ្នាតតូច<br>• ពង្រឹងសមត្ថភាពឃុំ-សង្កាត់ក្នុងការគ្រប់គ្រងគម្រោង<br>2. **បរិយាកាសអំណោយផលដល់ការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម**<br>• ធ្វើឲ្យគោលនយោបាយកសិកម្មមានភាពល្អប្រសើរឡើង<br>• បង្កើនលទ្ធភាពឲ្យកសិករទទួលបាននូវគ្រាប់ពូជប្រកបដោយគុណភាពល្អ<br>• ជួយឲ្យកសិករទទួលបាននូវព័ត៌មានកសិកម្ម និង ទិន្នន័យទីផ្សារ |

| | |
|---|---|
| | **3. ការគ្រប់គ្រងគម្រោងមានប្រសិទ្ធិភាព** |
| តំបន់គោលដៅគម្រោង | គម្រោងគ្របដណ្តប់196ឃុំ៖ បន្ទាយមានជ័យ(32ឃុំ) សៀមរាប(58ឃុំ) កំពង់ធំ(45ឃុំ) និងកំពង់ចាម (61ឃុំ)<br>ការជ្រើសរើសឃុំ សង្កាត់គោលដៅរបស់គម្រោងផ្អែកលើ៖ (i) កម្រិតភាពក្រីក្រ; (ii) អន្តរាគមន៍របស់ម្ចាស់ជំនួយនានា; (iii) ស៊ីនែហ្ស៊ី និង ភាពបង្គ្រប់ឲ្យគ្នា; (iv) សក្តានុពលលូតលាស់តាមតំបន់កេ្សត្រ-បរិស្ថាន; និង (v) ការផ្តោតតាមភូមិសាស្រ្ត |

## B. ផលប្រែប្រួល និង ផលប៉ះពាល់របស់គម្រោង

1. គម្រោង TSSD ត្រូវបានគ្រោងរចនា (រៀបចំ)ឡើង ដើម្បីកែលម្អឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធតម្រូវតាមអាទិភាពរបស់សហគមន៍ និងការអភិវឌ្ឍសមត្ថភាពឃុំ សង្កាត់ចំនួន 196 ក្នុងខេត្តបន្ទាយមានជ័យ សៀមរាប កំពង់ធំ និងកំពង់ចាម។[1] គម្រោង នឹងជួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បី ៖

- ✓ បង្កើតហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីកែលម្អផលិតកម្មកសិកម្ម លទ្ធភាពរកទីផ្សារលក់កសិផល និង គុណភាពជីវភាពរស់នៅរបស់សហគមន៍ជនបទ។
- ✓ ផ្តល់សេវាកម្មហិរញ្ញវត្ថុជនបទ ត្រូវបានផ្តល់ឲ្យដល់កសិករខ្នាតតូច ក្សត់ធនធាន។
- ✓ ផ្តល់សេវាកម្មគាំទ្រផ្នែកកសិកម្មល្អប្រសើរឡើង រួមទាំង ការផ្តល់សេវាកម្មផ្នែកស្រាវជ្រាវ ផ្សព្វផ្សាយ និង ព័ត៌មានដែលគាំទ្រដល់ការបង្កើនផលិតភាពកសិកម្មរបស់កសិករខ្នាតតូច។
- ✓ បង្កើតគោលនយោបាយ និង និយតកម្មសមស្របនានា ដែលគាំទ្រដល់សហគមន៍កសិករខ្នាតតូច។
- ✓ គ្រប់គ្រងគម្រោងមានប្រសិទ្ធភាព ដែលអនុញ្ញាតិឲ្យបញ្ចប់គម្រោង ទាន់ពេលវេលា និង សម្រេចបានទិសដៅគម្រោង

2. *ផលប្រែប្រួល* របស់គម្រោង TSSD គឺ បង្កើនផលិតភាពកសិកម្ម និង កែលម្អលទ្ធភាពទីផ្សារលក់ផលិតផល របស់កសិករប្រមាណ 630.000 គ្រួសារ ក្នុងខេត្តទាំងបួន ក្នុងតំបន់អាងបឹងទន្លេសាប នៅឆ្នាំ 2020។ *គោលបំណង* របស់គម្រោង គឺ សម្រេចឲ្យបាននូវការកើនឡើងនូវផលិតភាពកសិកម្ម និង កែលម្អលទ្ធភាពរកទីផ្សារលក់កសិផល សម្រាប់កសិករក្នុងឃុំ-សង្កាត់គោលដៅចំនួន 196 ក្នុង ខេត្តទាំងបួន។

3. គម្រោងមានភ្នាក់ងារប្រតិបត្តិចំនួន 2 គឺ លេខាធិការដ្ឋាន គ.ជ.អ.ប និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គម្រោងមានភ្នាក់ងារអនុវត្តចំនួន 4 គឺ (i) លេខាធិការដ្ឋាន គ.ជ.អ.ប (NCDDS), (ii) អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF/GDA), (iii) អាជ្ញាធរជាតិ ណៃដា (NiDA) និង (iv) អង្គភាពសម្របសម្រួលការអភិវឌ្ឍ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF/DCU)។[2]

4. ក្នុងផែនការបឋមដំបូងរបស់ គម្រោង ឃុំ សង្កាត់ទាំង196 ត្រូវបែងចែកជាបីដំណាក់កាល គឺ ដំណាក់កាលទី 1 មានឃុំ សង្កាត់ចំនួន 16 នឹងត្រូវចាប់ផ្តើមជួយ ក្នុងឆ្នាំ 2012, ដំណាក់កាលទី **2** មាន ឃុំ សង្កាត់ 88 នឹងត្រូវជួយក្នុងឆ្នាំ 2013 ហើយឃុំ សង្កាត់នៅសល់ដំណាក់កាលទី 3 នឹងត្រូវចាប់ផ្តើមជួយដើមឆ្នាំ 2014។ តែដោយមានវឌ្ឍភាពល្អក្នុងអំឡុងឆ្នាំ 2013 គម្រោងបានពង្រីកតំបន់គ្របដណ្តប់របស់ខ្លួន ដោយបញ្ចូលឃុំ សង្កាត់ដំណាក់កាលទី 2 និងទី 3 សរុបចំនួន 180 ឃុំ សង្កាត់ ក្នុងក្រុង ស្រុកគោលដៅទាំង 28។ ដូច្នេះ ការពង្រីកវិសាលភាពផ្ទៃដណ្តប់តំបន់គោលដៅទាំងអស់របស់គម្រោង ត្រូវបានសម្រេចទាំងស្រុងក្នុងឆ្នាំ 2013។

---

[1] ក្របខ័ណ្ឌគ្រោងរចនា និងពិនិត្យតាមដាន (DMF) របស់គម្រោង មានបង្ហាញក្នុង ឧបសម្ព័ន្ធ 1។ ក្របខ័ណ្ឌនេះ នឹងត្រូវពិនិត្យមើល និងធ្វើបច្ចុប្បន្នភាពឡើងវិញ ក្នុងអំឡុងបេសកកម្មពិនិត្យវាយតម្លៃវឌ្ឍនភាពគម្រោង នៅខែ កុម្ភៈ ឆ្នាំ 2014។

[2] ការចូលរួមរបស់មន្ត្រីពីអាជ្ញាធរជាតិណៃដា (NiDA) នឹងបន្តត្រឹមតែចុងត្រីមាសទី 1 ឆ្នាំ 2014។

5. គម្រោងមានសមាសភាគចំនួន ៣ គឺ (i) ការអភិវឌ្ឍឃុំ-សង្កាត់ តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ ឬ កញ្ចប់ថវិកាជំនួយឥតសំណងឃុំ-សង្កាត់ (NCDDS), (ii) ការបង្កើនផលិតភាពកសិកម្ម (MAFF/GDA & NiDA)និង (iii) ការគ្រប់គ្រងគម្រោងមានប្រសិទ្ធភាព (គ្រប់ភ្នាក់ងារអនុវត្តគម្រោងទាំងអស់)។

## C. ផែនការសកម្មភាពសម្រាប់ឆ្នាំ 2014

### C1. បញ្ហា និង ការប្រឈម

6. ក្នុងអំឡុងឆ្នាំ 2013 មានបញ្ហាមួយចំនួន បានលេចចេញឡើង ហើយផែនការសកម្មភាព និងថវិកាឆ្នាំនេះ ត្រូវបានរៀបចំឡើង ដោយពិចារណានូវកត្តាកម្រិតទាំងឡាយដែលបានកើតមានឡើង ដើម្បីព្យាយាម និងធានាថា ផលប៉ះពាល់របស់កត្តាកម្រិតទាំងនេះមកលើការអនុវត្តសកម្មភាពក្នុងឆ្នាំ 2014 ត្រូវបានកាត់បន្ថយឲ្យនៅតិចបំផុត។ បញ្ហា/កត្តាមក្រិតទាំងនេះត្រូវបានពិភាក្សាដូចខាងក្រោមនេះ៖

- ✓ **ការលំបាក ដែលបានជួបប្រទះក្នុងការរៀបចំចងក្រងក្រុម LIGs**។ ជាលទ្ធផលនៃការធ្វើចំណាកស្រុករយៈពេលវែងដោយគ្រួសារក្រីក្រ ពិសេសនៅខេត្ត បន្ទាយមានជ័យ និង ខេត្ត សៀមរាប, មើលទៅទំនងជាលំបាកខ្លាំង សម្រាប់ភូមិមួយចំនួន ក្នុងការកំណត់រកគ្រួសារជាសក្តានុពល បានគ្រប់ចំនួន ចូលជាសមាជិក LIG។ ក្នុងភូមិជាច្រើនមធ្យោបាយតែមួយគត់ដែលអាចចងក្រងក្រុម LIG មានសមាជិកតិចបំផុតចំនួន 10នាក់ នោះ គឺ តាមរយៈការបញ្ចូលសមាជិកខ្លះ មកពីគ្រួសារមានជីវភាពគ្រាន់បើ។ នៅកិច្ចប្រជុំសម្របសម្រួលគម្រោងប្រចាំឆមាស លើកទី ២ អង្គប្រជុំបានឯកភាពគ្នាថា នឹងកែសម្រួលគោលការណ៍ណែនាំចងក្រងក្រុម ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ហើយដាក់ឲ្យ ADB ពិនិត្យ និងផ្តល់អនុលោមភាព។
- ✓ **ការលំបាកក្នុងការស្វែងរកបានគ្រប់គ្រាន់គ្រួសារក្រីក្រកម្រិត-2 ដែលចាប់អារម្មណ៍ចូលរួមក្រុម** LIGs **ហើយបន្តចិតនៅជាសមាជិកក្រុម។** ក្រៅពីបញ្ហាជាមួយការកំណត់រកគ្រួសារក្រីក្រកម្រិត-2 (ID2 Poor) តាមភូមិ ក៏មានបញ្ហាផងដែរ ក្នុងការរកគ្រួសារក្នុងចំណោម ID2 Poor ដែលចង់ចូលរួមក្នុងក្រុម LIGs។ បញ្ហាចំបងដែលបានជួបប្រទះនោះគឺ ការពន្យារពេលយូរក្នុងការចងក្រងក្រុម LIG និង ពេលវេលារងចាំបន្ថែម នៅពេលដែលនិតិវិធីប្រើប្រាស់សម្រាប់ចងក្រងក្រុម LIG និមួយៗ កំពុងត្រូវបានពិនិត្យវាយតម្លៃនោះ។ ការពន្យារពេលយូរនេះ បាធ្វើឲ្យសមាជិកក្រុមខ្លះសម្រេចចិត្តចាកចេញពីសមាជិកក្រុម។ ក្នុងឆ្នាំ 2014 នេះ ការចាប់ផ្តើមដំណើរការរបស់ក្រុមហ៊ុនសេវាកម្មជំនាញ ដើម្បីគាំទ្រ ការកសាងសមត្ថភាព និងការណែនាំផ្ទាល់ដល់ក្រុម LIG ទាំងអស់ នឹងធានាថាសមាជិកក្រុម LIG នឹងបានចូលរួម ច្រើនជាមួយគម្រោង ហើយការនេះនឹងធានាឲ្យពួកគេកាន់តែមានចំណាប់អារម្មណ៍ច្រើនឡើង មុននឹងការរៀបចំបង្កើតទុនបង្វិលក្រុម (GRF) សម្រាប់ក្រុម LIG និមួយៗ។
- ✓ **ការជ្រើសរើសសេវាករតាមមូលដ្ឋាន សម្រាប់ផ្តល់ការបណ្តុះបណ្តាលដល់ក្រុម LIGs អាចមានការលំបាក**។ ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រុម LIGs ដើម្បីជួយគ្រួសារគាត់ក្នុងការអនុវត្តសកម្មភាពកែលម្អជីវភាព នឹងធ្វើឡើងតាមរយៈការជ្រើសរើសសេវាករ/គ្រូបណ្តុះបណ្តាលតាមមូលដ្ឋាន ដោយក្រុមប្រឹក្សាឃុំ សង្កាត់។ នៅពេលដែលគណនីទុនបង្វិលក្រុម ត្រូវបានបង្កើតដោយក្រុម LIGs នឹងមានតម្រូវការសេវាករ/គ្រូបណ្តុះបណ្តាលជាច្រើន ហើយទំនងជា

មិនមានគ្រូមានជំនាញគ្រប់គ្រាន់ សម្រាប់ឆ្លើយតបនឹងតម្រូវការ។ និតិវិធីលទ្ធកម្ម ដែលនឹងត្រូវអនុវត្តសម្រាប់ជួលសេវាករទាំងនេះ ក៏មានលក្ខណៈស្មុគស្មាញ ហើយអាចបណ្តាលឲ្យមានការពន្យារពេលថែមទៀតក្នុងការអនុវត្តសកម្មភាពកែលម្អជីវភាព។ ក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ដោយមានការគាំទ្រពីក្រុមសម្របសម្រួលថ្នាក់ខេត្ត និងទីប្រឹក្សាផ្សព្វផ្សាយកសិកម្មខេត្ត នឹងត្រូវបានជម្រុញលើកទឹកចិត្តឲ្យផ្តួចផ្តើមជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកំណត់រកសេវាករ/គ្រូបណ្តុះបណ្តាល មានលក្ខណៈសម្បត្តិសមស្រប ដែលអាចជួយគាំទ្រផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស សម្រាប់សមាជិកក្រុម LIG និង តាមដាននិតិវិធីលទ្ធកម្ម។ លើសពីនេះ ការចូលរួមរបស់កសិករធ្វើបង្ហាញពីគម្រោងTSTD ក្នុងនាមជាគ្រូបណ្តុះបណ្តាលនឹងត្រូវបានលើកទឹកចិត្តឲ្យអនុវត្តពេលណាអាចអនុវត្តកើត។

- ✓ **នឹងមានតម្រូវការឯកសារបណ្តុះបណ្តាលបច្ចេកទេសមានគុណភាពល្អ សម្រាប់គាំទ្រសមាជិកក្រុម LIG។** មានឯកសារផ្សព្វផ្សាយជាច្រើន (ទាំងក្នុងជាទម្រង់វីដេអូ និង ជាឯកសារបោះពុម្ព) ដែលត្រូវបានកំណត់រកបាន ប៉ុន្តែវាជាការសំខាន់ដែលត្រូវធានាថាឯកសារទាំងនេះ មានទម្រង់សមស្រប សម្រាប់ឲ្យគ្រួសារកសិករក្រីក្រ អាចទាញយកប្រយោជន៍ពីវាបាន។ នឹងត្រូវការកិច្ចប្រឹងប្រែងយ៉ាងច្រើន ដើម្បីធានាថាមានឯកសារបច្ចេកទេសគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់ក្នុងកម្មវិធីផ្តល់ព័ត៌មានចល័តតាមឃុំ សង្កាត់ (MCA) ។ ក្រុមទីប្រឹក្សាអនុវត្តគម្រោង បានផ្តល់ជំនួយយ៉ាងច្រើនដល់ GDAក្នុងការកំណត់រក និង កែលម្អឯកសារបណ្តុះបណ្តាលបច្ចេកទេស ហើយការនេះ នឹងជួយបង្គ្រប់បន្ថែមទៀតក្នុងឆ្នាំ 2014 តាមរយៈការជ្រើសរើសសេវាករ ដោយ NCDDS ដើម្បីរៀបចំបង្កើតមាតិកាមានលក្ខណៈពហុទម្រង់/មធ្យោបាយផ្សព្វផ្សាយ (ពហុ-មេឌា) ដើម្បីបញ្ចូលក្នុងកម្មវិធី MCA តាមរយៈវេបសាយរបស់គម្រោង។
- ✓ **ត្រូវការនូវការពិនិត្យតាមដាន និងការរាយការណ៍ស៊ីជម្រៅពីការអនុវត្តសកម្មភាពនៅថ្នាក់ក្រោមជាតិ -** របាយការណ៍វឌ្ឍនភាពត្រីមាស (QPRs) ពីខេត្តនិមួយៗ ត្រូវបានរៀបចំដាច់ផ្សេងពីគ្នា ដោយ ក្រុមសម្របសម្រួលថ្នាក់ខេត្ត និងអ្នកសម្របសម្រួលកសិកម្មខេត្តនឹងដាក់ជូនទៅភ្នាក់ងារអនុវត្តសាមីរបស់គេរៀងៗខ្លួន។ ក្រុមទីប្រឹក្សាអនុវត្តគម្រោងបានដើរតួទទួលខុសត្រូវក្នុងការបូកសរុបសំយោគចូលគ្នានូវរបាយការណ៍ទាំងនេះ ចូលជារបាយការណ៍វឌ្ឍនភាពត្រីមាសរបស់គម្រោង។ របាយការណ៍វឌ្ឍនភាពហិរញ្ញវត្ថុរបស់គម្រោង ត្រូវបានបូកសរុបសំយោគចូលគ្នា ដោយគណនេយ្យករ របស់ភ្នាក់ងារអនុវត្តនិមួយៗ ហើយដាក់ជូនមកទីប្រឹក្សាគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម (FPME) នៃក្រុម PIC ដើម្បីបូកសរុបសំយោគជារបាយការណ៍វឌ្ឍនភាពហិរញ្ញវត្ថុរួម របស់គម្រោង។ យ៉ាងណាក៏ដោយ ក្នុងត្រីមាសនិមួយៗ សមាជិកក្រុមទីប្រឹក្សា PIC (ប្រធាន និង អនុប្រធាន) ត្រូវចុះទៅតាមខេត្ត ដើម្បីជួបប្រជុំសួរបញ្ជាក់មាតិកាក្នុងរបាយការណ៍វឌ្ឍនភាពត្រីមាសរបស់ខេត្ត ពិសេសទិន្នន័យដែលបានបញ្ចូលក្នុងតារាងម៉ាទ្រិចប្រព័ន្ធ PPMS។ ការបណ្តុះបណ្តាលថែមទៀត នឹងត្រូវបានរៀបចំ ដើម្បីធានាថាបុគ្គលិកថ្នាក់ក្រោមជាតិ អាចរៀបចំរបាយការណ៍មានគុណភាពល្អប្រសើរជាងមុន ដោយមានទិន្នន័យតាមដានវឌ្ឍនភាពគម្រោង មានលក្ខណៈស៊ីចង្វាក់ សម្រាប់គាំទ្រដល់ការរាយការណ៍របស់ខ្លួន។ ក្នុងអំឡុងឆ្នាំ 2014 នេះ នឹងមានការបណ្តុះបណ្តាលថែមទៀត រៀបចំលើប្រធានបទស្តីពីប្រព័ន្ធពិនិត្យតាមដានគម្រោង សម្រាប់ឲ្យសមាជិកក្រុម PFTs, PACs និង DFT/DST ដើម្បីឲ្យពួកគេអាចដើរតួកាន់តែសំខាន់ឡើងក្នុងការរៀបចំចងក្រងរបាយការណ៍វឌ្ឍនភាព។

- ✓ **នៅតែមិនទាន់មានយុទ្ធសាស្ត្រអាចដំណើរការបានច្បាស់ សម្រាប់ផែនការផលិតកម្មពូជដំណាំ (ស្រូវ) -** ផែនការសកម្មភាព និងថវិកាឆ្នាំ រួមបញ្ចូលនូវយុទ្ធសាស្ត្រកំណត់យ៉ាងច្បាស់សម្រាប់ការស្តារសាងសង់ស្ថានីយ៍ស្រាវជ្រាវទាំងពីរ និង សម្រាប់ពង្រឹងក្រុមកសិករផលិតស្រូវពូជ។ ការអង្កេតថែមទៀត នឹងត្រូវធ្វើ ដើម្បីកំណត់ពីកម្រិតត្រូវការប្រភេទពូជស្រូវចំបងៗ ដែលនឹងឲ្យកែសម្រួលកាន់តែប្រសើរឡើងនូវផែនការផលិតកម្មសម្រាប់ស្ថានីយ៍ និង ក្រុមកសិករផលិតស្រូវពូជ។ ទោះបីជាតម្រូវការផលិតកម្មស្រូវពូជរបស់គម្រោង អាចងាយស្រួលអនុវត្តសម្រេចបាន ការប្រឈមជាចំបង គឺ ការលក់គ្រាប់ពូជដែលផលិតបាន។ ក្រុមទីប្រឹក្សាអនុវត្តឧតគម្រោង នឹងជួយគាំទ្រយ៉ាងសកម្មដល់ PACs ក៏ដូចជា GDA ក្នុងការរៀបចំបង្កើតនូវផែនការមានលក្ខណៈប្រទាក់គ្នាក្រឡាគ្នាមួយសម្រាប់ផលិតពូជស្រូវសុទ្ធ តាមរយៈក្រុមកសិករផលិតពូជស្រូវសុទ្ធ ដែលបានគាំទ្រដោយស្ថានីយ៍ស្រាវជ្រាវទាំងពីរ ក្នុងខេត្តកំពង់ធំ និង ខេត្តសៀមរាប និង តាមរយៈការភ្ជាប់ទំនាក់ទំនងជាមួយរោងម៉ាស៊ីនស្រូវតាមខេត្ត។

## C2. សេចក្តីសង្ខេបពីផែនការសកម្មភាព

7. គម្រោងទទួលបានវឌ្ឍនភាពប្រសើរឡើងក្នុងអំឡុងឆ្នាំ 2013 ដោយបានកែសម្រួលបញ្ចប់នូវគោលការណ៍ណែនាំទាំងអស់សម្រាប់គាំទ្រដល់ការរៀបចំចងក្រងក្រុមកែលម្អជីវភាព (LIGs) និងការប្រើប្រាស់កញ្ចប់ថវិកាឥតសំណងឃុំ សង្កាត់ (ឬ មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់)សម្រាប់គាំទ្រដល់សកម្មភាពកែលម្អជីវភាព ក៏ដូចជា គោលការណ៍ណែនាំសម្រាប់អនុវត្តសកម្មភាពគាំទ្រផ្នែកកសិកម្ម រួមទាំងការវិភាគប្រព័ន្ធកសិត្រ-បរិស្ថាន (AEA), ការរៀបចំធ្វើបង្ហាញបច្ចេកទេសកសិកម្ម, ការរៀបចំទិវាបូកសរុបផ្សព្វផ្សាយលទ្ធផលបង្ហាញ និងការដំណើរការសាលារៀនស្រែ-ចំការកសិករសម្រាប់ផលិតកម្មពូជស្រូវ។ ទោះបីមិនបានគ្រោងក្នុងឆ្នាំ 2013 គម្រោងបានពង្រីកវិសាលភាពគ្របដណ្តប់លើឃុំគោលដៅទាំង 180 ក្នុងឆ្នាំ2013 ដូច្នេះបច្ចុប្បន្ននេះ គម្រោងមានវិសាលភាពគ្របដណ្តប់តំបន់គោលដៅទាំងអស់របស់ខ្លួន ហើយភូមិគោលដៅចំនួន 1,239 ត្រូវបានជ្រើសរើសរួចហើយ។

8. ធាតុចំបងៗ នៃផែនការសកម្មភាពឆ្នាំ 2014 នេះ រួមមាន៖[3]

- ✓ គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទក្នុងឃុំ សង្កាត់គោលដៅ (ដំណាក់កាលទី 1 និង 2) ចំនួន 104 ដែលបានកំណត់ក្នុងឆ្នាំ 2013 កន្លងទៅ នឹងត្រូវបានបញ្ចប់។ ជុំបន្ទាប់នៃគម្រោងក្នុងឃុំ សង្កាត់គោលដៅទាំង 196 នឹងត្រូវបានកំណត់, គ្រោងការប្លង់ នឹងត្រូវបានរៀបចំ ហើយកិច្ចសន្យាសាងសង់ នឹងត្រូវចាប់ផ្តើមរៀបចំក្នុងអំឡុងត្រីមាសទី 2។
- ✓ ការរៀបចំចងក្រងក្រុមកែលម្អជីវភាព (LIGs) នឹងបន្តសម្រាប់ភូមិគោលដៅនៅសល់ចំនួន 839 បន្ទាប់ពីបានរួមបញ្ចូលនូវអនុសាសន៍របស់ក្រុមហ៊ុនផ្តល់សេវាកម្មជំនាញ SSP1 (សម្រាប់ត្រួតពិនិត្យមើលដំណើរការចងក្រងក្រុម LIG) ដោយផ្អែកលើ ការប៉ាន់ប្រមាណវាយតម្លៃរបស់បុគ្គលិកពួកគេ ទៅលើវិតីវិធីដែលបានប្រើ/អនុវត្តតាម ក្នុងអំឡុងពេលរៀបចំចងក្រងក្រុមLIG ដំបូងចំនួន 400ក្រុម។

---

[3] បញ្ជីសកម្មភាពលម្អិត តាមភ្នាក់ងារអនុវត្តនិមួយៗ មានបង្ហាញនៅក្នុង ឧបសម្ព័ន្ធ 2

- ✓ ការវិភាគប្រព័ន្ធកសិ-បរិស្ថាន (AEA) នឹងត្រូវធ្វើសម្រាប់ស្រុកនិមួយៗ ដែលនឹងសម្របសម្រួលដោយបុគ្គលិកការិយាល័យកសិកម្មស្រុក (DoA) សាមុីនិមួយៗ ហើយដោយមានជំនួយពីបុគ្គលិកមន្ទីរកសិកម្មខេត្ត (PDA)។
- ✓ មេឃុំ ចៅសង្កាត់ អ្នកផ្សព្វផ្សាយឃុំ សង្កាត់ និង ជំនួយការរដ្ឋបាលឃុំ សង្កាត់ទាំងអស់ នឹងទទួលបានការបណ្តុះបណ្តាល ស្តីពីគោលការណ៍ណែប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ (CDF) សម្រាប់គាំទ្រដល់សកម្មភាពកែលម្អជីវភាព និង ការបណ្តុះបណ្តាលពីជំនាញមូលដ្ឋានប្រើប្រាស់កុំព្យូទ័រ។ អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ ក៏នឹងត្រូវបានបណ្តុះបណ្តាលផងដែរ ដើម្បីបង្កើនសមត្ថភាពស្តីពី វិធីផ្សព្វផ្សាយ ការសម្របសម្រួលក្រុម និង បច្ចេកទេសផលិតកម្មកសិកម្មជាគន្លឹះមួយចំនួន។
- ✓ ក្រុមហ៊ុនផ្តល់សេវាកម្មជំនាញ SSP2 (បណ្តុះបណ្តាល និង ការណែនាំផ្ទាល់ដល់ក្រុម LIGs) កំពុងត្រូវបានជ្រើសរើស ហើយរំពឹងនឹងចាប់ផ្តើមកម្មវិធីកសាងសមត្ថភាព និងណែនាំធ្វើផ្ទាល់សម្រាប់ក្រុម LIGs, ហើយនឹងរៀបចំទុនបង្វិលក្រុម ឲ្យដំណើរការនៅចុងត្រីមាសទី 2។
- ✓ តាមឃុំគោលដៅទាំង 196 អន្តរាគមន៍(កម្មវិធី)សម្រាប់កែលម្អជីវភាពជាអាទិភាព នឹងត្រូវបានកំណត់រកឲ្យឃើញភាគច្រើនផ្អែកលើផែនការវិនិយោគឃុំ សង្កាត់ (CIPs) ហើយផែនការធុរកិច្ច (ផែនការមុខរបរ) សម្រាប់ក្រុមកែលម្អជីវភាព (LIGs) នឹងត្រូវបានរៀបចំ ដោយមានជំនួយពីក្រុមហ៊ុនផ្តល់សេវាកម្មជំនាញ SSP2 ហើយបន្ទាប់ពីទទួលបានអនុលោមភាពពីក្រុមប្រឹក្សាឃុំ សង្កាត់ ប្រាក់កម្ចី អាចផ្តល់ឲ្យសមាជិកក្រុម ដោយយកថវិកាពីទុនបង្វិលក្រុម (GRFs)។
- ✓ ក្រុមហ៊ុនផ្តល់សេវាកម្មជំនាញ SSP3 (កម្មវិធីសុខភាព និង ផលិតកម្មសត្វ) កំពុងត្រូវបានជ្រើសរើស ហើយរំពឹងនឹងចាប់ផ្តើមការងារផ្តល់ការគាំទ្រដល់កម្មវិធីចាក់ថ្នាំបង្ការជម្ងឺសត្វតាមឃុំ សង្កាត់គោលដៅទាំងអស់សម្រាប់សត្វគោ-ក្របី ជ្រូក និង មាន់ សម្រាប់បង្ការជម្ងឺមួយចំនួន ហើយសេវាចាក់ថ្នាំបង្ការនេះ នឹងត្រូវផ្តល់ឲ្យដោយភ្នាក់ងារសុខភាពភូមិ (VAHWs) ដែលនឹងទទួលបានការបណ្តុះបណ្តាលបន្ថែម នៅត្រីមាសទី 2 ឆ្នាំ 2014 ។
- ✓ កម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាព សម្រាប់បុគ្គលិកឃុំ សង្កាត់ រួមទាំង អ្នកផ្សព្វផ្សាយឃុំ សង្កាត់ និងជំនួយការរដ្ឋបាលឃុំ សង្កាត់ផង នឹងត្រូវរៀបចំឡើង ផ្អែកលើលទ្ធផលប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល ហើយដែលនឹងត្រូវផ្តល់ឲ្យដោយសេវាករជំនាញ/គ្រូបណ្តុះបណ្តាល ដែលនឹងជ្រើសរើសដោយ NCDDS។ លើសពីនេះ អ្នកផ្សព្វផ្សាយឃុំ សង្កាត់ នឹងទទួលបានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឧបករណ៍ផ្តល់ព័ត៌មានចល័ត (tablets) ដែលនឹងធ្វើលទ្ធកម្មដោយ NiDA។
- ✓ នឹងមានការគាំទ្រជាបន្តសម្រាប់ការអភិវឌ្ឍន៍គោលនយោបាយកសិកម្ម តាមរយៈសិក្ខាសាលាបង្កើនការយល់ដឹងនៅថ្នាក់ខេត្ត ដោយមានបញ្ចូលទាំងប្រធានបទស្តីពី លំនាំដើមពីការអនុវត្តកសិកម្មល្អ (GAP) និង ផលិតកម្មតាមកិច្ចសន្យា ភ្ជាប់ជាមួយនឹងកម្មវិធិផលិតកម្មស្រូវពូជ។
- ✓ ការសិក្សាអនុវត្តសាកល្បងស្តីពីការផ្សព្វផ្សាយបញ្ចូលការអនុវត្ត GAP នឹងត្រូវបន្តធ្វើនៅខេត្ត សៀមរាប ដោយធ្វើការជាមួយក្រុមកសិករផលិតទាំងបួន ដែលបានកំណត់ជ្រើសរើសឲ្យចូលរួមក្នុងផលិតកម្មដំណាំបន្លែ និងផ្លែឈើ ហើយ

នឹងបញ្ចប់សាលារៀនស្រែកសិករ។ បន្ទាប់មកទៀត គម្រោងនឹងរៀបចំការបណ្ដុះបណ្ដាលស្ដីពីនិតិវិធីសវនកម្មផ្ទៃក្នុងក្រុម និង ការចាប់ផ្ដើមសកម្មភាពបង្កើនការយល់ដឹងរបស់អ្នកប្រើប្រាស់ ក្នុងក្រុងសៀមរាប។ ការអង្កេតពីឱកាសទីផ្សារជាសក្ដានុពលសម្រាប់ផលិតផលមានបញ្ជាក់លក្ខណៈការអនុវត្តកសិកម្មល្អ (GAP) ហើយ ការបង្កើនការយល់ដឹងរបស់អ្នកប្រើប្រាស់ ត្រូវបានរំកិលទៅអនុវត្ត ក្នុងត្រីមាសទី1 ឆ្នាំ 2014។ មានសាលារៀនស្រែ-ចំការកសិករស្ដីពី GAP ចំនួនប្រាំពីរ នឹងត្រូវរៀបចំក្នុងស្រុកគោលដៅថ្មី ក្នុងខេត្ត សៀមរាប។

- ✓ នៅខេត្តកំពង់ចាម យុទ្ធសាស្ត្រស្រដៀងគ្នានេះ ក៏នឹងត្រូវបានប្រើប្រាស់ សម្រាប់ការផ្សព្វផ្សាយបញ្ចូលការងារស្ដីពីការអនុវត្តកសិកម្មល្អ ផ្អែកលើមេរៀនដកពិសោធន៍បានពីការអនុវត្តសកម្មភាពនៅខេត្តសៀមរាប ដោយរៀបចំចងក្រងក្រុមកសិករផលិតចំនួនបួន នៅចុងឆ្នាំ 2014 ហើយបន្ទាប់មក នឹងចាប់ផ្ដើមសកម្មភាពសាលារៀនស្រែ-ចំការកសិករ តាមក្រុមនិមួយៗ។

- ✓ ក្នុងខេត្តកំពង់ធំ ការសិក្សាអនុវត្តសាកល្បងខ្នាតតូចស្ដីពីផលិតកម្មតាមកិច្ចសន្យា សម្រាប់ផលិតកម្មស្រូវ នឹងត្រូវរៀបចំធ្វើ ដោយមានគោលដៅសម្របសម្រួលរៀបចំសន្យាចំនួនពីរ សម្រាប់ផលិតកម្មស្រូវចំណី និងគ្រាប់ពូជស្រូវរវាងរោងម៉ាស៊ីនស្រូវ និងក្រុមកសិករ (ផលិតស្រូវចំណី និងស្រូវពូជ)។ ការរៀបចំកិច្ចសន្យា នឹងត្រូវបានសម្របសម្រួលដោយមន្ទីរកសិកម្មសាមី។ សិក្ខាសាលាឆ្លុះបញ្ចាំង នឹងត្រូវរៀបចំនៅចុងឆ្នាំ ដោយមានការចូលរួមពីតំណាងមន្ទីរកសិកម្មខេត្តផ្សេងទៀត ដើម្បីពិនិត្យមើលពីវឌ្ឍនភាពទទួលបាន។

- ✓ សេចក្ដីព្រាងស្ដីពីក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយឥទ្ធិពលបម្រែបម្រួលអាកាសធាតុ ត្រូវបានរៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយ ដោយមានជំនួយពីទីប្រឹក្សាផ្នែកបរិស្ថាន និងបម្រែបម្រួលអាកាសធាតុ នៃក្រុមទីប្រឹក្សាអនុវត្តគម្រោង (PIC) គម្រោង នឹងគាំទ្រដល់ការសិក្សាពិនិត្យមើលពីឯកសារនេះ ក៏ដូចជា ឯកសារយោង/ក្របខ័ណ្ឌមានស្រាប់របស់ ADB ស្ដីពីការគ្រប់គ្រងបរិស្ថាន/បម្រែបម្រួលអាកាសធាតុ ហើយប្រើប្រាស់ឯកសារទាំងនេះជាមូលដ្ឋានសម្រាប់ការរៀបចំបង្កើតឡើងនូវវិធានការអនុវត្តជាក់ស្ដែងមានលក្ខណៈសម្រប សម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីបណ្ដុះបណ្ដាល/ធ្វើបង្ហាញ និង សកម្មភាពកែលម្អជីវភាព នៅតាមមូលដ្ឋាន។ បទពិសោធន៍ពីគម្រោងផ្សេងទៀត (ដែលបានអនុវត្តដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម GDA-DAE) ក៏នឹងត្រូវបានប្រើប្រាស់ តាមរយៈវេទិកាចែករំលែក/ផ្លាស់ប្ដូរជាផ្លូវការ (សិក្ខាសាលាថ្នាក់ជាតិ ស្ដីពីការអភិវឌ្ឍគោនយោបាយ និងការរៀនសូត្រ/ដកពិសោធន៍ផ្នែកការសម្របនឹងបម្រែ បម្រួលអាកាសធាតុ) ហើយនិងទស្សនកិច្ចសិក្សាស្វែងយល់មួយចំនួនទៀត។ ខ្លឹមសារអនុវត្តជាក់ស្ដែង / បញ្ជីផ្ទៀងផ្ទាត់សកម្មភាពតាមមូលដ្ឋាន (field checklist) សម្រាប់ការគ្រប់គ្រងបរិស្ថាន នឹងត្រូវបង្កើតឡើងសម្រាប់ការអនុវត្ត (បច្ចេកទេស) កសិកម្មគន្លឹះៗចំនួនប្រាំ ដែលនឹងត្រូវរៀបចំបញ្ចប់ នៅក្នុងអំឡុងឆ្នាំ នេះ។

- ✓ នៅស្ថានីយ៍ស្រាវជ្រាវបល្ល័ង្គ ក្នុងខេត្តកំពង់ធំ និង នៅស្ថានីយ៍ទឹកវិល ក្នុងខេត្តសៀមរាប[4] ការគាំទ្រដែលបានគ្រោងសម្រាប់ការស្ដារ/ជួសជុល នឹងត្រូវអនុវត្តឲ្យចប់តាមផែនការ ដើម្បីផ្ដល់សមត្ថភាពដល់ស្ថានីយ៍ ក្នុងការស្តុកមានលក្ខណៈប្រសើរឡើង និងការផ្គត់ផ្គង់ទឹកស្រោចស្រពកាន់តែមានប្រសិទ្ធភាពឡើង ដែលនឹងអនុញ្ញាតិឲ្យស្ថានីយ៍

[4] គ្រោងរចនា (ប្លង់)ស្រែ នឹងត្រូវកែលម្អ រួមទាំងការកៀរពង្រាបដីស្រែ ផង។

ទាំងពីរ មានសមត្ថភាពផលិតគ្រាប់ពូជយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ (ការស្តារ/ជួសជុលនេះ ត្រូវបានរំកិលពីឆ្នាំ 2013 មក)។ គ្រាប់ពូជសុទ្ធគ្រឹះនៃប្រភេទពូជស្រូវត្រូវការមួយចំនួន នឹងត្រូវបានទិញផ្ទាល់ពី CARDI ដោយស្ថានីយ៍ស្រាវជ្រាវនិមួយៗ ហើយយកមកដាំតាមស្ថានីយ៍សម្រាប់ផលិតជាពូជសុទ្ធអនុញ្ញាតិ សម្រាប់លក់ឲ្យក្រុមកសិករផលិតគ្រាប់ពូជ (RSPGs)។ កម្មវិធីផលិតកម្មពូជស្រូវសុទ្ធ នៅតាមស្ថានីយ៍និមួយៗ នឹងត្រូវតម្រូវតាមតម្រូវការប៉ាន់ស្មានរបស់ក្រុមកសិករផលិតពូជ ក្នុងខេត្តនិមួយៗ។ កិច្ចសន្យាផលិត នឹងត្រូវបានជួយសម្របសម្រួលរវាងក្រុមកសិករផលិតពូជ និង ស្ថានីយ៍ស្រាវជ្រាវ ដើម្បីឆ្លើយតបនឹងតម្រូវការគ្រាប់ពូជស្រូវ ដោយផ្តល់នូវការធានាផ្តល់តម្លៃគោល 0,6 ដុល្លារ ក្នុង 1 គីឡូក្រាម គ្រាប់ពូជសុទ្ធអនុញ្ញាតិមានគុណភាព។

- ✓ កម្មវិធីកសាងសមត្ថភាពសម្រាប់ក្រុមកសិករផលិតស្រូវពូជ នឹងត្រូវបន្តធ្វើទៀត ដើម្បីអភិវឌ្ឍន៍ជំនាញ/បំនិនផ្នែកបច្ចេកទេស/ធ្វើទីផ្សារ និង ផ្នែកគ្រប់គ្រង សម្រាប់សមាជិកក្រុម ហើយនឹងមានការគាំទ្រដល់ក្រុមលើផ្នែកបរិក្ខារកែច្នៃ និងស្តុកទុកដាក់របស់គេ ដូចដែលបានកំណត់រកឃើញក្នុងការអង្កេត ធ្វើនៅឆ្នាំ 2013។ ក្រុមកសិករផលិតស្រូវពូជ នឹងត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងការផលិតពូជសុទ្ធគុណភាព ដោយប្រើប្រាស់ពូជសុទ្ធអនុញ្ញាតិ ផលិតដោយស្ថានីយ៍ និង ដើម្បីបង្កើតចំណងទាក់ទងផ្នែកទីផ្សារជាមួយរោងម៉ាស៊ីនស្រូវ ដើម្បីផលិតពូជសុទ្ធគុណភាពសម្រាប់ប្រភេទពូជស្រូវ ដែលមានតម្រូវការមួយចំនួន។
- ✓ មានទីតាំងធ្វើបង្ហាញចំនួន 432 នឹងត្រូវគ្រោងរៀបចំសម្រាប់បង្ហាញបច្ចេកទេសផលិតកម្មស្រូវ (ប្រពលវប្បកម្ម និងពូជពេញនិមយ) បន្លែ ផ្សិត ដំណាំលក់ (ដំណាំចំការ /ដំណាំឆ្លងកាត់) ចិញ្ចឹមសត្វ និង វារីវប្បកម្ម។
- ✓ យុទ្ធនាការផ្សព្វផ្សាយ នឹងត្រូវចាប់ផ្តើមក្នុងខេត្តនិមួយៗ ដើម្បីបង្កើនការយល់ដឹងពីកម្មវិធីផលិតកម្មគ្រាប់ពូជស្រូវសុទ្ធ និង កម្មវិធីផ្សេងទៀត ហើយឯកសារផ្សព្វផ្សាយ ក៏នឹងត្រូវផលិត និងចែកចាយ តាមគ្រប់ស្រុក ផងដែរ។
- ✓ នឹងមានការប្រជុំជាប្រចាំឆមាស រៀបចំឡើងដោយ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍កសិកម្ម និងជនបទ (CARD) ដែលតាមរយៈកិច្ចប្រជុំនេះ វឌ្ឍនភាពគម្រោង នឹងត្រូវបានពិនិត្យមើល និង ផ្តល់យោបល់ ហើយបញ្ហា និងការប្រឈមចំបងៗ និងដំណោះស្រាយ/វិធានការកែតម្រូវ នឹងត្រូវស្នើឡើង។
- ✓ ដើម្បីរក្សាបាននូវកិច្ចសម្របសម្រួលល្អនៅថ្នាក់ក្រោមជាតិ ការប្រជុំសម្របសម្រួលប្រចាំខែ នឹងត្រូវបានរៀបចំនៅថ្នាក់ស្រុកក្នុងគ្រប់ស្រុកទាំងអស់ ហើយនិងក្នុងខេត្តនិមួយៗ ដោយមានការចូលរួមពីក្រុមថ្នាក់ជាតិ ក្នុងកិច្ចប្រជុំថ្នាក់ខេត្ត។ ជនបង្គោលយេនឌ័រ នឹងចូលរួមក្នុងកិច្ចប្រជុំសម្របសម្រួលទាំងនេះ ហើយនឹងទទួលបាននូវការបណ្តុះបណ្តាលថែមទៀតសម្រាប់ដោះស្រាយបញ្ហាផ្នែកសង្គម និងយេនឌ័រ។ នៅថ្នាក់ជាតិ នឹងមានកិច្ចប្រជុំសម្របសម្រួលប្រចាំឆមាស ដែលនឹងរៀបចំ (មុនកិច្ចប្រជុំគណកម្មការតម្រង់ទិសគម្រោងនិមួយៗ) ឆ្លាស់វេនគ្នារវាងក្រសួងកសិកម្ម (MAFF/DCU) និង លេខាធិការដ្ឋាន គ.ជ.អ.ប (NCDDS)។
- ✓ ក្រោមសមាសភាគទី 2 នឹងមានការប្រជុំត្រីមាស រៀបចំប្តូរវេនគ្នា ដោយខេត្តនិមួយៗ។ ការប្រជុំនេះ នឹងត្រូវចូលរួមដោយ អ្នកសម្របសម្រួលកសិកម្មខេត្ត ទីប្រឹក្សាផ្សព្វផ្សាយកសិកម្មខេត្ត និង ក្រុមការងារថ្នាក់ជាតិ។
- ✓ ក្រុមការងារថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ នឹងរៀបចំត្រួតពិនិត្យជាប្រចាំលើសកម្មភាពទាំងអស់របស់គម្រោង។

- ✓ នឹងបន្តការផ្ទេរជំនាញផ្នែកហិរញ្ញវត្ថុ និងគ្រប់គ្រង តាមរយៈការបណ្តុះបណ្តាលដល់ថ្នាក់ឃុំ សង្កាត់ ដោយក្រុមថ្នាក់ខេត្ត។
- ✓ កម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាព នឹងបន្តផ្តល់ឲ្យដល់ក្រុមការងារថ្នាក់ក្រុង ស្រុក។ កម្មវិធីបណ្តុះបណ្តាលចំបងៗដែលបានគ្រោងសម្រាប់ថ្នាក់ក្រោមជាតិរួមមានផលិតកម្មស្រូវពូជ ការអនុវត្តកសិកម្មល្អ វិធីសាស្ត្រផ្សព្វផ្សាយ ការបង្កើនការយល់ដឹងពីយេនឌ័រ ការបង្កើនការយល់ដឹងពីការគ្រប់គ្រងបរិស្ថាន/ការបម្រែបម្រួលអាកាសធាតុ និងវិធានការសម្រាប់កាត់បន្ថយឥទ្ធិពល ការបណ្តុះបណ្តាលជំនាញសម្រាប់គ្រូបង្គោល និង ប្រព័ន្ធពិនិត្យតាមដានគុណផលអនុវត្តគម្រោង PPMS (+ project MIS/databases)។
- ✓ ដើម្បីពង្រីកចំណេះដឹងរបស់ក្រុមអនុវត្តគម្រោង នឹងមានទស្សនកិច្ចសិក្សា រៀបចំទៅខេត្តផ្សេងទៀត ដើម្បីសិក្សាដកពិសោធន៍ពីគម្រោងផ្សេងទៀតដែលមានលក្ខណៈស្រដៀងគ្នា ក្នុងនោះមានទាំងគម្រោងដែលគាំទ្រដោយ IFAD។ ទស្សនកិច្ចសិក្សា នឹងត្រូវបានរៀបចំសម្រាប់សិក្សាដកពិសោធន៍ការងារសម្រប/ការបន្ថយឥទ្ធិពលបម្រែបម្រួលអាកាសធាតុ របស់គម្រោងផ្សេងទៀត ក្នុងខេត្តផ្សេង។
- ✓ ការសិក្សាទិន្នន័យដើមគ្រា នឹងត្រូវបញ្ចប់ក្នុងក្រុង ស្រុកគោលដៅទាំង 28 និងក្រុង ស្រុកមិនមែនគោលដៅចំនួនបួន (ជាស្រុកកស្សិណ) តាមរយៈការគាំទ្រពីក្រុមហ៊ុនជួលពីក្រៅ ដែលបានជ្រើសរើសឲ្យផ្តល់សេវាកម្មនេះ ដោយ NCDDS។ ការចុះអង្កេតតាមភូមិ បានចាប់ផ្តើមនៅខែមករា ហើយរបាយការណ៍ចុងក្រោយ នឹងត្រូវបញ្ចប់នៅចុងត្រីមាសទី 1។ ប្រព័ន្ធ PPMS នឹងត្រូវបានកែសម្រួល និងសម្របកាន់តែប្រសើរថែមទៀត ដើម្បីបញ្ចូលរាល់សកម្មភាពក្នុងផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ 2014 នេះ។
- ✓ ដំណើរការកសាងផែនការឆ្នាំ សម្រាប់ឆ្នាំ 2015 នឹងត្រូវសម្រេចបាន តាមរយៈដំណើរការដោយមានការចូលរួមពេញលេញដែលនឹងចាប់ផ្តើមពីសិក្ខាសាលាកសាងផែនការថ្នាក់ក្រុង ស្រុកសិក្ខាសាលាផែនការថ្នាក់ខេត្តតាមខេត្តគោលដៅនិមួយៗ ហើយបន្ទាប់មក សិក្ខាសាលាថ្នាក់ជាតិសម្រាប់បូកសរុបជាផែនការសកម្មភាព និងថវិកាឆ្នាំ។
- ✓ ទីប្រឹក្សាអនុវត្តន៍គម្រោង (PIC) នឹងបន្តផ្តល់ការគាំទ្រដល់ភ្នាក់ងារអនុវត្តនិមួយៗ (IAs) ក្នុងអំឡុងឆ្នាំទាំងមូល ហើយ ទីប្រឹក្សាថ្នាក់ខេត្ត នឹងនៅបន្តរក្សាទុកដោយ NCDDS និង MAFF។

9. ថវិកាសរុបប្រចាំឆ្នាំ 2014នេះ ប៉ាន់ប្រមាណទៅមានប្រហែលជា 22,2 លានដុល្លារសហរដ្ឋអាមេរិក។[5] ការវិភាជន៍ថវិកាតាមភ្នាក់ងារអនុវត្តន៍ មាន 85,8%, 7,4%, 5,4% និង 1,4% តាមលំដាប់រៀងគ្នាសម្រាប់ NCDDS, MAFF/GDA, MAFF/DCU និង NiDA។ ការវិភាជន៍ថវិកាចូលរួមរបស់ ADB មាន 12,5% ជាកម្ចី និង 45,9% ជាជំនួយឥតសំណង; សម្រាប់ IFAD មាន 10,7% ពីកម្ចី និងជំនួយឥតសំណង; សម្រាប់រដ្ឋាភិបាលហ្វាំងឡង់ មាន 5% ហើយបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា មាន 15%។[6]

---

[5] តារាងថវិកាលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ 3

[6] ចំណាយបូកយោងពីជំនួយឥតសំណងរបស់រដ្ឋាភិបាលហ្វាំងឡង់ មិនអាចលើសពី 1,25 លានអឺរ៉ូ ហើយត្រូវបញ្ចប់នៅចុងឆ្នាំ 2014។

ថវិកាឆ្នាំ 2014 (USD)

ខេត្តទាំងអស់

| ភ្នាក់ងារប្រតិបត្តិ | ចំនួនថវិកា (USD) | | | | |
|---|---|---|---|---|---|
| | ត្រីមាសទី 1 | ត្រីមាសទី 2 | ត្រីមាសទី 3 | ត្រីមាសទី 4 | សរុប |
| ភ្នាក់ងារអនុវត្ត | | | | | |
| NCDDS | 4.219.894 | 6.802.609 | 7.258.649 | 790.859 | 19.072.011 |
| GDA | 473.990 | 602.550 | 266.471 | 311.400 | 1.654.411 |
| NiDA | 304.575 | 0 | 0 | 0 | 304.575 |
| DCU | 285.350 | 320.100 | 314.400 | 276.400 | 1.196.250 |
| ប្រភពថវិកា | 5.283.809 | 7.725.259 | 7.839.520 | 1.378.659 | 22.227.247 |
| កម្ចី ADB | 678.500 | 1.150.000 | 960.250 | 0 | 2.788.750 |
| ជំនួយឥតសំណង ADB | 2.694.259,6 | 3.598.100,6 | 2.860.558,5 | 1.058.164,6 | 10.211.083,3 |
| កម្ចី IFAD | 90.270 | 750.600 | 1.430.595 | 114.000 | 2.385.465 |
| ជំនួយឥតសំណង IFAD | 90.270 | 750.600 | 1.430.595 | 114.000 | 2.385.465 |
| រដ្ឋាភិបាលហ្វាំងឡង់ | 831.960 | 167.400 | 94.500 | 21.600 | 1.115.460 |
| រដ្ឋាភិបាលកម្ពុជា | 898.549,4 | 1.308.558,4 | 1.063.021,5 | 70.894,4 | 3.341.023,7 |
| សរុប | 5.283.809 | 7.725.259 | 7.839.520 | 1.378.659 | 22.227.247 |






## C.3 សមាសភាគទី 1: ការអភិវឌ្ឍឃុំ-សង្កាត់ តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ (NCDDS)

### C.3.1 ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដែលគាំទ្រផលិតភាពកសិកម្ម

10. គម្រោងនឹងបន្តផ្តល់ថវិកាសម្រាប់ការអភិវឌ្ឍ និង ការកែលម្អឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធជនបទខ្នាតតូច ដើម្បីគាំទ្រដល់ផលិតភាពកសិកម្មកាន់តែខ្ពស់ឡើង ជាមួយនឹងការវិនិយោគ ដូចបានកំណត់នៅក្នុងផែនការវិនិយោគឃុំ សង្កាត់ (CIPs)។ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចធ្វើវិភាជន៍/បែងចែករហូតដល់ 43 ភាគរយនៃចំនួនថវិកាវិភាជន៍គម្រោងរបស់ពួកគេ សម្រាប់ការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធជនបទ។ យ៉ាងតិចមានទឹកប្រាក់ចំនួន 10 ភាគរយនៃតម្លៃចំណាយវិនិយោគគម្រោងហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានវិភាជន៍ (លៃទុក) សម្រាប់ការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធ រួមទាំងហេដ្ឋារចនាសម្ព័ន្ធ ដែលផ្តល់ថវិកាសាងសង់ដោយគម្រោងនេះផង។ ការវិនិយោគ ទំនងជាមានទម្រង់ជាការសាងសងសម្រាប់យកទឹកប្រើប្រាស់ (ស្រោចស្រព) មានលក្ខណៈខ្នាតតូច គ្រប់គ្រងដោយកសិករ ដែលរួមមានប្រព័ន្ធប្រឡាយចែកចាយស្រោចស្រពកម្រិតទីបី និង ការសាងសង់ទំនប់ការពារទឹកជំនន់ ឬ ប្រព័ន្ធបណ្តោះទឹក; ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីការពារ និងអភិរក្សធនធានធម្មជាតិ នៅក្នុង និងជុំវិញសហគមន៍គោលដៅរបស់គម្រោង; សំណង់ និងការស្តារ/ជួសជុលផ្លូវលំតភ្ជាប់ពីកសិដ្ឋាន-ទៅ-ទីផ្សារ; ផ្សារឃុំ; បរិក្ខារស្តុកទុកដាក់ និងហាលសម្ងួតកសិផល។[7] ថវិការបស់គម្រោងសម្រាប់វិនិយោគឃុំ សង្កាត់មានលក្ខណៈជាមូលនិធិ(ទំហំតូច)បន្ថែម លើមូលនិធិឃុំ-សង្កាត់។ ឃុំ សង្កាត់ក៏អាចប្រើថវិកាគម្រោងផងដែរ ដោយភ្ជាប់ជាមួយមូលនិធិឃុំ-សង្កាត់ ឬ ថវិកាពីប្រភពផ្សេងទៀត សម្រាប់ចំណាយលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈត្រូវគ្នាជាមួយនឹងលក្ខណៈវិនិច្ឆ័យជ្រើសរើសគម្រោង។ គម្រោងទាំងនេះ ចាំបាច់ត្រូវបង្គ្រប់បន្ថែមឲ្យសកម្មភាពរបស់គម្រោងផ្សេងទៀត រួមទាំងការផ្តល់ផលប្រយោជន៍ផ្ទាល់ដល់សមាជិកក្រុម LIG។

11. សកម្មភាពជាក់លាក់ខាងក្រោមនេះ នឹងត្រូវអនុវត្ត ក្នុងឆ្នាំ 2014 ៖

**(a) កំណត់តម្រូវការហេដ្ឋារចនាសម្ព័ន្ធជាអាទិភាព សម្រាប់បញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់(CIPs)**

- ✓ ក្នុងអំឡុងត្រីមាសទី 1 ក្នុងគ្រប់ឃុំ សង្កាត់គោលដៅទាំងអស់ នឹងមានរៀបចំការប្រជុំដើម្បីកំណត់ពីគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ ត្រូវបានជ្រើសរើសជាអាទិភាព។ គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ ត្រូវតែត្រូវបានកំណត់ជ្រើសរើសក្នុងអំឡុងពេលដំណើរការកសាងផែនការឆ្នាំថ្នាក់ឃុំ សង្កាត់ ហើយត្រូវបានដាក់បញ្ចូលក្នុងផែនការវិនិយោគប្រចាំឆ្នាំឃុំ សង្កាត់ សម្រាប់ឃុំ សង្កាត់និមួយៗ។ ការប្រជុំថ្នាក់ឃុំ សង្កាត់ នឹងត្រូវបានសម្របសម្រួលដោយអ្នកសម្របសម្រួលថ្នាក់ក្រុង ស្រុក និង ត្រូវជួយនៅពេលត្រូវការ ដោយសមាជិកក្រុមសម្របសម្រួលថ្នាក់ខេត្ត (PFT)។ ក្រុមប្រឹក្សាឃុំ សង្កាត់ នឹងដាក់ជូនមកក្រុម PFT នូវបញ្ជីចុងក្រោយនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទជាអាទិភាព ដែលបានជ្រើសរើសម្រាប់ការអនុវត្តនៅឆ្នាំ2014។ ចំនួនជាគោលដៅកំណត់សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទថ្មី សម្រាប់ឆ្នាំ 2014 មានយ៉ាងតិចចំនួន 196 ផ្អែកលើការប៉ាន់ស្មាន មួយគម្រោង សម្រាប់មួយឃុំ សង្កាត់។

[7] ត្រូវការការយល់ព្រមជាមុនពី ADB សម្រាប់សកម្មភាព/ចំណាយវិនិយោគ ដូចជាៈ (i) សម្រាប់ម៉ូទ័រ និង ម៉ាស៊ីនបូមទឹកស្រោចស្រព; (ii) បានចាប់ផ្តើមហើយ តែមិនទាន់បញ្ចប់ ដោយសារតែភាពខ្វះចន្លោះផ្នែកគ្រោងរចនា ឬ ផ្នែកសាងសង់; និង (iii) ត្រូវបានគាំទ្រដោយ ADB តាមរយៈគម្រោងផ្សេងទៀត។

### តារាងលេខ 1

### លទ្ធផល 1.1: កែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលគាំទ្រផលិតភាពកសិកម្ម គោលដៅប្រចាំឆ្នាំ តាមខេត្ត

| | ខេត្ត | | | | សរុប |
|---|---|---|---|---|---|
| | បន្ទាយមានជ័យ | សៀមរាប | កំពង់ធំ | កំពង់ចាម | |
| ចំនួនគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ(បន្តអនុវត្តពីឆ្នាំ 2013) | 33 | 30 | 25 | 30 | 118 |
| ចំនួនគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទថ្មី (ឆ្នាំ 2014) | 64 | 116 | 65 | 122 | 367 |

#### (b) រៀបចំគ្រោងការ(គំនូរប្លង់)គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ

✓ ការសិក្សាលទ្ធភាព និង គ្រោងរចនា(ប្លង់)សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ ដោយក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវគាំទ្រដោយមន្ត្រីគាំទ្របច្ចេកទេសថ្នាក់ក្រុង ស្រុក (TSOs) ក៏ដូចជាដោយជំនួយការបច្ចេកទេសឃុំ សង្កាត់ (CTAs) ដែលប្រចាំការតាមក្រុង ស្រុកនិមួយៗផងដែរ។ វិស្វករហេដ្ឋារចនាសម្ព័ន្ធជនបទ (RIEs) ពីក្រុមទីប្រឹក្សាអនុវត្តគម្រោង (PIC) ក៏នឹងផ្តល់ជំនួយបច្ចេកទេស តាមដែលត្រូវការ។ ដើម្បីធ្វើការសិក្សាលទ្ធភាពបាន នឹងត្រូវមានការចុះពិនិត្យជាក់ស្តែងតាមទីតាំងនិមួយៗ ដើម្បីសិក្សាវាស់វែង (សិក្សាប្លង់)ចាំបាច់ និង ប្រមូលទិន្នន័យ តាមរយៈការពិគ្រោះយោបល់ជាមួយអ្នកទទួលផលរបស់គម្រោង។ សម្រាប់ទីតាំងគម្រោងនិមួយៗ នឹងមានតម្រូវការរៀបចំនូវរបាយការណ៍សុវត្ថិភាព ដែលនឹងប៉ាន់ប្រមាណពីផលប៉ះពាល់ផ្នែកបរិស្ថាន និងវិធានការបន្ថយឥទ្ធិពលបម្រែបម្រួលអាកាសធាតុ។ បន្ទាប់ពីបានបញ្ចប់គ្រោងការប្លង់ និងប៉ាន់ស្មានតម្លៃរួច មេឃុំ ចៅសង្កាត់ជាអ្នកទទួលខុសត្រូវក្នុងការអនុម័តគម្រោងដើម្បីទទួលបានការគាំទ្រផ្នែកថវិកាពីមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ (CDF) ហើយបន្ទាប់មក នឹងត្រូវដាក់ជូនទៅក្រុមសម្របសម្រួលថ្នាក់ខេត្ត (PFT) សម្រាប់សុំការបញ្ជាក់បច្ចេកទេស បន្ទាប់ពីការវាយតម្លៃលើគ្រោងការប្លង់ និងតម្លៃប៉ាន់ស្មានរបស់គម្រោង ដោយក្រុម PFT ជាមួយនឹងការជួយគាំទ្រពីបុគ្គលិកផ្សេងទៀត មកពីមន្ទីរជំនាញពាក់ព័ន្ធនានាក្នុងខេត្ត។

#### (c) ពិនិត្យគ្រោងការបច្ចេកទេស ការដេញថ្លៃ និង ចុះកិច្ចសន្យា

✓ បន្ទាប់ពីទទួលបានការបញ្ជាក់បច្ចេកទេស ក្រុមប្រឹក្សាឃុំ សង្កាត់នឹងបន្តការងាររៀបចំឯកសារដេញថ្លៃ និងការប្រកាសពីការដាក់ដេញថ្លៃ ដោយមានជំនួយនៅពេលចាំបាច់ពីក្រុមសម្របសម្រួលខេត្ត និង ក្រុមសម្របសម្រួលក្រុង ស្រុក។ ការប្រកាសជូនដំណឹងស្តីពីការដេញថ្លៃ នឹងត្រូវបិទប្រកាសនៅថ្នាក់ឃុំ សង្កាត់ និង ថ្នាក់ខេត្ត។ លើសពីនេះ ក្រុមសម្របសម្រួលខេត្ត នឹងទទួលខុសត្រូវក្នុងការដាក់ផ្សាយសេចក្តីប្រកាសដាក់ដេញថ្លៃតាមគេហទំព័ររបស់ NCDDS។ អ្នកដេញថ្លៃដែលមានចំណាប់អារម្មណ៍ តម្រូវឲ្យដាក់ពាក្យឯកសារដេញថ្លៃនៅថ្នាក់ឃុំ សង្កាត់ នៅតាមសាលាឃុំ សង្កាត់សាមុី មុនថ្ងៃឈប់ទទួលពាក្យ ដែលបន្ទាប់មក គណៈកម្មការលទ្ធកម្មគម្រោងឃុំ សង្កាត់ (PPC)

នឹងរៀបចំការប្រជុំដេញថ្លៃ ជាពេលដែលឯកសារដេញថ្លៃទាំងអស់សម្រាប់គម្រោងនិមួយៗ ត្រូវបើកកញ្ចប់ វាយតម្លៃ ហើយផ្តល់កិច្ចសន្យាចំពោះអ្នកដេញថ្លៃដែលឈ្នះគេ។

**(d) តាមដាន និងត្រួតពិនិត្យការអនុវត្តការងាររបស់អ្នកម៉ៅការ រៀបចំទូទាត់តាមលទ្ធផលការងារ និង វាយតម្លៃគុណភាពការងារសាងសង់**

✓ សម្រាប់គម្រោងនិមួយៗ នឹងមានគណកម្មការគ្រប់គ្រងគម្រោងឃុំ សង្កាត់ (PMC) ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ គណកម្មការនេះ នឹងទទួលខុសត្រូវក្នុងការពិនិត្យតាមដានជាប្រចាំលើវឌ្ឍនភាពនៃការសាងសង់ ដោយមានជំនួយពីជំនួយការបច្ចេកទេស ដែលគម្រោងបានជ្រើសរើស។ ជំនួយការបច្ចេកទេសឃុំ សង្កាត់ និង មន្ត្រីគាំទ្របច្ចេកទេសនៅថ្នាក់ក្រុង ស្រុក ដោយមានជំនួយពីក្រុមសម្របសម្រួលថ្នាក់ខេត្ត និងនៅពេលចាំបាច់ពីវិស្វករហេដ្ឋារចនាសម្ព័ន្ធជនបទ នឹងចុះពិនិត្យតាមដានជាប្រចាំ តាមទីតាំងសាងសង់ ដើម្បីពិនិត្យមើលគុណភាពសាងសង់។ គណកម្មការគ្រប់គ្រងគម្រោងឃុំ សង្កាត់ នឹងផ្តល់អនុសាសន៍ដល់មេឃុំ ចៅសង្កាត់ ដើម្បីរៀបចំការទូទាត់កិច្ចសន្យា ទៅឲ្យអ្នកទទួលការ ផ្អែកលើវឌ្ឍនភាពនៃការសាងសង់។

### C.3.2 ការពង្រឹងសមត្ថភាពកសិករខ្នាតតូច

12. គម្រោងនឹងកែលម្អសមត្ថភាពផលិតកម្មរបស់កសិករខ្នាតតូច ដោយរៀបចំចងក្រងជាក្រុមកែលម្អជីវភាព (LIGs) តាមភូមិគោលដៅ និង ដោយសម្របសម្រួលការរៀបចំបង្កើតទុនបង្វិលក្រុម (GRFs) និង/ឬ ភ្ជាប់ទំនាក់ទំនងក្រុមជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ និង ដោយការផ្តល់ការបណ្តុះបណ្តាល និង សេវាកម្មផ្សព្វផ្សាយ។ អ្នកទទួលផល ដែលជាសមាជិកក្រុម LIGs ត្រូវបានកំណត់ជ្រើសរើសយក ដោយផ្អែកលើចំណាត់ថ្នាក់ទ្រព្យធនរបស់គ្រួសារ ហើយមិនមែនផ្អែកលើទំហំដីរបស់គេឡើយ។ សមាជិកក្រុម តម្រូវឲ្យចូលរួមបដិភាគជាថវិកា សម្រាប់ជាទុនសន្សំ ចូលក្នុងទុនបង្វិលរបស់ក្រុម។ គម្រោងនឹងជ្រើសរើសអ្នកផ្តល់សេវជំនាញបន្ថែម សម្រាប់ (i) ផ្តល់ការគាំទ្រកសាងសមត្ថភាព និងណែនាំផ្ទាល់ ដល់ក្រុម LIG ដើម្បីឲ្យគាត់អាចពង្រឹងសមត្ថភាពក្រុមរបស់គាត់ និង ដើម្បីរៀបចំផែនការធុរកិច្ច (ផែនការអាជីវកម្ម) សម្រាប់សកម្មភាពកែលម្អជីវភាពបានស្នើឡើង (អ្នកផ្តល់សេវាជំនាញ SSP2); (ii) គាំទ្រកម្មវិធីចាក់ថ្នាំបង្ការជម្ងឺសត្វ របស់សមាជិកក្រុម LIG; និង (iii) ផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសដល់ក្រុម LIGs និមួយៗ ដើម្បីឲ្យពួកគាត់អាចអនុវត្តសកម្មភាពកែលម្អជីវភាពរបស់គាត់បាន។ ការវិភាគប្រព័ន្ធកៀសត្រ-បរិស្ថាន (AEA) នឹងត្រូវធ្វើបញ្ចប់ សម្រាប់ឃុំ សង្កាត់នៅសល់ទាំងអស់។

13. សកម្មភាពជាក់លាក់ខាងក្រោមនេះ នឹងត្រូវអនុវត្ត ក្នុងឆ្នាំ 2014 ៖

**(a) ការចងក្រងក្រុមកែលម្អជីវភាព (LIGs)**

✓ ដោយអនុវត្តតាមគោលការណ៍ណែនាំសម្រាប់ការរៀបចំចងក្រងក្រុម LIGs ក្នុងខេត្តនិមួយៗ នឹងមានរៀបចំចងក្រងក្រុម LIGs បន្ថែម ក្នុងភូមិគោលដៅនិមួយៗ ដោយផ្តោតតាមលទ្ធភាពអាចធ្វើទៅកើត លើគ្រួសារក្រីក្រកម្រិត-2 ដែលមានសមាជិកច្រើនបំផុតចំនួន 25 ក្នុងមួយក្រុម។ អ្នកផ្តល់សេវាជំនាញ SSP1 ដែលបានជ្រើសរើសដោយ NCDDS ក្នុងឆ្នាំ 2013 នឹងបន្តពិនិត្យតាមដាននិតិវិធី ដែលបានប្រើ/អនុវត្តតាម ក្នុងការរៀបចំចងក្រងក្រុម LIGs ក្នុងខេត្តនិមួយៗ ហើយផ្តល់អនុសាសន៍សម្រាប់រៀបចំចងក្រងឡើងវិញ សម្រាប់ក្រុមណាដែលចាំបាច់។ NCDDS

នឹងរៀបចំកែសម្រួលគោលការណ៍ណែនាំចងក្រងក្រុម LIG ដើម្បីដោះស្រាយបញ្ហាមិនមានចំនួនគ្រួសារក្រីក្រកម្រិត-2 ដោយអនុញ្ញាតិឲ្យមានលក្ខណៈវិនិច្ឆ័យជ្រើសរើសសមាជិកភាព LIG ខុសៗគ្នាមួយចំនួន។

### (b) ការវិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន

✓ ក្នុងឃុំ សង្កាត់នៅសល់ចំនួន 92 នឹងមានធ្វើការវិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន (AEA) ដែលនឹងជួយសម្របសម្រួលដោយមន្ទីរកសិកម្មខេត្ត (PDA) ជាមួយនឹងការគាំទ្រពីក្រុមគាំទ្រក្រុង ស្រុក (DST) និង ដោយមានជំនួយពីទីប្រឹក្សាផ្សព្វផ្សាយកសិកម្មខេត្ត (PAEA) និងអ្នកសម្របសម្រួលកសិកម្មខេត្ត (PAC)។[8] បន្ទាប់ពីបានបញ្ចប់ការប្រមូលទិន្នន័យពីតាមភូមិរួចមក នឹងមានការប្រជុំតាមឃុំ សង្កាត់សាមីនិមួយៗ ដើម្បីធ្វើសុពលភាពលទ្ធផលរកឃើញក្នុងការវិភាគ AEA ហើយបន្ទាប់មក របាយការណ៍វិភាគ នឹងត្រូវបានប្រមូលផ្តុំសំយោគដោយ PDA ដោយមានជំនួយពីទីប្រឹក្សា PAEA ។ នៅពេលដែលរបាយការណ៍វិភាគនេះ បានរៀបចំចប់ នឹងមានការប្រជុំតាមឃុំ សង្កាត់សាមីនិមួយៗ ដើម្បីបង្ហាញពីលទ្ធផលនៃការវិភាគ AEA។ របាយការណ៍វិភាគ AEA ច្បាប់ចុងក្រោយ នឹងត្រូវផ្ញើរមកថ្នាក់ជាតិសម្រាប់រក្សាទុកជាឯកសារ (ក្នុងប្រព័ន្ធទិន្នន័យ ដាតេបេស) ដែលគ្រប់គ្រងដោយ ជនបង្គោលទទួលបន្ទុកផ្នែកផ្សព្វផ្សាយរបស់គម្រោង។

### (c) កំណត់ និងគ្រោងការគម្រោងកែលម្អជីវភាព សម្រាប់ក្រុមកែលម្អជីវភាព (LIGs)

✓ ការកំណត់យកគម្រោងកែលម្អជីវភាព គួរតែផ្អែក តាមលទ្ធភាពទៅរួច លើផែនការវិនិយោគឃុំ សង្កាត់ (CIPs) គឺដូចគ្នានឹងករណីគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទដែរ, ដើម្បីផ្តល់ការណែនាំតម្រង់ទិសសម្រាប់ការជ្រើសរើសយកអន្តរាគមន៍(សកម្មភាព)កែលម្អជីវភាពសមស្រប សម្រាប់ក្រុម LIG និមួយៗ។[9] ក្នុងក្រុម LIG និមួយៗ នឹងមានក្រុមមានចំណាប់អារម្មណ៍ដូចគ្នា (CIGs) ត្រូវបានបង្កើតឡើង ដោយមានសមាជិកពីគ្រួសារដែលមានបំណងចង់ធ្វើវិនិយោគក្នុងសកម្មភាពកែលម្អជីវភាពជាក់លាក់ណាមួយដូចគ្នា។ អ្នកផ្តល់សេវាជំនាញ SSP2 នឹងជួយអ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ ដើម្បីតម្រង់ទិសសមាជិកក្រុម LIGក្នុងការកំណត់រកអាទិភាពសកម្មភាពកែលម្អជីវភាព និង ក្នុងការរៀបចំផែនការអាជីវកម្ម សម្រាប់ក្រុម ដោយកំណត់នូវកម្រិតគាំទ្រវិនិយោគដែលត្រូវការចាំបាច់។ អ្នកផ្តល់សេវាជំនាញ SSP2 ក៏នឹងផ្តល់ជំនួយផងដែរ ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកំណត់រកសេវាករ/គ្រូបណ្តុះបណ្តាល សម្រាប់ផ្តល់សេវាបណ្តុះបណ្តាលគាំទ្រសកម្មភាពកែលម្អជីវភាពដែលបានកំណត់ដោយក្រុម CIG។ ក្រុមគាំទ្រក្រុង ស្រុក (DSTs) នឹងផ្តល់ឱវាទផ្នែកបច្ចេកទេសស្តីពីសំណើរបច្ចេកទេសរបស់អ្នកដេញថ្លៃ ហើយក៏នឹងពិនិត្យតាមដានជាប្រចាំលើគុណភាពបច្ចេកទេសនៃការផ្តល់សេវាបណ្តុះបណ្តាលកែលម្អជីវភាព។ ផែនការអាជីវកម្មរបស់ក្រុមLIG នឹងត្រូវដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីសុំសេចក្តីសម្រេច ហើយដែលផែនការនេះ ក៏នឹងត្រូវពិនិត្យមើលដោយសមាជិកក្រុម DST។ បន្ទាប់ពីផែនការនេះ ទទួលបានការយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ ថវិកា

[8] មន្ទីរកសិកម្មខេត្ត នឹងត្រូវបានផ្តល់កិច្ចសន្យាដោយក្រសួងកសិកម្ម ដើម្បីធ្វើការវិភាគកៀ្សត្រ-បរិស្ថាន (AEA) ផ្អែកលើបញ្ចប់ថវិកាសរុបបានព្រមព្រៀងគ្នា សម្រាប់ការវិភាគ AEA និមួយៗ។

[9] សកម្មភាពកែលម្អជីវភាព(ចិញ្ចឹមជីវិត) ដែលត្រូវបានជ្រើសរើសដោយក្រុម LIGs ដែលមិនទាន់បានបញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ (CIP) ឆ្នាំ 2014 អាចបញ្ចូលបាន ដោយក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយការធ្វើវិសោធនកម្មលើ CIP ។

ផ្នែក(វគ្គ)ទីមួយ (វិភាជន៍សម្រាប់សមាជិកក្រុម CIG សាមីនេះ) នឹងត្រូវផ្ទេរចូលគណនីរបស់ក្រុម LIG សម្រាប់ជាទុនបង្វិលរបស់ក្រុម(GRF)។ គណនីរបស់ក្រុម LIG នឹងត្រូវរៀបចំបើក ដោយមានជំនួយពីសេវាករជំនាញ SSP2។

#### (d) ការអនុវត្តគម្រោងកែលម្អជីវភាព

✓ ក្រុម LIG និមួយៗ នឹងអនុវត្តតាមនិតិវិធី មានចែងក្នុងគោលការណ៍នាំសម្រាប់ការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ (CDF) សម្រាប់គាំទ្រសកម្មភាពកែលម្អជីវភាព។ ថវិកាដែលបានផ្ទេរឲ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់ ចូលក្នុងគណនីទុនបង្វិលរបស់ក្រុម LIG នឹងត្រូវដកប្រើដោយសមាជិកគណកម្មការដឹកនាំក្រុម LIG ដែលបានផ្តល់សិទ្ធឲ្យ និង ផ្តល់ឲ្យសមាជិកក្រុម LIG ដើម្បីឲ្យគាត់អាចទិញសម្ភារៈត្រូវការសម្រាប់សកម្មភាពកែលម្អជីវភាពជាក់លាក់របស់គាត់។ សមាជិកក្រុម LIG នឹងទិញសម្ភារៈត្រូវការរបស់គាត់ ដោយខ្លួនគាត់ផ្ទាល់។ ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានជំនួយពីសមាជិកក្រុមគាំទ្រក្រុង ស្រុក (DST) នឹងជួយកំណត់ និងជ្រើសរើសសេវាករ/គ្រូបណ្តុះបណ្តាល ដែលនឹងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស ដល់សមាជិកក្រុម CIG ទៅតាមប្រធានបទដែលគាត់បានជ្រើសរើសសម្រាប់សកម្មភាពកែលម្អជីវភាពរបស់គាត់ ក៏ដូចជាជួយក្នុងការរៀបចំការធ្វើបង្ហាញបច្ចេកទេសខ្នាតតូចក្នុងភូមិដែលត្រូវការសម្រាប់គាំទ្រការបណ្តុះបណ្តាល។ អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ និង ជំនួយការរដ្ឋបាលឃុំ សង្កាត់ នឹងចូលរួមយ៉ាងសកម្មជាមួយអ្នកផ្តល់សេវាជំនាញ SSP2 ក្នុងការផ្តល់កិច្ចសម្របសម្រួល និងជំនួយថ្នាក់មូលដ្ឋានដល់ក្រុមLIGs និងពិនិត្យតាមដានលើការអនុវត្តសកម្មភាពកែលម្អជីវភាពរបស់សមាជិកក្រុមCIGs។ ការចំណាយទូទាត់ដល់សេវាករ/គ្រូបណ្តុះបណ្តាល សម្រាប់សេវាកម្មបានផ្តល់របស់ពួកគេ នឹងត្រូវធ្វើតាមរយៈការផ្ទេរផ្ទាល់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ពីគណនីមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់(CDF)។

**តារាងលេខ 2**

**លទ្ធផល 1.2: គម្រោងកែលម្អជីវភាព**

**គោលដៅប្រចាំឆ្នាំ តាមខេត្ត**

| | ខេត្ត | | | | សរុប |
|---|---|---|---|---|---|
| | បន្ទាយមានជ័យ | សៀមរាប | កំពង់ធំ | កំពង់ចាម | |
| ចំនួនគម្រោងកែលម្អជីវភាព | 468 | 1.048 | 720 | 1.120 | 3.356 |

#### (e) គាំទ្រដល់កម្មវិធីចាក់ថ្នាំបង្ការជម្ងឺសត្វ សម្រាប់ឃុំ សង្កាត់គោលដៅ

✓ អ្នកផ្តល់សេវាជំនាញ SSP3 ដែលបានជ្រើសរើសដោយ NCDDS នឹងគាំទ្រយុទ្ធនាការចាក់ថ្នាំបង្ការជម្ងឺសត្វគោ ក្របី ជ្រូក និងមាន់ ដែលជាកម្មសិទ្ធិរបស់សមាជិកក្រុម LIG។ សេវាករ SSP3 នឹងរៀបចំការប្រជុំក្នុងឃុំ សង្កាត់គោលដៅនិមួយៗ ដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីយុទ្ធនាការចាក់ថ្នាំបង្ការជម្ងឺសត្វ និង ដើម្បីប្រមូលព័ត៌មានពីចំនួនសត្វតាមភូមិគោលដៅទាំងអស់។ ក្នុងខេត្តនិមួយៗ សេវាករ SSP3 នឹងរៀបចំសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់ភ្នាក់ងារសុខភាពសត្វភូមិទាំងអស់ ពីឃុំ សង្កាត់គោលដៅ ហើយផ្តល់ឲ្យពួកគេម្នាក់ៗនូវ ឃីត (កញ្ចប់សម្ភារៈ)

បសុសត្វ មួយម្នាក់ៗ។ សមាជិកក្រុមគាំទ្រថ្នាក់ក្រុង ស្រុក (DST) និង អ្នកសម្របសម្រួលកសិកម្មខេត្ត (PAC) នឹងចុះពិនិត្យតាមដានវឌ្ឍនភាពកម្មវិធីចាក់ថ្នាំបង្ការជម្ងឺសត្វនេះ តាមឃុំ សង្កាត់គោលដៅនិមួយៗ។

### C.3.3 ការពង្រឹងសមត្ថភាពឃុំ សង្កាត់ក្នុងការគ្រប់គ្រងគម្រោង

14. ក្នុងឃុំ សង្កាត់គោលដៅនិមួយៗ នឹងមានកម្មវិធីបន្តកសាងសមត្ថភាពសម្រាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និង បុគ្គលិកគាំទ្រឃុំ សង្កាត់ ដូចជា ស្មៀនឃុំ សង្កាត់/អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់/ជំនួយការរដ្ឋបាលឃុំ សង្កាត់។

#### (a) ការកំណត់តម្រូវការបណ្តុះបណ្តាលរបស់បុគ្គលិកឃុំ សង្កាត់ និង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

- ✓ ការប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល ត្រូវបានធ្វើចប់សព្វគ្រប់សម្រាប់ឃុំ សង្កាត់ដំណាក់កាលចុងក្រោយទាំង 92 ឃុំ សង្កាត់ ដើម្បីផ្តល់ព័ត៌មានសម្រាប់តម្រង់ទិសការរៀបចំចងក្រងកម្មវិធីបណ្តុះបណ្តាលសម្រាប់បុគ្គលិកឃុំ សង្កាត់ និង អ្នកផ្សព្វផ្សាយឃុំ សង្កាត់/ជំនួយការរដ្ឋបាលឃុំ សង្កាត់។

### C.2.4 បណ្តុះបណ្តាលកសាងសមត្ថភាពសម្រាប់បុគ្គលិកឃុំ សង្កាត់ និង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

- ✓ លេខាធិការដ្ឋាន គ.ជ.អ.ប (NCDDS) និង ក្រុមទីប្រឹក្សាអនុវត្តគម្រោង (PIC) នឹងគាំទ្រក្រុមសម្របសម្រួលខេត្តក្នុងខេត្តនិមួយៗ ក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាព ដែលត្រូវបានរៀបចំឡើងផ្អែកលើលទ្ធផលវិភាគប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល (TNAs) ដែលបានរៀបចំបញ្ចប់ រួចហើយ។ កម្មវិធីបណ្តុះបណ្តាលដែលគ្រោងសម្រាប់អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ រួមមានប្រធានបទស្តីពី វិធីសាស្ត្រផ្សព្វផ្សាយ ការប្រាស្រ័យទាក់ទង ការសម្របសម្រួល និង បច្ចេកវិទ្យាផលិតកម្មកសិកម្មគន្លឹះៗមួយចំនួន (ផលិតកម្មស្រូវ បន្លែ និង ការចិញ្ចឹមសត្វ)។ គម្រោងក៏គ្រោងផ្តល់ការបណ្តុះបណ្តាលផងដែរសម្រាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់/ជំនួយការរដ្ឋបាលឃុំ សង្កាត់/អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ទាំងអស់ លើប្រធានបទស្តីពីគោលការណ៍ណែនាំពី ការប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ សម្រាប់សកម្មភាពកែលម្អជីវភាព ឯកសារណែនាំការអនុវត្តគម្រោង (ភីម) ការគ្រប់គ្រងហិរញ្ញវត្ថុ ការត្រួតពិនិត្យគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ ការបង្កើនការយល់ដឹងពីយេនឌ័រ ការធ្វើចំណាត់ថ្នាក់ទ្រព្យធនគ្រួសារតាមភូមិ និង ពីបំនិន/ជំនាញកម្រិតមូលដ្ឋានក្នុងការប្រើប្រាស់កុំព្យូទ័រ។

## C.4 <u>សមាសភាគទី</u> 2: ការកែលម្អផលិតភាពកសិកម្ម (MAFF/GDA)

### C.4.1 កែលម្អបរិយាកាសគោលនយោបាយកសិកម្ម

15. ការគាំទ្រសម្រាប់ការសិក្សាអនុវត្តសាកល្បង GAP នឹងបន្តធ្វើនៅខេត្តសៀមរាប ដោយពង្រីកវិសាលភាពបន្ថែម ទៅស្រុកថ្មី តាមរយៈការកំណត់/ចងក្រងក្រុមកសិករផលិតថ្មីថែមទៀត។ ការផ្សព្វផ្សាយពីផលិតផលមានបញ្ជាក់លក្ខណៈផលិតបែបការអនុវត្តកសិកម្មល្អ (GAP) នឹងត្រូវធ្វើក្នុងក្រុងសៀមរាប ដើម្បីធានាថា មានទីផ្សារចិតថេរសម្រាប់ផលិតផល GAP។ ដំណើរការបញ្ជាក់ផលិតផលផលិតតាមលក្ខណៈ GAP ក៏នឹងត្រូវពង្រីកបន្ថែមក្នុងខេត្តកំពង់ចាម ដោយអនុវត្តតាមមេរៀនដកពិសោធន៍ទទួលបានជោគជ័យពីការងារចាប់ផ្តើមក្នុងខេត្តសៀមរាប។ ក្នុងខេត្តកំពង់ធំ ទស្សនទានស្តីពីផលិតកម្មតាមកិច្ច

សន្យា (CF) ក៏នឹងត្រូវណែនាំបញ្ចូលអនុវត្តក្នុងកម្មវិធីផលិតស្រូវពូជ។ គម្រោងក៏នឹងផ្តល់ការគាំទ្រផងដែរដល់ អគ្គនាយដ្ឋានកសិកម្ម MAFF/GDA សម្រាប់ការរៀបចំទស្សនវិស័យផលិតកម្មដំណាំនៅកម្ពុជា នៅឆ្នាំ 2030។

16. សកម្មភាពចំបងៗ មានដូចជា៖

(a) **កំណត់វិសាលភាពនៃការងារផ្នែកគោលនយោបាយកសិកម្ម ដោយសិក្សាពិនិត្យមើលឯកសារគោលនយោបាយមានស្រាប់**

- ✓ បណ្តាញការងារគោលនយោបាយកសិកម្ម ដែលបានបង្កើតឡើងក្នុងឆ្នាំ 2013 ដែលមានសមាជិកជាតំណាងអ្នកផ្តល់ជំនួយនានា នឹងបន្តការជួបប្រជុំរបស់ខ្លួន ដើម្បីពិភាក្សាពីប្រធានបទទាក់ទងនឹងគ្រាប់ពូជស្រូវសុទ្ធ។ សមាជិកក្រុមទីប្រឹក្សា PIC នឹងបន្តចូលរួមក្នុងការប្រជុំនេះ។

**C.4.2 រៀបចំបង្កើតឯកសារ/គោលការណ៍ណែនាំប្រតិបត្តិការ និង គ្រោងរចនាសម្រាប់ធ្វើតេស្តសាកល្បងគោលនយោបាយកសិកម្មមួយចំនួន**

- ✓ ក្រៅពីទស្សនកិច្ចសិក្សាស្តីពីការអនុវត្តកសិកម្មល្អ (GAP) នឹងមានការគាំទ្រជាបន្តស្តីពីការអនុវត្តសាកល្បងជាក់ស្តែងពីទស្សនទានផលិតកម្មតាមកិច្ចសន្យា (CF) ដែលសមស្របសម្រាប់កម្មវិធីផលិតកម្មពូជស្រូវសុទ្ធ ដែលកំពុងបានគាំទ្រដោយគម្រោង។ ឯកសារប្រតិបត្តិការ (ដូចជា គោលការណ៍ណែនាំអនុវត្តស្តីពីផលិតកម្មតាមកិច្ចសន្យា) នឹងត្រូវបានរៀបចំ ផ្អែកលើឯកសារច្បាប់មានស្រាប់ស្តីពីផលិតកម្មតាមកិច្ចសន្យា ហើយនឹងការគាំទ្រសម្រាប់ការសម្របសម្រួលទំនាក់ទំនងរវាងកសិករផលិតស្រូវពូជសុទ្ធនិងស្រូវចំណី ជាមួយរោងម៉ាស៊ីនស្រូវ។

**(a) រៀបចំសិក្ខាសាលាពិគ្រោះយោបល់ដើម្បីបញ្ចូលគំនិត/យោបល់ពីក្រសួងពាក់ព័ន្ធ និងអ្នកពាក់ ព័ន្ធនានា ដើម្បីកែសម្រួលសម្រេចឯកសារគោលការណ៍ណែនាំប្រតិបត្តិការនានា**

- ✓ គម្រោងនឹងរៀបចំសិក្ខាសាលាមួយចំនួនដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីគោលនយោបាយទាក់ទងវិស័យកសិកម្ម ដូចជា ការសម្របនឹងបម្រែបម្រួលអាកាសធាតុក្នុងវិស័យកសិកម្ម ច្បាប់ពូជដំណាំ គោលនយោបាយនាំអង្ករចេញ និងការផ្សព្វផ្សាយពូជស្រូវពេញនិយម។ គោលនយោបាយនាំអង្ករចេញ។ សកម្មភាពនេះ ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបនឹងបញ្ហាកំណត់រកឃើញកង្វះព័ត៌មាននៅថ្នាក់ក្រោមជាតិស្តីពីគោលនយោបាយកសិកម្មដែលមានស្រាប់។ សិក្ខាសាលាទាំងនេះ នឹងត្រូវរៀបចំដោយក្រុមអនុវត្តគម្រោងមកពីអគ្គនាយកដ្ឋានកសិកម្ម សហការជាមួយមន្ទីរកសិកម្មក្នុងខេត្តគោលដៅនិមួយៗ។

(b) **ធ្វើការសាកល្បងការអនុវត្តកសិកម្មល្អ**

- ✓ នៅក្នុងអគ្គនាយកដ្ឋានកសិកម្ម នឹងមានក្រុមការងារបង្កើតឡើងសម្រាប់ការអនុវត្តសាកល្បងនូវការអនុវត្តកសិកម្មល្អ GAP (ក្រោមគម្រោង TSSD), ដែលនឹងរួមបញ្ចូលសមាជិកម្នាក់ពីក្រុមទីប្រឹក្សាអនុវត្តគម្រោង (PIC) ផង។ ក្រុមការងារនេះ នឹងផ្តល់កិច្ចសម្របសម្រួលជាបន្តសម្រាប់ការសិក្សាអនុវត្តសាកល្បងនេះ ដែលមានសរុប 11 ក្រុមកសិករផលិតបន្លែ និងផ្លែឈើ ក្នុងខេត្តសៀមរាប និង បួនក្រុមថ្មី ក្នុងខេត្តកំពង់ចាម។ ការអង្កេតពីចំណងទាក់ទងទីផ្សារ និងការយល់ដឹងរបស់អ្នកប្រើប្រាស់ក្នុងក្រុងសៀមរាប (រំកិលពីឆ្នាំ 2013 មក) នឹងត្រូវធ្វើឲ្យចប់ក្នុងត្រីមាសទី

មួយ ដើម្បីតម្រង់ទិសការអនុវត្តសកម្មភាពផ្សព្វផ្សាយលើកកំពស់ការយល់ដឹងរបស់ប្រជាជន តាមរយៈបណ្តាញផ្សព្វផ្សាយព័ត៌មានក្នុងមូលដ្ឋាន(ខេត្ត)។ សិក្ខាសាលាមួយនឹងត្រូវបានរៀបចំ ក្នុងខេត្តសៀមរាប ដើម្បីបង្ហាញពីលទ្ធផលនៃការអង្កេតនេះ និង ដើម្បីទទួលបាននូវចំលើយតបពីអ្នកពាក់ព័ន្ធនានាក្នុងមូលដ្ឋាន។ទីប្រឹក្សាអន្តរជាតិផ្នែក GAP នឹងមកបន្តការងារចំនួនពីរលើកទៀតក្នុងមករា ដើម្បីផ្តល់ការបណ្តុះបណ្តាលពីសវនកម្ម និងក្នុងត្រីមាសទី 2 ដើម្បីពិនិត្យតាមដានវឌ្ឍនភាពសរុប ដែលសម្រេចបាន។ ដើម្បីទទួលបានបទពិសោធន៍ថែមទៀតស្តីពីការប្រើប្រាស់ GAP ក្នុងប្រទេសផ្សេងទៀត គម្រោងនឹងរៀបចំទស្សនកិច្ចសិក្សាមួយក្នុងត្រីមាសទី 3 ទៅប្រទេសម៉ាឡេស៊ី ឬ ប្រទេសហ្វីលីពីន សម្រាប់សមាជិកក្រុមការងារ GAP និងបុគ្គលិកពាក់ព័ន្ធមកពីមន្ទីរកសិកម្មខេត្តសៀមរាប។[10] នៅចុងបញ្ចប់នៃទស្សនកិច្ចសិក្សានេះ នឹងមានសិក្ខាសាលារយៈពេលមួយថ្ងៃ ត្រូវបានរៀបចំឡើង ដើម្បីកត់ត្រាមេរៀនដកពិសោធន៍ពីទស្សនកិច្ចនេះ ហើយដែលសិក្ខាសាលានេះ នឹងអាចចូលរួមដោយប្រធានមន្ទីរកសិកម្មខេត្តគោលដៅទាំងបួន។ នៅពាក់កណ្តាលឆ្នាំ នឹងមានសិក្ខាសាលាឆ្លុះបញ្ចាំងមួយ រៀបចំឡើងដើម្បីពិនិត្យមើលពីវឌ្ឍនភាពទទួលបានពីការសិក្សាអនុវត្តសាកល្បងផ្ទាល់លើ GAP នេះ និងដើម្បីចែករំលែកបទពិសោធន៍បឋម ជាមួយខេត្តផ្សេងទៀត។ លទ្ធផល/បទពិសោធន៍ប្រមូលបានពីការអនុវត្តសាកល្បងនេះ នឹងត្រូវបានប្រើសម្រាប់ផ្តល់ព័ត៌មានដល់ GDA ស្តីពីការរៀបចំគោលនយោបាយស្តីពី GAP និងសម្រាប់កែលម្អឯកសារផ្សព្វផ្សាយមានស្រាប់របស់អគ្គនាយកដ្ឋានកសិកម្ម GDA ស្តីពី GAP។

### (c) បោះពុម្ពឯកសារមេរៀនស្តីពី GAP និង គោលនយោបាយ ឬ គោលការណ៍ណែនាំមួយចំនួន

- ✓ ការបោះពុម្ព និងចែកចាយគោលការណ៍ណែនាំមានស្រាប់ស្តីពីគោលនយោបាយ និង ច្បាប់នានា ដែលពាក់ព័ន្ធនឹងផលិតកម្មកសិករខ្នាតតូច នឹងត្រូវធ្វើក្នុងអំឡុងឆ្នាំ 2014 នេះ។ ការនេះរួមទាំងការបញ្ចេញ/ផ្សព្វផ្សាយនូវច្បាប់ចុងក្រោយនៃសៀវភៅណែនាំស្តីពី GAP។

### (d) ជួយអគ្គនាយកដ្ឋានកសិកម្ម រៀបចំទស្សនវិស័យផលិតកម្មដំណាំកម្ពុជាសម្រាប់ឆ្នាំ 2030

- ✓ បន្តពីការរៀបចំសេចក្តីគោលព្រាងស្តីពីទស្សនវិស័យផលិតកម្មដំណាំកម្ពុជា នៅឆ្នាំ 2030 អគ្គនាយកដ្ឋានកសិកម្មនឹងរៀបចំសិក្ខាសាលាសម្រាប់ក្រុមបង្គោលការងារគោលនយោបាយរបស់ក្រសួងកសិកម្ម ក្នុងត្រីមាសទី 1 ដើម្បីពិនិត្យមើលពីខ្លឹមសារនៃឯកសារសេចក្តីគោល និងពិភាក្សាពីយុទ្ធសាស្រ្តប្រមូលព័ត៌មានត្រូវការ។ ទស្សនវិស័យនេះនឹងផ្តោតជាពិសេសលើតួនាទីរបស់ផលិតកម្មកសិករខ្នាតតូច នឹងត្រូវដើរតួក្នុងផែនការផលិតកម្ម និងកម្មវិធីគាំទ្រ នាពេលអនាគត ។ សិក្ខាសាលាដំបូងនេះ នឹងផ្តល់នូវមូលដ្ឋានសម្រាប់ការរៀបចំលក្ខខ័ណ្ឌយោងការងារសម្រាប់ទីប្រឹក្សា (អន្តរជាតិម្នាក់ និង ជាតិម្នាក់) ដែលនឹងត្រូវជ្រើសរើសដោយអង្គភាពសម្របសម្រួលការអភិវឌ្ឍរបស់ក្រសួងកសិកម្ម (MAFF/DCU) សម្រាប់គាំទ្រដល់ការបង្កើតក្រុមការងារក្នុង MAFF/GDA និង ការរៀបចំឯកសារទស្សនវិស័យនេះ។ ឯកសារព្រាងនេះ នឹងត្រូវបង្ហាញនៅឯសិក្ខាសាលាពិគ្រោះយោបល់ រៀបចំនៅថ្នាក់ជាតិ។ ចំលើយតប

[10] ឯកសារទស្សនភាពលម្អិតពីទិសដៅ និងលទ្ធផលរំពឹងទុក ស្ថាប័នម្ចាស់ផ្ទះរៀបចំទទួល បញ្ជីអ្នកចូលរួម រួមទាំងស្រ្តីផង និង ថវិកាលម្អិត និងខ្ទង់ថវិកាត្រូវចំណាយ នឹងត្រូវរៀបចំដោយ GDA ផ្ញើមក ADB ដើម្បីសុំការយល់ព្រម មុននឹងចាប់ផ្តើមរៀបចំទស្សនកិច្ច។

ទទួលបានពីសិក្ខាសាលានេះ នឹងជួយក្រុមការងារ GDA ឲ្យអាចកែសម្រួលបន្ថែមលើសេចក្តីព្រាងឯកសារទស្សនវិស័យ និងឲ្យអនុលោមភាពបញ្ជូនទៅ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)។

## C.4.3 បង្កើនការផលិតផ្គត់ផ្គង់ និង លទ្ធភាពអាចរកបាននូវគ្រាប់ពូជដំណាំមានគុណភាព

17. ផ្អែកលើបទពិសោធន៍ទទួលបានក្នុងឆ្នាំ 2013 គម្រោងនឹងពង្រីកវិសាលភាពកម្មវិធីគាំទ្រក្រុមកសិករផលិតស្រូវពូជក្នុងខេត្តគោលដៅនិមួយៗ។ ដើម្បីធានាថា មានគ្រាប់ពូជសុទ្ធអនុញ្ញាតិគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់ក្រុមកសិករផលិតស្រូវពូជ ការស្តារ/សាងសង់ស្ថានីយ៍ស្រាវជ្រាវទាំងពីរ នឹងដំណើរការទៅ (សកម្មភាពនេះ ត្រូវបានលើករំកិលពីឆ្នាំ 2013)។ នឹងមានការបណ្តុះបណ្តាលកសាងសមត្ថភាពយ៉ាងច្រើន ផ្តល់ឲ្យដល់ក្រុមកសិករផលិតស្រូវពូជ ដើម្បីធានាថាពួកគាត់អាចក្លាយជាអ្នកផលិតគ្រាប់ពូជលក់បានជោគជ័យ ដោយមានចំណងទាក់ទងរឹងមាំជាមួយរោងម៉ាស៊ីនស្រូវ ដើម្បីធានាថាគ្រាប់ពូជស្រូវដែលគាត់ផលិត ជាពូជមានតម្រូវការ ហើយអាចរកបានដោយកសិករផលិតស្រូវចំណី។ ការចាត់ចែងផលិតកម្មតាមកិច្ចសន្យា រវាងក្រុមកសិករផលិតស្រូវពូជ ជាមួយនិងរោងម៉ាស៊ីនស្រូវ ក៏នឹងត្រូវបានសិក្សាពិនិត្យ ដើម្បីសាកល្បង។ នឹងមានការពង្រីកវិសាលភាពនៃកម្មវិធីធ្វើបង្ហាញបច្ចេកទេសក ដោយបញ្ចូលបច្ចេកវិទ្យាកសិកម្មផ្សេងទៀត ក្រៅពីស្រូវ។

18. សកម្មភាពចំបងៗ មានដូចជា៖

### (a) កំណត់រកក្រុមកសិករសម្រាប់ផលិតកម្មពូជ

- ✓ ការប៉ាន់ប្រមាណពីសមត្ថភាពត្រូវការបន្ថែមទៀត នឹងត្រូវធ្វើសម្រាប់គ្រប់ក្រុមកសិករផលិតស្រូវពូជថ្មីទាំងអស់ ដែលកំណត់រកក្នុងខេត្តនិមួយៗ។ ជាគោលបំណងនោះ គឺ ឲ្យមានក្រុមកសិករផលិតស្រូវពូជមួយ ក្នុងមួយក្រុង ស្រុកគោលដៅ ប៉ុន្តែអាចមានក្រុង ស្រុកមួយចំនួន មានពីរក្រុម។ ជាសរុប គម្រោងនឹងរៀបចំបង្កើត និងជួយគាំទ្រ ក្រុមកសិករផលិតពូជស្រូវសរុបបូកយោងចំនួន 31 នៅដំណាច់ឆ្នាំ 2014 នេះ។

### (b) បង្កើតភាពជាដៃគូជាមួយស្ថានីយ៍ស្រាវជ្រាវពាក់ព័ន្ធ សម្រាប់ផលិតកម្ម និងចែកចាយពូជដំណាំ

- ✓ ការស្តារសាងសង់ស្ថានីយ៍ស្រាវជ្រាវទាំងពីរក្នុងខេត្តសៀមរាប(ស្ថានីយ៍ទឹករិល) និងក្នុងខេត្តកំពង់ធំ (ស្ថានីយ៍បល្ល័ង្គ) ត្រូវបានពន្យារពេល ដោយសារតែបរាជ័យក្នុងនិតិវិធីដេញថ្លៃ។ បន្ទាប់ពីបានចុះកិច្ចសន្យា ការងារសាងសង់ ដែលរួមមាន ការសាងសង់ឃ្លាំង និងការស្តារប្រព័ន្ធស្រោចស្រពផង នឹងត្រូវចាប់ផ្តើម។ នឹងមានការកែលម្អគ្រោងរចនា (ប្លង់) ស្រែ និង ការកៀរពង្រាបដីស្រែដោយប្រព័ន្ធឡាហ្សែរ (3 ហិចតា / ស្ថានីយ៍) ក្នុងត្រីមាសទី 1។ ផ្ទៃដីមានអាចស្រោចស្រពបានតាមស្ថានីយ៍និមួយៗ នឹងត្រូវប្រើសម្រាប់ផលិតកម្មពូជស្រូវសុទ្ធអនុញ្ញាតិ សម្រាប់ពូជល្អៗមួយចំនួន (ពូជស្រូវស្រាល / កណ្តាល / ធ្ងន់)។ គ្រាប់ពូជសុទ្ធគ្រឹះនៃពូជស្រូវទាំងនេះ នឹងត្រូវទិញផ្ទាល់ដោយស្ថានីយ៍និមួយៗ តែពី CARDI ដោយសារតែ CARDI ជាអ្នកផ្គត់ផ្គង់ពូជសុទ្ធគ្រឹះតែមួយគត់នៅកម្ពុជា។ ស្ថានីយ៍និមួយៗនឹងតម្រូវឲ្យរៀបចំផែនការផលិតកម្មពូជស្រូវសុទ្ធ ផ្អែកលើតម្រូវការរំពឹងទុកនៃគ្រាប់ពូជស្រូវសុទ្ធ នៃប្រភេទពូជដែលត្រូវការដោយក្រុមកសិករផលិតស្រូវពូជ។ ផលិតកម្មស្រូវចំណី នៅលើផ្ទៃដីផ្សេងក្នុងស្ថានីយ៍ អាចធ្វើបាន ប៉ុន្តែគម្រោង នឹងមិនជួយលើផលិតកម្មស្រូវចំណីនេះឡើយ។ ស្ថានីយ៍ស្រាវជ្រាវ នឹងធ្វើកិច្ចសន្យាជាមួយក្រុមកសិករផលិតស្រូវពូជ ដើម្បីផលិតផ្គត់ផ្គង់គ្រាប់ពូជសុទ្ធអនុញ្ញាតិមានគុណភាព សម្រាប់ក្រុមកសិករផលិតពូជទាំងអស់។

នៅពេលស្រូវពូជតាមស្ថានីយ៍ ជិតដល់ពេលប្រមូលផល ស្ថានីយ៍និមួយៗនឹងរៀបចំទិវាស្រែ ហើយសមាជិកក្រុមកសិករផលិតស្រូវពូជ ម្ចាស់រោងម៉ាស៊ីនស្រូវ កសិករផលិតស្រូវចំណីលក់ និងអ្នកលក់គ្រាប់ពូជស្រូវ នឹងត្រូវបានអញ្ជើញឲ្យចូលរួមសង្កេតមើលស្រែស្រូវពូជ តាមប្រភេទពូជដែលល្អៗ ពេញនិយម។

- ✓ ការបណ្តុះបណ្តាលកសាងសមត្ថភាពស្តីពីការគ្រប់គ្រងធុរកិច្ច (រួមទាំង ផ្នែកហិរញ្ញវត្ថុ/កត់ត្រា គណនេយ្យ និងទីផ្សារ) នឹងត្រូវបានរៀបចំផ្តល់ដល់បុគ្គលិកស្ថានីយ៍ ដើម្បីឲ្យបុគ្គលិទាំងនេះ អាចគ្រប់គ្រងកាន់តែមានប្រសិទ្ធភាពលើកម្មវិធីផលិតកម្មពូជស្រូវរបស់ស្ថានីយ៍។

### (c) ជ្រើសរើសពូជស្រូវសមស្រប ផ្អែកលើតម្រូវការទីផ្សារ និង រៀបចំបង្កើតយុទ្ធសាស្រ្តទីផ្សារ

- ✓ ដើម្បីកំណត់ពីតម្រូវការពូជស្រូវល្អៗ ក្រុមគាំទ្រថ្នាក់ក្រុង ស្រុក (DSTs) ដោយមានជំនួយពីទីប្រឹក្សា PAEAs/PICs និងក្រុមការងាររបស់ GDA នឹងរៀបចំធ្វើអង្កេតតាមឃុំ សង្កាត់គោលដៅនៅសល់ចំនួន 92 ក្នុងអំឡុងត្រីមាសទី 1 ។ ក៏នឹងមានធ្វើអង្កេតជាមួយនឹងរោងម៉ាស៊ីនស្រូវមួយចំនួនក្នុងខេត្តនិមួយៗ ដើម្បីកំណត់ពីប្រភេទពូជស្រូវ ដែលគេត្រូវការ។ លទ្ធផលនៃការអង្កេតទាំងនេះ នឹងត្រូវបានផ្សព្វផ្សាយ/ចែករំលែកជាព័ត៌មាននឹងគ្នា នៅក្នុងកិច្ចប្រជុំប្រចាំត្រីមាស រវាងរោងម៉ាស៊ីនស្រូវ និងក្រុមកសិករផលិតស្រូវពូជ ហើយសិក្ខាសាលាពិគ្រោះយោបល់មួយ នឹងត្រូវរៀបចំតាមខេត្តគោលដៅនិមួយៗ ដើម្បីចែករំលែកជាព័ត៌មានស្តីពីលទ្ធផលអង្កេតរកឃើញ និង ឈានទៅឯកភាពព្រមព្រៀងគ្នាលើប្រភេទពូជកែលម្អថ្មីៗ ដែលគួរជាការផ្តោតនៃកម្មវិធីផលិតគ្រាប់ពូជស្រូវ។

### (d) កសាងសមត្ថភាពក្រុមផលិតស្រូវពូជ ដើម្បីផលិត និងចែកចាយគ្រាប់ពូជ បានប្រសើរឡើង

- ✓ ការបណ្តុះបណ្តាលកសាងសមត្ថភាព នឹងត្រូវបានរៀបចំសម្រាប់ក្រុមកសិករផលិតស្រូវពូជ ដែលទើបបានចងក្រងថ្មី។ ការបណ្តុះបណ្តាលនេះ នឹងត្រូវរៀបចំក្នុងទម្រង់ជាសាលារៀនស្រែកសិករផលិតស្រូវពូជ ក៏ដូចជា ក្នុងទម្រង់ជាការបណ្តុះបណ្តាលបច្ចេកទេសស្តីពីការត្រួតពិនិត្យផលិតកម្មគ្រាប់ពូជស្រូវ ។ មេរៀនដកពិសោធន៍បានពីការអនុវត្តសាលារៀនស្រែកសិករក្នុងឆ្នាំ 2013 សម្រាប់ក្រុមកសិករផលិតស្រូវពូជ នឹងត្រូវបានពិនិត្យរួមបញ្ចូលក្នុងគោលការណ៍ណែនាំសម្រាប់សាលារៀនស្រែកសិករផលិតស្រូវពូជ។

- ✓ បន្ទាប់ពីបញ្ចប់សិក្ខាសាលាពិគ្រោះយោបល់រវាងក្រុមកសិករផលិតស្រូវពូជ និង រោងម៉ាស៊ីនស្រូវក្នុងមូលដ្ឋានខេត្តនិមួយៗ គម្រោងនឹងបន្តជួយគាំទ្រពង្រឹងថែមទៀតនូវចំណងទាក់ទងរវាងក្រុមកសិករផលិតស្រូវពូជ ជាមួយរោងម៉ាស៊ីនស្រូវតាមមូលដ្ឋាន ដោយការជួយសម្របសម្រួលការប្រជុំត្រីមាសក្នុងខេត្តនិមួយៗ ដើម្បីធានាថាកម្មវិធីផលិតពូជស្រូវ ត្រូវបានសម្រួលឲ្យឆ្លើយតបនឹងតម្រូវការគ្រាប់ពូជស្រូវ និងដើម្បីលើកកំពស់ផ្សព្វផ្សាយពីផលិតកម្មតាមកិច្ចសន្យា រវាងក្រុមកសិករផលិតស្រូវពូជ និងរោងម៉ាស៊ីនស្រូវ។ ក្នុងខេត្តនិមួយៗ មន្ទីរកសិកម្មខេត្ត នឹងដើរតួសម្របសម្រួល ការប្រជុំប្រចាំត្រីមាសដាច់ដោយឡែកពីគ្នា ជាមួយតំណាងមកពីក្រុមកសិករផលិតស្រូវពូជទាំងអស់។ នឹងមានការបណ្តុះបណ្តាលបន្ថែម រៀបចំផ្តល់ឲ្យដល់សមាជិកក្រុមកសិករផលិតស្រូវពូជ ក្នុងអំឡុងត្រីមាសទី 2 និងត្រីមាសទី 4 លើប្រធានបទស្តីពី ការកសាងផែនការ ការគ្រប់គ្រង និងកត់ត្រា (ចំណាយចំណូលផលិតកម្ម/គណនេយ្យ) ការវេចខ្ចប់ ការរៀបចំផែនការធុរកិច្ច និង យុទ្ធសាស្ត្រធ្វើទីផ្សារ។ ការចុះពិនិត្យមើលផលិតកម្មគ្រាប់ពូជស្រូវតាមស្រែផលិត នឹងត្រូវធ្វើដោយក្រុមគាំទ្រថ្នាក់ស្រុក/ការិយាល័យកសិកម្មស្រុក និងបុគ្គលិកមន្ទីរកសិកម្មខេត្ត។

ដើម្បីឲ្យសមាជិកក្រុមកសិករផលិតស្រូវពូជ អាចពង្រីកចំណេះដឹងរបស់ពួកគាត់ គម្រោងនឹងរៀបចំទស្សនកិច្ច ទៅសិក្សាដកពិសោធន៍កម្មវិធីផលិតកម្មស្រូវពូជលក់ជាក្រុមអនុវត្តទទួលបានជោគជ័យនៅប្រទេសវៀតណាម។[11] ផ្អែកលើការប៉ាន់ប្រមាណលើសមត្ថភាព និងបរិក្ខារមានស្រាប់របស់ក្រុមកសិករផលិតស្រូវពូជ គម្រោងនឹងរៀបចំការគាំទ្រ ផ្នែកបរិក្ខារស្តុកទុកដាក់ស្រូវ និងឧបករណ៍កែច្នៃផ្សេងទៀត។

(e) **រៀបចំការធ្វើបង្ហាញបច្ចេកទេសកសិកម្ម និង ធ្វើអង្កេតដើម្បីប៉ាន់ប្រមាណពីកំណើនទិន្នផល**

- ✓ ក្នុងអំឡុងត្រីមាសទី 2-4 ក្នុងខេត្តនិមួយៗ នឹងមានរៀបចំការធ្វើបង្ហាញបច្ចេកទេសថែមទៀត នៅតាមឃុំគោលដៅនានា។ ជាសរុប នឹងមានការធ្វើបង្ហាញបច្ចេកទេសជាង 430 ទីតាំង សម្រាប់ដំណាំស្រូវ បន្លែ ផ្សិត ដំណាំលក់ ចិញ្ចឹមសត្វ និង វារីវប្បកម្ម។
- ✓ នៅតាមទីតាំងធ្វើបង្ហាញបច្ចេកទេសនិមួយៗ នឹងមានរៀបចំធ្វើទិវាបូកសរុបផ្សព្វផ្សាយលទ្ធផលបង្ហាញ ក្នុងពេលប្រមូលផល ហើយកសិករពីក្រុម LIGs នឹងត្រូវបានអញ្ជើញឲ្យចូលរួមក្នុងទិវានេះ។

| ប្រភេទធ្វើបង្ហាញបច្ចេកទេសកសិកម្ម | ចំនួនធ្វើបង្ហាញ |
|---|---|
| ពូជស្រូវ/ប្រពលវប្បកម្មដំណាំស្រូវ | 184 |
| ផលិតកម្មដំណាំបន្លែ | 90 |
| ដំណាំលក់(ដំណាំចំការ) | 38 |
| ផលិតកម្មផ្សិត | 26 |
| ចិញ្ចឹមសត្វ | 91 |
| វារីវប្បកម្ម | 3 |
| **សរុប** | **432** |

(f) **យុទ្ធនាការផ្សព្វផ្សាយបង្កើនការយល់ដឹងពីផលិតកម្មស្រូវពូជដែលគម្រោងសម្រេចបាន**

- ✓ ក្នុងខេត្តនិមួយៗ អគ្គនាយកដ្ឋានកសិកម្ម ដោយសហការជាមួយមន្ទីរកសិកម្មខេត្ត នឹងរៀបចំផ្សព្វផ្សាយព័ត៌មានដែលនឹងផ្តល់ព័ត៌មានបន្ថែមទៀតដល់កសិករ ស្តីពីបច្ចេកទេសផលិតកម្មស្រូវពូជ និងផលប្រយោជន៍របស់ប្រភេទពូជសុទ្ធស្រូវល្អៗ ដែលក្រសួងកសិកម្មកំពុងផ្សព្វផ្សាយ។[12] នឹងមានការផ្សព្វផ្សាយព័ត៌មានផងដែរស្តីពីដំណាំលក់(ដំណាំចំការ)មួយចំនួន និងផលប្រយោជន៍នៃពិពិធភាវូនីយកម្ម(ផលិតកម្មច្រើនមុខ)ដំណាំ។

[11] ឯកសារទស្សនភាពលម្អិតពីទិសដៅ និងលទ្ធផលរំពឹងទុក ស្ថាប័នម្ចាស់ផ្ទះរៀបចំទទួល បញ្ជីអ្នកចូលរួម រួមទាំងស្ត្រីផង និង ថវិកាលម្អិត និងខ្ទង់ថវិកាត្រូវចំណាយ នឹងត្រូវរៀបចំដោយ GDA ផ្ញើមក ADB ដោយ DCU ដើម្បីសុំការយល់ព្រម មុននឹងចាប់ផ្តើមរៀបចំទស្សនកិច្ច។

[12] ការផ្សព្វផ្សាយពីព័ត៌មាននេះ នឹងត្រូវបានរួមបញ្ចូលក្នុងកម្មវិធីផ្សាយផ្សាយតាមវិទ្យុ ដែលគាំទ្រក្នុងលទ្ធផល 2.3.

- ✓ ក្នុងខេត្តនិមួយៗ នឹងមានការគាំទ្រការរៀបចំពិព័រណ៍ពាណិជ្ជកម្មកសិកម្មប្រចាំឆ្នាំ នៅចុងឆ្នាំ ដើម្បីបង្ហាញកសិផល របស់កសិករធ្វើបង្ហាញ និង សមាជិកក្រុមកសិករផលិតពូជស្រូវ ដល់ក្រុមកែលម្អជីវភាព និង កសិករផ្សេងទៀត មក ពីទូទាំងខេត្ត។

(g) **ការបោះពុម្ពឯកសារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម**

- ✓ អគ្គនាយកដ្ឋានកសិកម្ម នឹងបន្តចែកឯកសារផ្សព្វផ្សាយបច្ចេកទេសស្តីពីផលិតកម្មស្រូវ បន្លែ និង ការចិញ្ចឹមសត្វ ដែលត្រូវបានរៀបចំចងក្រងដោយបុគ្គលិកផ្សព្វផ្សាយរបស់ខ្លួន និងផ្អែកលើឯកសារផ្សព្វផ្សាយ ដែលបានចងក្រង ដោយគម្រោង TSTD និង គម្រោងផ្តល់ថវិកាដោយ USAID។ មាតិកានៃឯកសារទាំងនេះនឹងត្រូវបានពិនិត្យមើល ហើយរចនាបថបង្ហាញរបស់ឯកសារ នឹងត្រូវបានកែលម្អ ដើម្បីធានាថាវាមានលក្ខណៈសមស្រប ងាយយល់បាន សម្រាប់សមាជិកក្រុម LIG ដោយពិចារណាលើកម្រិតចេះអក្សររបស់ពួកគាត់។ នឹងមានការផ្តោតលើរចនាបថ បង្ហាញមានសណ្ឋានជាលក្ខណៈរូបភាព/ដ្យាក្រាម ជំនួយដល់ការយល់ សម្រាប់គ្រប់ឯកសារបណ្តុះបណ្តាលទាំង អស់។ ឯកសារផ្សព្វផ្សាយទាំងនេះ នឹងត្រូវបានបោះពុម្ព ផ្តល់ឲ្យមន្ទីរកសិកម្មខេត្តគោលដៅនិមួយៗ សម្រាប់ចែកឲ្យ ក្រុមកសិករ LIGs និងអ្នកផ្សព្វផ្សាយឃុំ។ រាល់ឯកសារផ្សព្វផ្សាយទាំងនេះ ក៏នឹងត្រូវដាក់បញ្ចូលក្នុងវេបសាយរបស់ គម្រោង TSSD ដើម្បីឲ្យឯកសារទាំងនេះអាចយកប្រើប្រាស់បាន ដោយថ្នាក់ក្រោមជាតិ។

### C.4.4 បង្កើនលទ្ធភាពអាចរកបានព័ត៌មានកសិកម្ម និង ទិន្នន័យទីផ្សារ ( NiDA/NCDDS )

19. ឥឡូវនេះ ការគាំទ្រដល់កម្មវិធីអាយស៊ីធីជនបទ (Rural ICT) នឹងផ្តោតខ្លាំងនៅថ្នាក់ក្រោមជាតិ តាមរយៈការបង្កើត ឡើងនូវចំណងទាក់ទងរឹងមាំ រវាងមណ្ឌលព័ត៌មានកសិករជនបទ (តេលេស៊ិនធ័រ) ក្នុងឃុំ សង្កាត់គោលដៅរបស់គម្រោង និង ក្រុមប្រឹក្សាឃុំ សង្កាត់សាមីនិមួយៗ។ ទន្ទឹមគ្នានេះ ក៏នឹងមានការគាំទ្រសម្រាប់កម្មវិធីផ្តល់ព័ត៌មានចល័តថ្នាក់ឃុំ សង្កាត់ (MCA) ដែលនឹងអនុវត្តសាកល្បងនូវបច្ចេកវិទ្យាចល័តសម្រាប់ផ្សព្វផ្សាយព័ត៌មានផ្សព្វផ្សាយកសិកម្ម តាមរយៈអ្នកផ្សព្វ ផ្សាយកសិកម្មឃុំ សង្កាត់។

20. សកម្មភាពចំបងៗ មានដូចជា៖

**(a) កម្មវិធីផ្តល់ព័ត៌មានចល័តថ្នាក់ឃុំ សង្កាត់**

- ✓ មាតិកាបច្ចេកទេសកសិកម្ម សម្រាប់កម្មវិធីផ្តល់ព័ត៌មានចល័តថ្នាក់ឃុំ សង្កាត់(MCA) ដែលបានប្រមូលពីគម្រោង បង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពក្នុងតំបន់ទន្លេសាប(TSTD) និងពីប្រភពផ្សេងទៀត ត្រូវបានរៀបចំជាទម្រង់ សមស្រប ដោយមានរៀបឯកសារប្រើឈ្មោះជាភាសាខ្មែរ បែងចែកតាមប្រធានបទចំបងៗ (ដំណាំ ចិញ្ចឹមសត្វ...) និងប្រធានបទរង។ មាតិកាបានរៀបចំហើយនេះ ត្រូវបានប្រគល់ឲ្យក្រុមការងារណៃដា សម្រាប់បញ្ចូលក្នុងឧបករណ៍ ផ្តល់ព័ត៌មានចល័ត ដែលនឹងត្រូវផ្តល់ឲ្យអ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ (CEW) ម្នាក់ៗ។ ការបណ្តុះបណ្តាលពី ការប្រើប្រាស់ឧបករណ៍នេះ គ្រោងនឹងរៀបចំធ្វើក្នុងត្រីមាសទី 1 ដោយក្រុមការងារ NiDA ។

- ✓ មាតិកាបច្ចេកទេសទាំងនេះ ក៏នឹងត្រូវបញ្ចូលក្នុងកុំព្យូទ័រ desktops របស់បណ្ណាល័យអេឡិចត្រូនិច (e-Libraries) ដែលបានរៀបចំបង្កើតដោយគម្រោង TSTD នៅតាមមន្ទីរកសិកម្មខេត្តគោលដៅទាំងបួន។ មាតិកាបច្ចេកទេសនេះ ក៏នឹងត្រូវចែកចាយដល់តេលេសិុនធ័រ ក្រុមការងារថ្នាក់ក្រុង ស្រុក និង ថ្នាក់ឃុំ សង្កាត់ផងដែរ។
- ✓ ដើម្បីពង្រីកវិសាលភាព និងប្រភេទខ្លឹមសារ(ព័ត៌មាន)មានលក្ខណៈសមស្របសម្រាប់កសិករខ្នាតតូច, លេខាធិការដ្ឋានគ.ជ.អ.ប (NCDDS) នឹងជ្រើសរើសសេវាករពីក្រៅ ដើម្បីផលិតខ្សែវីដេអូបណ្តុះបណ្តាលអាយសុីធី និង មាតិកាពហុ-ទម្រង់មធ្យោបាយផ្សព្វផ្សាយព័ត៌មាន (ពហុ-មេដ្យា) ចំនួន 20 ប្រធានបទ។ ប្រធានបទមាតិកាបច្ចេកទេសទាំងនេះ នឹងត្រូវជ្រើសរើសផ្អែកលើតម្រូវការរបស់សមាជិក្រុម LIG ដើម្បីគាំទ្រដល់សកម្មភាពកែលម្អជីវភាពជាអាទិភាព ដែលក្នុងចំណោមប្រភពព័ត៌មានផ្សេងទៀត អាចត្រូវបានកំណត់បានពីលទ្ធផលប៉ាន់ប្រមាណពីតម្រូវការ ដែលនឹងត្រូវបានរៀបចំធ្វើដោយសេវាករជំនាញ SSP2។
- ✓ គម្រោងក៏នឹងជួយគាំទ្រផងដែរដល់ការភ្ជាប់បណ្តាញ និងទំនាក់ទំនងគ្នាជាមួយគម្រោងផ្សេងទៀត ដែលកំពុងរៀបចំផលិតកម្មវិធីចល័តផ្តល់មាតិកាជាក់ស្តែង (Apps) ឬក៏ ទម្រង់ផ្សេងទៀតនៃពហុ-មេដ្យាសម្រាប់ប្រើដោយឧបករណ៍ផ្តល់ព័ត៌មានចល័ត ដែលមានលក្ខណៈសមស្រប/មានប្រយោជន៍សម្រាប់ការផ្សព្វផ្សាយតាមមូលដ្ឋាន (ដោយអ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់) និង ក្រុមកសិករខ្នាតតូច។

### (b) ផ្តល់ការបណ្តុះបណ្តាលជំនាញ/បំនិនកុំព្យូទ័រ ដល់ក្រុមការងារថ្នាក់ក្រុង ស្រុក

- ✓ ដោយសារមានទឹកទឹកជំនន់ឆ្នាំកន្លងទៅ និង ការជាន់កម្មវិធី/ពេលវេលាគ្នា ក្នុងត្រីមាសទី 4 ឆ្នាំ2013, ក្រុមការងារ NiDA អាចរៀបចំផ្តល់ការបណ្តុះបណ្តាលជំនាញកម្រិតមូលដ្ឋានប្រើប្រាស់កុំព្យូទ័រ សម្រាប់តែក្រុមមន្ត្រីថ្នាក់ក្រុង ស្រុកចំនួន 14 ក្រុង ស្រុកក្នុងខេត្ត បន្ទាយមានជ័យ និង សៀមរាប ប៉ុណ្ណោះ។ ការបណ្តុះបណ្តាលដូចគ្នានេះ សម្រាប់ 14 ផ្សេងទៀត ក្នុងខេត្ត កំពង់ចាម និង ខេត្តកំពង់ធំ គ្រោងនឹងអនុវត្តឲ្យចប់ក្នុងត្រីមាសទី 1។

### (c) ការគាំទ្រដល់មណ្ឌលព័ត៌មានកសិករជនបទ/តេលេសុិនធ័រ (TCs)

- ✓ ក្រុមការងារ NiDA នឹងបញ្ចប់ការបណ្តុះបណ្តាលស្តីពីការប្រើកុំព្យូទ័រ (Khmer Unicode, Open Source, social media/face book, internet and email) ដល់តេលេសុិនធ័រ (TC) នៅសល់មិនទាន់បានបណ្តុះបណ្តាលទាំង 9 ដែលថិតនៅក្រៅតំបន់គោលដៅរបស់គម្រោង។
- ✓ ចំពោះតេលេសុិនធ័រចំនួន 11 ដែលថិតក្នុងឃុំ សង្កាត់/ក្រុង ស្រុកគោលដៅរបស់គម្រោង នឹងទទួលបានការជួយចេញថ្លៃចំណាយប្រតិបត្តិការពេញមួយឆ្នាំនេះ ដែលថ្លៃចំណាយនេះនឹងត្រូវផ្តល់ឲ្យដោយឃុំ សង្កាត់សាមុីនិមួយៗ ដោយប្រើថវិកាពីមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់។ កិច្ចសន្យាជាផ្លូវការក្នុងទម្រង់ជាឯកសារផ្លូវច្បាប់ មានបញ្ចូលនូវខ្លឹមសារស្តីពីទស្សនទានគ្រប់គ្រងជាមូលដ្ឋាន ដែលផ្តល់នូវគោលការណ៍តម្រង់ទិសសម្រាប់ដំណើរការ/ប្រតិបត្តិការតេលេសុិធ័រដោយប្រតិបត្តិករ និងក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវរៀចំឡើងរវាងប្រតិបត្តិករតេលេសុិនធ័រនិមួយៗ ជាមួយនឹង ក្រុមប្រឹក្សាឃុំ សង្កាត់សាមុី មុននឹងការជួយចេញថ្លៃចំណាយនេះ អាចចាប់ផ្តើមបាន។

- ✓ ឧបករណ៍អាយស៊ីធី សម្រាប់តេលេស៊ិនធ័រ និង បណ្ណាល័យអេឡិចត្រូនិច នៅតាមមន្ទីរកសិកម្មខេត្តនិមួយៗ ក៏ដូចជា ឧបករណ៍/សម្ភារៈផ្សេងទៀតដែលបានផ្តល់ឲ្យក្រោមគម្រោង TSTD បានផ្ទេររួចរាល់ហើយ (ពី ADB-CARM) ទៅប្រធានសម្របសម្រួលថ្នាក់ជាតិក្រសួងកសិកម្មនៃគម្រោង TSTD នៅចុងឆ្នាំ 2013 ហើយបន្ទាប់មក នឹងត្រូវប្រគល់បន្តមកឲ្យនាយកគម្រោង MAFF-TSSD។ មុននឹងមានការរៀបចំអនុវត្តការគាំទ្ររបស់ឃុំ សង្កាត់ ដល់តេលេស៊ិនធ័រ ជាការចាំបាច់ត្រូវមានការសម្របសម្រួលមានលក្ខណៈរលូន សម្រាប់ការផ្ទេរនូវឧបករណ៍អាយស៊ីធី និងឧបករណ៍ និងសម្ភារៈការិយាល័យ ពីមន្ទីរកសិកម្មខេត្ត ទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ទាំង 11 ដែលតេលេស៊ិនធ័រជាគោលដៅទាំងនេះ ថិតនៅ។[13]
- ✓ ជំនួយបច្ចេកទេស នឹងត្រូវបានផ្តល់ឲ្យទៅ តេលេស៊ិនធ័រនិមួយៗ ក្នុងចំណោមតេលេស៊ិនធ័រទាំង 11 ដែលថិតក្នុងឃុំ សង្កាត់គោលដៅរបស់គម្រោង TSSD សម្រាប់រៀបចំផែនការធុរកិច្ច និង ការអនុវត្តផែនការនោះ សម្រាប់តេលេស៊ិនធ័រនិមួយៗ។ ផែនការធុរកិច្ចនេះ នឹងកំណត់ពីសកម្មភាពផ្តល់ប្រាក់ចំណូល ដែលនឹងអនុវត្តដោយតេលេស៊ិធ័រនិមួយៗ ផ្អែកលើសក្តានុពល និងអាទិភាពតាមមូលដ្ឋាន ដើម្បីធានាបាននូវនិរន្តភាពប្រតិបត្តិការរបស់តេលេស៊ិនធ័រ នៅចុងឆ្នាំ 2014 នៅពេលដែលជំនួយពីខាងក្រៅ ត្រូវបានបញ្ចប់។ នឹងមានទីប្រឹក្សាជាតិរហូតដល់បីនាក់ ត្រូវបានជ្រើសរើសជាលក្ខណៈបុគ្គលដាច់ៗគ្នា ដោយ NCDDS ដើម្បីធ្វើការក្រោមការណែនាំតម្រង់ទិសពីអ្នកជំនាញប្រាស្រ័យទាក់ទងជនបទ និងកែលម្អជីវភាព (RCLIE) ដើម្បីអនុវត្តកិច្ចការទាំងនេះ។[14]
- ✓ ចំណងទាក់ទងរវាងតេលេស៊ិនធ័រ និង អ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន (មានដូចជា ក្រុមគាំទ្រថ្នាក់ក្រុង ស្រុក អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមកសិករ...) នឹងត្រូវបានពង្រឹង តាមរយៈកិច្ចសម្របសម្រួលជាប្រចាំ និងការគាំទ្រគ្នាទៅវិញទៅមកសម្រាប់អន្តរកម្មរបស់តួអង្គ/អ្នកពាក់ព័ន្ធគន្លឹះៗនៅថ្នាក់មូលដ្ឋាន។ ការលើកកំពស់ផ្សព្វផ្សាយពីតេលេស៊ិនធ័រ (ក្នុងន័យជា សេវាកម្មរបស់តេលេស៊ិនធ័រ និង ការប្រើប្រាស់សេវាកម្មបានកើនឡើងដោយអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន រួមទាំង ដោយក្រុមប្រឹក្សាឃុំ សង្កាត់ផង) ការភ្ជាប់ទំនាក់ទំនងតេលេស៊ិនធ័រ ជាមួយនឹងកម្មវិធីធ្វើបង្ហាញបច្ចេកទេសកសិកម្ម និង ជាមួយក្រុមកសិករផលិតស្រូវពូជ.... គឺជាស្នូលនៃជោគជ័យ និងនិរន្តរភាពរបស់តេលេស៊ិនធ័រ។

#### (d) ការរៀបចំបង្កើត និងដាក់ឲ្យដំណើរការវេបសាយគម្រោង TSSD

- ✓ ដោយសារថា គម្រោង TSSD កំពុងតែខិតជិតពេលវេលាពាក់កណ្តាលគម្រោង ហើយឥឡូវនេះ បានសម្រេចនូវវឌ្ឍនភាពល្អ នឹងមានតម្រូវការបន្ទាន់ឲ្យគម្រោងមានគេហទំព័រ (វេបសាយ) ដែលដំណើរបានពេញលេញ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ។ ក៏នឹងមានតម្រូវការបន្ទាន់ផងដែរ ក្នុងការផ្ទេរវេបសាយតេលេស៊ិនធ័រដែលបង្កើតឡើងដោយ

[13] សម្រាប់តេលេស៊ិនធ័រទាំងប្រាំបួន ដែលថិតនៅក្រៅឃុំ/ស្រុកគោលដៅគម្រោង TSSD ឧបករណ៍/សម្ភារៈអាយស៊ីធី ដែលបានដាក់ឲ្យប្រើក្នុងតេលេស៊ិនធ័រទាំងនោះ នឹងត្រូវថិតនៅក្រោមការមើលខុសត្រូវរបស់មន្ទីរកសិកម្មខេត្តសាមីនិមួយៗ ប៉ុន្តែនឹងត្រូវបន្តប្រើ ដោយប្រតិបត្តិករតេលេស៊ិនធ័រទាំងនោះ។

[14] ប្រតិបត្តិករពីតេលេស៊ិនធ័រ ដែលថិតនៅក្រៅឃុំ/ស្រុកគោលដៅគម្រោង នឹងត្រូវបានអញ្ជើញឲ្យចូលរួមក្នុងសកម្មភាពបណ្តុះបណ្តាលដែលនឹងត្រូវបានផ្តល់ឲ្យ ជាផ្នែកមួយនៃដំណើរការអភិវឌ្ឍន៍ផែនការធុរកិច្ច។

គម្រោងTSTD ឲ្យស្ថិតក្រោមការគ្រប់គ្រងថែទាំដោយTSSD ហើយធានាបានការធ្វើបច្ចុប្បន្នភាពជាប្រចាំនូវមាតិកាបច្ចេកទេស(រួមមាន ខ្លឹមសារកសិកម្ម ខ្លឹមសារក្រៅពីកសិកម្ម ព័ត៌មានទីផ្សារ គោលនយោបាយ ....)។ របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ គួរតែជាមាតិកា/ខ្លឹមសារសមស្របមួយសម្រាប់ ចែករំលែកតាមវេបសាយនេះ ផងដែរ។ ការទទួលខុសត្រូវលើការរៀបចំ និងថែទាំវេបសាយនេះ នឹងជាបន្ទុករបស់អង្គភាពសម្របសម្រួលការអភិវឌ្ឍ របស់ក្រសួងកសិកម្ម (MAFF-DCU) ប៉ុន្តែនឹងត្រូវការជ្រើសរើសបុគ្គលិករដ្ឋមានលក្ខណៈសមស្រប ចំនួនពីរនាក់បន្ថែមលើក្រុមការងារអង្គភាពសម្របសម្រួលការអភិវឌ្ឍ (DCU) មានប្រាំមួយនាក់បច្ចុប្បន្ន ដើម្បីជួយធ្វើកិច្ចការទាំងនេះ។[15] ការតភ្ជាប់ជាមួយវេបសាយរបស់ CARD, NCCDS... ក៏នឹងត្រូវបង្កើតឲ្យមាន ផងដែរនៅលើវេបសាយរបស់គម្រោង ដែលនឹងត្រូវបង្កើតនេះ។

### (e) កម្មវិធីវិទ្យុ (គាំទ្រដល់សម្មភាពតាមមូលដ្ឋានរបស់អ្នកផ្សព្វផ្សាយ)

✓ កម្មវិធីផ្សព្វផ្សាយតាមវិទ្យុដោយមានទទួលការហៅទូរស័ព្ទចូល នឹងត្រូវរៀបចំប្រចាំត្រីមាស (តាមរយៈស្ថានីយ៍វិទ្យុតាមខេត្ត) ក្នុងខេត្តនិមួយៗ។ កម្មវិធីនេះ នឹងគាំទ្រដល់ការផ្សព្វផ្សាយតាមមូលដ្ឋាន ស្តីពីប្រធានបទចំបងៗដែលជាទីចាប់អារម្មណ៍របស់មូលដ្ឋាន ដែលអាចមានដូចជា ប្រភេទពូជស្រូវកែលម្អថ្មីៗ ពូជមានគុណភាព និងទីផ្សារ ការចិញ្ចឹមសត្វ...។ បុគ្គលជំនាញបច្ចេកទេសមកពីមន្ទីរកសិកម្មខេត្ត ក៏ដូចជាពីមន្ទីរពាក់ព័ន្ធផ្សេងទៀត និង អ្នកជំនាញក្នុងមូលដ្ឋាន រួមទាំងម្ចាស់រោងម៉ាស៊ីនស្រូវ ក្រុមកសិករផលិតពូជដំណាំ កសិករដាំដំណាំលក់ តំណាងសភាពាណិជ្ជកម្មខេត្ត..... ក៏នឹងត្រូវបានអញ្ជើញឲ្យចូលរួមជា វាគ្មិន នៅក្នុងកម្មវិធីនេះ ដើម្បីផ្តល់ចម្លើយចំពោះសំណួររបស់កសិករ។ ជាគោលបំណងចង់បាននោះ គឺ ភ្ជាប់ការទាក់ទងគ្នារវាងតួអង្គសំខាន់ៗក្នុងសង្វាក់អាជីវកម្មផលិតផលនានា ហើយតាមរយៈដំណើរការទាក់ទងគ្នានេះ គាត់នឹងចែករំលែកព័ត៌មាន និងបង្កើតទំនាក់ទំនងផ្តល់ផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមក។

### (f) ការកែលម្អសមត្ថភាពអាយស៊ីធីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

✓ លទ្ធផលនៃការអនុវត្តសាកល្បងកម្មវិធីអាយស៊ីធីជនបទ តាមរយៈតេលេស៊ិនធ័រ របស់គម្រោង TSTD មិនបានសម្រេចដល់កម្រិតរំពឹងទុក ដែលនាំទៅដល់ការកែសម្រួលផ្នែកយុទ្ធសាស្រ្ត និង ការផ្តោតការងារក្នុងផ្នែកនេះ របស់គម្រោង TSSD។ ជាលទ្ធផល អភិក្រម (យុទ្ធវិធី) ផ្សេងកំពុងត្រូវបានទទួលយក ដែលពឹងផ្អែកលើការប្រើបច្ចេកវិទ្យាអាយស៊ីធីចល័ត។ កម្មវិធីអាយស៊ីធីចល័តនេះ នឹងចាប់ផ្តើមប្រតិបត្តិការពេញលេញនៅដើមត្រីមាសទី 2។ ដើម្បីភ្ជាប់ទំនាក់ទំនងកម្មវិធីនេះ ជាមួយនឹងតួអង្គ/អ្នកពាក់ព័ន្ធគន្លឹះៗតាមមូលដ្ឋាន គម្រោងនឹងផ្តល់ជំនួយសម្រាប់កែលម្អសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈការផ្តល់បរិក្ខារ អាយស៊ីធីជនបទ កម្រិតមូលដ្ឋានដល់សាលាឃុំ សង្កាត់និមួយៗ (ឧបករណ៍ /បរិក្ខារអាយស៊ីធី ផ្ទាំងកញ្ចក់សូឡែរអគ្គីសនី អំពូល កង្ហារជញ្ជាំង និង បណ្តាញអិនធ័រណេត[16])

[15] ចំនួនបុគ្គលិកសហការរបស់រដ្ឋាភិបាល មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងមិនកើនឡើងទេ ប៉ុន្តែនឹងការកែប្រែ/ផ្លាស់ប្តូរមុខតំណែងចំនួនពីរ ក្នុងចំណោមមុខតំណែងដែលមានស្រាប់។

[16] ថ្លៃភ្ជាប់អ៊ិនធ័រណេត ត្រូវរំពឹងថា នឹងត្រូវបង់/ចំណាយ ដោយក្រុមប្រឹក្សាឃុំសាម៉ីនិមួយៗ ចេញពីខ្ទង់ថវិកាចំណាយប្រតិបត្តិការ។

និង បង្កើនជំនាញប្រើប្រាស់កុំព្យូទ័រ កម្រិតមូលដ្ឋាន ដល់បុគ្គលិកឃុំ សង្កាត់។ បែបនេះ ក្រុមប្រឹក្សាឃុំ សង្កាត់អាចកែលម្អសមត្ថភាព និង ប្រសិទ្ធផលគ្រប់គ្រងគម្រោង (ការគ្រប់គ្រងព័ត៌មាន ការប្រាស្រ័យទាក់ទងជាការសរសេរ ជាមួយថ្នាក់ក្រុង ស្រុក ខេត្ត និង ការរាយការណ៍) និង លទ្ធភាពអាចរកប្រើប្រាស់បាននូវព័ត៌មានកសិកម្ម និងទីផ្សារតាមអ៊ិនធ័រណេត និង ឯកសារផ្ទុកក្នុងកុំព្យូទ័រ (គឺថា មាតិការបស់កម្មវិធីផ្តល់ព័ត៌មានចល័តតាមឃុំ សង្កាត់ MCA)។

## C.5 សមាសភាគទី 3: ការគ្រប់គ្រងគម្រោងមានប្រសិទ្ធភាព ( គ្រប់ភ្នាក់ងារប្រតិបត្តិ- អនុវត្ត)

21. នឹងមានការគាំទ្រជាបន្តសម្រាប់ការប្រជុំជាប្រចាំនៃគណកម្មការតម្រង់ទិសគម្រោង (PSC)។ កិច្ចសម្របសម្រួលសកម្មភាព នៅថ្នាក់ក្រោមជាតិ នឹងត្រូវសម្រេចបានតាមរយៈការជួបប្រជុំប្រចាំខែជាប្រចាំ ដែលបានអនុវត្តនៅថ្នាក់ខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់។ ការទទួលខុសត្រូវជាចំបងលើការពិនិត្យតាមដានសកម្មភាពគម្រោង នឹងជាបន្ទុករបស់ថ្នាក់ក្រោមជាតិ តាមរយៈការបង្កើនសមត្ថភាពរបស់ពួកគេ ដោយការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធ PPMS។ គម្រោងនឹងគាំទ្រកម្មវិធីជាច្រើនសម្រាប់បណ្តុះបណ្តាលកសាងសមត្ថភាពថ្នាក់ក្រោមជាតិ រួមទាំងទស្សនកិច្ចសិក្សាក្នុង និង ក្រៅប្រទេស។

សកម្មភាពចំបងៗ មានដូចជា៖

### C.5.1 ការប្រជុំគណកម្មការតម្រង់ទិសគម្រោង តាមរយៈការប្រជុំជាប្រចាំ នៅ CARD

- ✓ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) នឹងរៀបចំការប្រជុំគណកម្មការតម្រង់ទិសគម្រោងប្រចាំឆមាសចំនួនពីរ ដោយចាប់ផ្តើមពីត្រីមាសទី 2 ដែលក្នុងពេលប្រជុំនេះ គណកម្មការ នឹងពិនិត្យមើលវឌ្ឍនភាពពាក់កណ្តាលឆ្នាំរបស់គម្រោង និង នៅត្រីមាសទី 4 ដើម្បីពិនិត្យមើលលទ្ធផលសម្រេចបានប្រចាំឆ្នាំរបស់គម្រោង (ធៀបនឹងផែនការសកម្មភាព និងថវិកាឆ្នាំ 2014) និង បង្ហាញជូនគណកម្មការនូវសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំបន្ទាប់។ មុនកិច្ចប្រជុំទីមួយការប្រជុំសម្របសម្រួលគម្រោងថ្នាក់ជាតិ នឹងត្រូវរៀបចំដោយអង្គភាពសម្របសម្រួលការអភិវឌ្ឍ (MAFF-DCU)។ បុគ្គលិក CARD នឹងចុះពិនិត្យតាមដានជាប្រចាំ តាមតំបន់គោលដៅរបស់គម្រោង ដើម្បីជួបអ្នកពាក់ព័ន្ធរបស់គម្រោងនៅតាមមូលដ្ឋាន និង ពិភាក្សាពីវឌ្ឍនភាព និងយុទ្ធសាស្ត្រអនុវត្ត របស់គម្រោង។ របាយការណ៍សង្ខេបពីលទ្ធផលរកឃើញតាមរយៈបេសកកម្ម និងការជួបពិភាក្សានេះ និងអនុសាសន៍នឹងត្រូវចែករំលែកជាមួយភ្នាក់ងារប្រតិបត្តិ និងADB។ CARD ក៏នឹងជួយក្នុងការរៀបចំបេសកកម្មពិនិត្យវាយតម្លៃវឌ្ឍនភាពពាក់កណ្តាលគម្រោង ដោយដៃគូអភិវឌ្ឍន៍ ADB/IFAD/GoF ដែលទំនងជានឹងរៀបចំនៅត្រីមាសទី 3 ឆ្នាំ 2014។

### C.5.2 ប្រសិទ្ធភាពសម្របសម្រួល និងត្រួតពិនិត្យ លើសកម្មភាពគម្រោង ដោយថ្នាក់ជាតិ ខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់

#### (a) ការប្រជុំសម្របសម្រួលថ្នាក់ខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់

- ✓ នៅពេលទទួលបានការអនុម័តយល់ព្រមលើផែនការសកម្មភាព និងថវិកាឆ្នាំ 2014 គម្រោងនឹងរៀបចំសិក្ខាសាលាតាមខេត្តនិមួយៗ (នៅចុងខែ មករា) ដើម្បីផ្សព្វផ្សាយពីផែនការសកម្មភាព និងថវិកាឆ្នាំ ដែលបានយល់ព្រម។ ក្នុងអំឡុងពេលសិក្ខាសាលានេះ អ្នកចូលរួមនឹងស្តាប់បទបង្ហាញស្តីពីសកម្មភាព និងថវិកា បានយល់ព្រមសម្រាប់ ឆ្នាំ

2014 ហើយមានឱកាសសាកសួរបញ្ជាក់។ ផែនការសកម្មភាព និងថវិកាឆ្នាំ លម្អិត ជាភាសាខ្មែរ នឹងត្រូវបានចែកឲ្យអ្នកចូលរួម សម្រាប់ជាព័ត៌មាន និងសេចក្តីយោងរបស់គេ សម្រាប់ការអនុវត្តសកម្មភាពក្នុងទូទាំងឆ្នាំ។

- ✓ ការប្រជុំសម្របសម្រួលថ្នាក់ខេត្តប្រចាំខែ នឹងត្រូវបានរៀបចំដោយក្រុមសម្របសម្រួលថ្នាក់ខេត្ត ដោយមានការចូលរួមពីមន្ទីរកសិកម្មខេត្ត/អ្នកសម្របសម្រួលកសិកម្មខេត្ត ទីប្រឹក្សាប្រចាំខេត្ត និងតំណាងពីក្រុមថ្នាក់ក្រុង ស្រុក និងថ្នាក់ឃុំ សង្កាត់។
- ✓ ក្រុមការងារថ្នាក់ជាតិនៃអគ្គនាយកដ្ឋានកសិកម្ម ក្រុមទីប្រឹក្សាអនុវត្តគម្រោង និងទីប្រឹក្សាផ្សព្វផ្សាយកសិកម្មខេត្ត នឹងជួបប្រជុំរៀងរាល់ខែ ដើម្បីពិនិត្យមើលវឌ្ឍនភាព បញ្ហាជួបប្រទះ និង ផែនការអនុវត្តបន្ត។
- ✓ នឹងមានការប្រជុំប្រចាំឆ្នាំតាមខេត្តនិមួយៗ រៀបចំដោយក្រុមសម្របសម្រួលថ្នាក់ខេត្ត ដើម្បីពិនិត្យមើល និង រៀបចំបញ្ជីសេវាករសម្រាប់គម្រោងកែលម្អជីវភាព។
- ✓ ការចុះពិនិត្យតាមដាន និងជួយគាំទ្រ នឹងត្រូវធ្វើជាប្រចាំដោយក្រុមអនុវត្តគម្រោងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។ លើសពីនេះ ការចុះពិនិត្យតាមដានការអនុវត្តសកម្មភាពតាមមូលដ្ឋាន ក៏នឹងត្រូវបានសម្របសម្រួលដោយក្រុមសម្របសម្រួលថ្នាក់ខេត្ត (PFT) ដោយមានការចូលរួមពីបុគ្គលិកមន្ទីរបរិស្ថានទៅតាមឃុំ សង្កាត់គោលដៅ សម្រាប់វាយតម្លៃផលប៉ះពាល់បរិស្ថាន។ នៅពេលចាំបាច់ ក្រុម PFT ក៏នឹងអញ្ជើញបុគ្គលិកមកពីមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត ចុះពិនិត្យតាមឃុំ សង្កាត់គោលដៅ ដើម្បីជួយសម្រួលដល់ការបញ្ជាក់បច្ចេកទេសគម្រោងប្រព័ន្ធស្រោចស្រពខ្នាតតូចផងដែរ។ គម្រោងនឹងផ្តល់ប្រាក់ឧបត្ថម្ភចុះបេសកកម្មពិនិត្យតាមឃុំ សង្កាត់គោលដៅ របស់បុគ្គលិកមន្ទីរពាក់ព័ន្ធទាំងនេះ។
- ✓ រៀងរាល់ត្រីមាស មន្ទីរកសិកម្មខេត្ត/អ្នកសម្របសម្រួលកសិកម្មខេត្ត នឹងធ្វើជាម្ចាស់ផ្ទះរៀបចំការប្រជុំគ្រប់គ្រងប្រចាំត្រីមាស សម្រាប់សមាសភាគទី 2។ នៅក្នុងកិច្ចប្រជុំនេះ អ្នកសម្របសម្រួលកសិកម្មខេត្តទាំងបួន នឹងធ្វើបទបង្ហាញជាសង្ខេប (ជា PPT) ពីវឌ្ឍនភាពប្រចាំត្រីមាស និងផែនការសម្រាប់ត្រីមាសបន្ត សម្រាប់ខេត្តរបស់ខ្លួន។ ក្រុមថ្នាក់ជាតិនឹងចូលរួមក្នុងកិច្ចប្រជុំនេះ ហើយចូលរួមជាមតិយោបល់(+កង្វល់)ទាក់ទងនឹងការគ្រប់គ្រងគម្រោង និងផ្តល់ចំលើយតបទៅលទ្ធផលនៃការចុះពិនិត្យតាមដានការអនុវត្តសកម្មភាពក្នុងខេត្តទាំងបួន ក្នុងអំឡុងត្រីមាស។ ការប្រជុំនេះនឹងរួមបញ្ចូលនូវការទស្សនកិច្ចតាមទីតាំងបង្ហាញមួយចំនួន ក្នុងខេត្តធ្វើជាម្ចាស់ផ្ទះ។

(b) **ការគាំទ្រ និងពិនិត្យតាមដានសកម្មភាពគម្រោង**

- ✓ ការពិនិត្យតាមដានជាប្រចាំ នឹងត្រូវអនុវត្តដោយក្រុមសម្របសម្រួលថ្នាក់ខេត្ត និង អ្នកសម្របសម្រួលកសិកម្មខេត្ត ហើយ សមាជិកក្រុមការងារថ្នាក់ក្រុង ស្រុក DST/ DFT នឹងចុះជាប្រចាំតាមឃុំ សង្កាត់គោលដៅ ក្នុងក្រុង ស្រុករបស់ខ្លួន ដើម្បីពិនិត្យមើលពីវឌ្ឍនភាពរបស់គម្រោងនានា និង ពិភាក្សាជាមួយសមាជិកក្រុម LIG ពីបញ្ហានានាដែលបានកើតមាន។ ក្នុងករណីគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ ការចុះនេះ នឹងរួមបញ្ចូលនូវការពិនិត្យគុណភាពសាងសង់។

- ✓ សម្រាប់សកម្មភាពក្នុងសមាសភាគទី 2, បន្ថែមលើការរៀបចំកម្មវិធីបង្ហាញ/បណ្តុះបណ្តាលតាមមូលដ្ឋាន, សមាជិកក្រុមគាំទ្រថ្នាក់ក្រុង ស្រុក នឹងចុះជួបកសិករ និងក្រុមកសិករដែលបានអនុវត្តជាមួយ ក្នុងឆ្នាំមុន ដើម្បីជម្រុញឲ្យគាត់ទទួលយកអនុវត្តនូវបច្ចេកវិទ្យាបានធ្វើបង្ហាញរួចហើយ (រួមទាំង ពូជស្រូវកែលម្អបានបង្ហាញ) និង ដើម្បីផ្សព្វផ្សាយបន្ត ទៅកសិករផ្សេងទៀត។ លទ្ធផលនៃការចុះជួបតាមដាននេះ នឹងត្រូវឆ្លុះបញ្ចាំង (របាយការណ៍) ជាទម្រង់ព័ត៌មាន/ទិន្នន័យស្តីពីការទទួលយក និងសាយភាយបច្ចេកវិទ្យាដែលបានបង្ហាញផ្សព្វផ្សាយ ហើយត្រូវដាក់បញ្ចូលជាឧបសម្ព័ន្ធ នៃរបាយការណ៍ជាប្រចាំរបស់ខ្លួន ផ្ញើមកអ្នកសម្របសម្រួលកសិកម្មខេត្ត។
- ✓ ក្នុងឆ្នាំ 2013 មានសេចក្តីរាយការណ៍ពីបទពិសោធន៍អនុវត្តបានល្អ របស់ក្រុមគាំទ្រក្រុង ស្រុក (DSTs) មួយចំនួនដែលបានជម្រុញលើកទឹកចិត្តឲ្យអ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ និង ជំនួយការរដ្ឋបាលឃុំ សង្កាត់ ចូលរួមយ៉ាងសកម្មក្នុងការគ្រោងរៀបចំធ្វើបង្ហាញបច្ចេកទេសកសិកម្ម។ ការចូលរួមនេះ បានផ្តល់នូវឱកាសដ៏មានតម្លៃសម្រាប់អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ រៀនមានប្រសិទ្ធភាព (អនុវត្តជាក់ស្តែង) នូវបច្ចេកវិទ្យា/ការអនុវត្តបច្ចេកទេសកសិកម្មថ្មីៗ ហើយការធ្វើបែបនេះ នឹងត្រូវបានលើកទឹកចិត្តបន្តពង្រីកអនុវត្តក្នុងឆ្នាំនេះ ទៅស្រុកផ្សេងទៀត ដែលបានអនុវត្តមិនសូវបានជោគជ័យ ឬ ទៅស្រុកណាដែល មិនទាន់បានអនុវត្ត នៅឡើយ។
- ✓ នឹងមានទិវាបូកសរុបផ្សព្វផ្សាយលទ្ធផល (ឬ ទិវាស្រែ-ចំការ) មួយ សម្រាប់រៀងរាល់ការធ្វើបង្ហាញពីរ ដែលបានរៀបចំក្នុងភូមិពីរជិតគ្នា។ ក្រៅពីកសិករ (រួមទាំងសមាជិកក្រុម LIG/CIG)ក្នុងមូលដ្ឋាន, តាមដែលអាចអនុវត្តទៅបាន, ក៏នឹងមានការអញ្ជើញក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ ប្រតិបត្តិករតេលេស៊ិនធ័រ[17] តាមឃុំ សង្កាត់សាមី និង តួអង្គ សង្វាក់អាជីវកម្មសកម្មចំបងៗមួយចំនួន (អ្នកប្រមូលទិញ រោងម៉ាស៊ីនកិនស្រូវលក់ ក្រុមកសិករផលិតស្រូវពូជ) ឲ្យចូលរួមក្នុងទិវានេះផងដែរ។ គម្រោងនឹងទាញយកប្រយោជន៍ពីការចូលរួមរបស់ពួកគេក្នុងទិវានេះ ដោយជម្រុញឲ្យមានអន្តរកម្ម (ជម្រុញលើកទឹកចិត្តឲ្យចែករំលែកព័ត៌មានមានប្រយោជន៍ផ្សេងៗ, គឺមិនគ្រាន់តែចូលរួមអកម្ម នោះទេ) រវាងគ្នានឹងគ្នា និងជាមួយកសិករក្នុងមូលដ្ឋាន។

### (c) ការផ្ទេរជំនាញ/បំនិនផ្នែកបច្ចេកទេសដល់ក្រុម PSTs/DSTs និង CEWs

- ✓ ក្នុងឆ្នាំ 2013 ការបណ្តុះបណ្តាលបច្ចេកទេសបានគ្រោងស្ទើរតែទាំងអស់សម្រាប់ក្រុមគាំទ្រថ្នាក់ក្រុង ស្រុក (DSTs) ត្រូវបានអនុវត្ត។ យ៉ាងណាក៏ដោយ ការបណ្តុះបណ្តាលស្តីពីបច្ចេកវិទ្យាផលិតកម្មស្រូវ និង វិធីសាស្ត្រផ្សព្វផ្សាយ នឹងត្រូវរំកិលមកឆ្នាំ 2014។ ការបណ្តុះបណ្តាលបន្ថែមត្រូវបានកំណត់ក្នុងឆ្នាំ 2014 សម្រាប់ក្រុម DSTs រួមមាន ការបណ្តុះបណ្តាលស្តីពីសវនកម្ម និង ការបញ្ជាក់ផលិតកម្មគ្រាប់ពូជស្រូវ។ ការបណ្តុះបណ្តាលទាំងនេះ នឹងត្រូវបញ្ចូលបុគ្គលិកស្ថានីយ៍ ហើយត្រូវផ្តល់ឲ្យ ដោយគ្រូមកពីក្រៅ - CARDI។

---

[17] ពីតេលេស៊ិនធ័រ ដែលចិតនៅក្នុងឃុំគោលដៅ ឬ ក្នុងឃុំជាប់/ជិតខាង ក្នុងអំឡុងពេលទិវាបូកសរុបផ្សព្វផ្សាយលទ្ធផល នឹងមានទុកពេលខ្លីមួយ សម្រាប់ផ្សព្វផ្សាយលើកកំពស់ពី តេលេស៊ិនធ័រ (+ សេវាកម្មបម្រើ)។ ការត្រៀមរៀបចំ នឹងត្រូវធ្វើឡើង ដោយមានជំនួយពីក្រុមមន្ត្រីថ្នាក់ ស្រុក / ក្រុមប្រឹក្សាឃុំ / អ្នកផ្សព្វផ្សាយឃុំ។

### (d) ការផ្ទេរជំនាញ/បំនិនផ្នែកគ្រប់គ្រង ដល់ក្រុម PST/DST និង បុគ្គលិកឃុំ សង្កាត់

- ✓ ការបណ្តុះបណ្តាលកសាងសមត្ថភាពមួយចំនួន គ្រោងនឹងរៀបចំសម្រាប់បុគ្គលិកថ្នាក់ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ។ សម្រាប់ការងារគ្រប់គ្រង ការបណ្តុះបណ្តាល ត្រូវបានគ្រោងសម្រាប់សមាជិកក្រុម DST លើប្រធានបទគ្រប់គ្រងហិរញ្ញវត្ថុ (សម្រាប់ ក្រុម DTS និង អ្នកគ្រប់គ្រងស្ថានីយ៍ស្រាវជ្រាវ), ប្រព័ន្ធ PPMS/MIS/database និងការកែលម្អការគ្រប់គ្រងគុណភាពរបស់កម្មវិធីបណ្តុះបណ្តាល/កសាងសមត្ថភាព។

- ✓ ការបណ្តុះបណ្តាលផ្សេងទៀត រួមមាន៖

  - ➢ សម្រាប់ការងារយេនឌ័រ នឹងមានការបណ្តុះបណ្តាលពីរប្រភេទត្រូវបានគ្រោង គឺ - (i) ការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ សម្រាប់ជនបង្គោលយេនឌ័រ (ដោយទីប្រឹក្សាផ្នែកអភិវឌ្ឍន៍សង្គម និងយេនឌ័រ) និង (ii) ការបណ្តុះបណ្តាលថ្នាក់ខេត្ត (ដោយជនបង្គោលយេនឌ័រ)។ ជាផ្នែកមួយនៃការបណ្តុះបណ្តាលគ្រូបង្គោលនេះ គឺដើម្បី (a) ត្រៀមរៀបចំសមត្ថភាពរបស់ជនបង្គោលយេនឌ័រ សម្រាប់ការបណ្តុះបណ្តាលបន្ត ដល់បុគ្គលិកថ្នាក់ក្រោមជាតិ; (b) ការបណ្តុះបណ្តាលរយៈពេលខ្លី (និងខ្លឹមសារ)ស្តីពីយេនឌ័រ សម្រាប់រួមបញ្ចូលជាមួយវគ្គបណ្តុះបណ្តាលបច្ចេកទេសនានា; (c) ការបណ្តុះបណ្តាលរយៈពេលខ្លី (និងខ្លឹមសារ)ស្តីពីយេនឌ័រ សម្រាប់អ្នកគ្រប់គ្រង-សេវាករបានជ្រើសរើសអនុវត្តកិច្ចសន្យា; និង (d) សម្រាប់ពិនិត្យតាមដានវឌ្ឍនភាពការអនុវត្តផែនការសកម្មភាពយេនឌ័រ (ការប្រមូល និងការធ្វើបច្ចុប្បន្នភាពទិន្នន័យ)។ មាតិកាចំបងៗចំនួនប្រាំស្តីពីយេនឌ័រ នឹងត្រូវបានរៀបចំដោយទីប្រឹក្សាអភិវឌ្ឍន៍សង្គម និង យេនឌ័រ (SDGE) សម្រាប់គោលបំណង (b) ខាងលើ។ គ្រប់ការបណ្តុះបណ្តាលទាំងអស់នេះ នឹងត្រូវរៀបចំក្នុងត្រីមាសទី 1។

  - ➢ ការបណ្តុះបណ្តាលថ្នាក់ខេត្ត នឹងត្រូវអនុវត្តដោយទីប្រឹក្សាផ្នែកបរិស្ថាន និងបម្រែបម្រួលអាកាសធាតុ (ECCE) សម្រាប់បុគ្គលិកថ្នាក់ក្រោមជាតិ ស្តីពីការគ្រប់គ្រងបរិស្ថាន និងវិធានការណ៍សម្របនឹងបម្រែបម្រួលអាកាសធាតុ ទាក់ទងនឹងសកម្មភាពកសិកម្ម និងកែលម្អជីវភាព។ វិធានការណ៍គ្រប់គ្រងបរិស្ថានជាក់ស្តែង នឹងត្រូវបញ្ជ្រាបចូលក្នុងការបណ្តុះបណ្តាលបច្ចេកវិទ្យាកសិកម្មសម្រាប់បុគ្គលិក និងសម្រាប់សកម្មភាពកែលម្អជីវភាព។ មាតិតាចំបងៗចំនួនប្រាំ (ដែលឆ្លុះបញ្ចាំងសកម្មភាពចំបងៗក្នុងសមាសភាគទី 2 នៃផែនការសកម្មភាព និងថវិកាឆ្នាំ) ក្នុងទម្រង់ជាម៉ាទ្រិច និង/ឬ បញ្ជីផ្ទៀងផ្ទាត់សកម្មភាពជាក់ស្តែង នឹងត្រូវបានរៀបចំដោយទីប្រឹក្សា PIC-ECCE នៅក្នុងត្រីមាសទី 1។

  - ➢ ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ នឹងត្រូវរៀបចំផ្តល់ឲ្យតាមខេត្តនិមួយៗ សម្រាប់ស្មៀនឃុំ សង្កាត់ អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ និង ជំនួយការរដ្ឋបាលឃុំ សង្កាត់ ទាំងអស់ មកពីឃុំ សង្កាត់ថ្មីនៅសល់ទាំងអស់។ ការបណ្តុះបណ្តាលនេះ នឹងរៀបចំធ្វើក្នុងអំឡុងត្រីមាសទី 1 ដោយក្រុមសម្របសម្រួលថ្នាក់ក្រុង ស្រុក (DFT) ដោយមានការគាំទ្រពីក្រុមសម្របសម្រួលថ្នាក់ខេត្ត និង ទីប្រឹក្សាហិរញ្ញវត្ថុថ្នាក់ខេត្ត (LGFSA)។

- ការបណ្តុះបណ្តាលពីនិតិវិធីពិនិត្យតាមដាន វាយតម្លៃ និងរាយការណ៍ពីគម្រោង នឹងត្រូវរៀបចំក្នុងអំឡុងត្រីមាសទី 1 ដោយទីប្រឹក្សាគ្រប់គ្រងគម្រោងថ្នាក់ខេត្ត (PPMAs) តាមខេត្តគោលដៅនិមួយៗ។
- ការបណ្តុះបណ្តាលពីការត្រួតពិនិត្យតាមដាន និងណែនាំលើគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ នឹងត្រូវផ្តល់ឲ្យមន្ត្រីគាំទ្របច្ចេកទេស (TSOs) ថ្នាក់ក្រុង ស្រុក ក្នុងអំឡុងត្រីមាសទី 1 និងទី 3 ដោយវិស្វករហេដ្ឋារចនាសម្ព័ន្ធជនបទ ដោយមានជំនួយពីក្រុមសម្របសម្រួលថ្នាក់ខេត្ត និង ក្រុមសម្របសម្រួលថ្នាក់ក្រុង ស្រុក។
- ការបណ្តុះបណ្តាលពីការត្រួតពិនិត្យតាមដាន និងណែនាំលើគម្រោងកែលម្អជីវភាព នឹងត្រូវផ្តល់ឲ្យសមាជិកក្រុមគាំទ្រថ្នាក់ក្រុង ស្រុកទាំងអស់ ក្នុងអំឡុងត្រីមាសទី 2 និងទី 3 ដោយទីប្រឹក្សាផ្សព្វផ្សាយកសិកម្មខេត្ត (PAEAs) ដោយមានជំនួយពីអ្នកសម្របសម្រួលកសិកម្មខេត្តនិមួយៗ។

(e) **ទស្សនៈកិច្ចសិក្សា**

- ✓ មានទស្សនៈកិច្ចសិក្សាក្នុងប្រទេសចំនួន 8 នឹងត្រូវរៀបចំក្នុងឆ្នាំ 2014 ៖
  - ក្រោមសមាសភាគទី 1 នឹងមានទស្សនកិច្ចសិក្សា ត្រូវបានរៀបចំសម្រាប់ក្រុមថ្នាក់ក្រោមជាតិ ដើម្បីទទួលបានបទពិសោធន៍ស្តីពីយន្តការសម្រាប់ការកែលម្អជីវភាព និងការចងក្រងក្រុមសន្សំ ដែលបានគាំទ្រដោយគម្រោងផ្សេងទៀត។
  - ក្រោមសមាសភាគទី2 នឹងមានទស្សនកិច្ចសិក្សា សម្រាប់ក្រុមថ្នាក់ក្រោមជាតិ ដោយផ្តោតលើវិធានការណ៍/សកម្មភាពសម្របនឹងបម្រែបម្រួលអាកាសធាតុ ដែលកំពុងអនុវត្តបានជោគជ័យក្នុងខេត្តផ្សេងទៀត។

- ✓ ទស្សនកិច្ចសិក្សាក្រៅប្រទេសមួយ នឹងត្រូវរៀបចំដើម្បីសង្កេតដកពិសោធន៍ពីការផ្សព្វផ្សាយបញ្ចូលវិធានការណ៍ GAP ក្នុងតំបន់អាស៊ាន។ ទស្សនកិច្ចសិក្សានេះ នឹងធ្វើនៅប្រទេសម៉ាឡេស៊ី ឬ ប្រទេសហ្វីលីពីន ហើយនឹងគ្រោងជាបឋមសម្រាប់សមាជិកក្រុមការងាររបស់ MAFF/GDA និងបុគ្គលិកថ្នាក់ក្រោមជាតិមួយចំនួន ដែលបានចូលរួមក្នុងការអនុវត្តសាកល្បង GAP។ លក្ខខ័ណ្ឌយោងលម្អិតមួយសម្រាប់ទស្សនកិច្ចនេះ នឹងត្រូវបានរៀបចំដោយ GDA ដោយមានការគាំទ្រពីក្រុមទីប្រឹក្សាអនុវត្តគម្រោង ដើម្បីសុំការយល់ព្រមពី ADB មុននឹងចាប់ផ្តើមអនុវត្ត។
- ✓ ទស្សនកិច្ចសិក្សាក្រៅប្រទេសមួយ នឹងត្រូវបានរៀបចំសម្រាប់ប្រធានក្រុមកសិករផលិតស្រូវពូជ និង សមាជិកថ្នាក់ក្រោមជាតិមួយចំនួន ទៅប្រទេសវៀតណាម ដើម្បីមើលដកពិសោធន៍កម្មវិធីផលិតស្រូវពូជលក់ជាក្រុម។ លក្ខខ័ណ្ឌយោងលម្អិតមួយសម្រាប់ទស្សនកិច្ចនេះ នឹងត្រូវបានរៀបចំដោយ GDA ដោយមានការគាំទ្រពីក្រុមទីប្រឹក្សាអនុវត្តគម្រោង ដើម្បីសុំការយល់ព្រមពី ADB មុននឹងចាប់ផ្តើមអនុវត្ត។
- ✓ ទស្សនៈកិច្ចក្រៅប្រទេសមួយនឹងត្រូវរៀបចំសម្រាប់ប្រធានគ្រប់គ្រងគម្រោង និងមន្ត្រីសម្របសម្រួលគម្រោងថ្នាក់ជាតិនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដែលគាំទ្រដោយ IFAD។

### C.5.3 បង្កើត និងគាំទ្រឲ្យដំណើរការប្រព័ន្ធពិនិត្យតាមដានគុណផលអនុវត្តគម្រោង (PPMS)

22. ការអង្កេតដើមគ្រា នឹងត្រូវធ្វើចប់ ហើយលទ្ធផលរកឃើញ នឹងត្រូវប្រើសម្រាប់កែលម្អខ្លឹមសាររបស់ប្រព័ន្ធពិនិត្យតាមដានគុណផលអនុវត្តគម្រោង (PPMS) តាមរយៈការរួមបញ្ចូលនូវរង្វាស់សូចនាករដើមគ្រា នៅកម្រិតផលប្រែប្រួល និងកម្រិតលទ្ធផល។ ប្រព័ន្ធ PPMS នឹងត្រូវបានធ្វើបច្ចុប្បន្នភាព ផ្អែកលើមាតិកានៃផែនការសកម្មភាព និងថវិកាឆ្នាំ 2014 ដើម្បីឆ្លុះបញ្ចាំងពីសកម្មភាពថ្មីៗ ដែលមានបញ្ចូល។ ដំណើរការកសាងផែនការតាមបែបចូលរួម នឹងត្រូវធ្វើឡើងវិញ សម្រាប់ការរៀបចំកសាងផែនការសកម្មភាព និងថវិកាឆ្នាំ 2015។ សេវាកម្មទីប្រឹក្សា នឹងត្រូវបានផ្តល់សម្រាប់គាំទ្រដល់ភ្នាក់ងារប្រតិបត្តិ/ភ្នាក់ងារអនុវត្ត ក្នុងការអនុវត្តគម្រោង។

23. សកម្មភាពចំបងៗ មានដូចជាៈ

**(a) ការសិក្សាទិន្នន័យដើមគ្រា**

- ✓ ការអនុវត្តការអង្កេតទិន្នន័យដើមគ្រា បានចាប់ផ្តើមហើយ, ក្រោមការត្រួតពិនិត្យពីក្រុមការងារ NCDDS ដោយមានការគាំទ្រពីទីប្រឹក្សា PIC-RCLIE។ ក្រុមហ៊ុន SBK ដែលទទួលកិច្ចការនេះ បានចាប់ផ្តើមសកម្មភាព ហើយបានជូនរបាយការណ៍ចាប់ផ្តើមការងារ នៅចុងខែ វិច្ឆិកា ឆ្នាំ 2013។ ការបណ្តុះបណ្តាលដល់អ្នកចុះប្រមូលទិន្នន័យ ហើយការធ្វើតេស្តសាកល្បងផ្ទាល់បញ្ជីសំណួរ ត្រូវបានធ្វើចប់នៅចុងខែធ្នូ ឆ្នាំ 2013។ ការចុះអង្កេត/ការសម្ភាស នឹងចាប់ផ្តើមនៅដើមខែមករា។ សេចក្តីព្រាងទីមួយនៃរបាយការណ៍អង្កេតទិន្នន័យដើមគ្រានេះ នឹងរៀបចំបញ្ចប់នៅចុងខែកុម្ភៈ ឆ្នាំ 2014 ហើយបន្ទាប់មក (ពាក់កណ្តាលខែ មីនា) នឹងមានរៀបចំសិក្ខាសាលាពិគ្រោះយោបល់មួយ ដើម្បីបង្ហាញលទ្ធផលអង្កេតដែលបានរកឃើញ ហើយ របាយការណ៍ចុងក្រោយ នឹងដាក់ជូន នៅចុងខែមីនា។

**(b) ការប្រើប្រាស់ប្រព័ន្ធពិនិត្យតាមដានគុណផលអនុវត្តគម្រោង (PPMS)**

- ✓ ប្រព័ន្ធ PPMS នឹងត្រូវបានធ្វើបច្ចុប្បន្នភាពដោយក្រុមទីប្រឹក្សាអនុវត្តគម្រោង (PIC) ហើយនឹងមានការរៀបចំការបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ប្រព័ន្ធនេះ សម្រាប់វាស់វែងសូចនាករ ដែលបានកំណត់សម្រាប់សកម្មភាពទាំងអស់របស់គម្រោង ក៏ដូចជា សម្រាប់លទ្ធផល និងផលប្រែប្រួលសម្រាប់សមាសភាគនិមួយៗ។ ការបណ្តុះបណ្តាលនេះ នឹងត្រូវរៀបចំក្នុងត្រីមាសទី 1 ដោយក្រុមទីប្រឹក្សា PIC តាមរយៈសិក្ខាសាលាតាមខេត្តនិមួយៗ ដែលនឹងត្រូវចូលរួមដោយសមាជិកក្រុមការងារថ្នាក់ក្រុង ស្រុកទាំងអស់។ ក្នុងអំឡុងពេលនៃការបណ្តុះបណ្តាលនេះ នឹងមានការកែតម្រូវកាន់តែប្រសើរឡើងថែមទៀត នូវទម្រង់ប្រើសម្រាប់របាយការណ៍វឌ្ឍនភាពគម្រោងប្រចាំត្រីមាស។

**(g) សិក្ខាសាលាកសាងផែនការថ្នាក់ជាតិ**

- ✓ ការរៀបចំឯកសារផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ 2015 នឹងអនុវត្តតាមដំណើរការបែបមានការចូលរួម ដូចបានធ្វើកន្លងមក តាមរយៈការធ្វើសិក្ខាសាលាកសាងផែនការថ្នាក់ក្រុង ស្រុក និងថ្នាក់ខេត្ត ដូចក្នុងករណី ឆ្នាំ 2014 ដែរ។ សិក្ខាសាលាធ្វើផែនការថ្នាក់ខេត្ត នឹងត្រូវបានរៀបចំក្នុងខេត្តនិមួយៗ ដើម្បីបូកសរុបលទ្ធផលសិក្ខាសាលាផែនការថ្នាក់ក្រុង ស្រុក ដើម្បីចងក្រងបានជាផែនការថ្នាក់ខេត្ត។ ការឆ្លុះបញ្ចាំងដកពិសោធន៍ការអនុវត្ត នឹងជាផ្នែកមួយនៃកម្មវិធីសិក្ខាសាលារៀបចំផែនការតាមថ្នាក់និមួយៗនេះ។ ការបូកសរុបសំយោគផែនការការងារថ្នាក់ខេត្ត នឹង

ត្រូវដឹកនាំធ្វើដោយក្រុមទីប្រឹក្សាអនុវត្តគម្រោង ដោយសហការជាមួយក្រុមបុគ្គលិកគម្រោង តាមភ្នាក់ងារអនុវត្តនិមួយៗ។ សិក្ខាសាលាកសាងផែនការប្រចាំឆ្នាំថ្នាក់ជាតិ នឹងត្រូវរៀបចំធ្វើក្នុងត្រីមាសទី 4 ដើម្បីឲ្យសេចក្តីព្រៀងចុងក្រោយនៃឯកសារផែនការសកម្មភាព និងថវិកាឆ្នាំ (AWPB) សម្រាប់ឆ្នាំ 2015 អាចដាក់ជូនបានទាន់ពេល ទៅ ADB ដើម្បីចៀសវាងការពន្យារពេលចាប់ផ្តើមអនុវត្តសកម្មភាព ក្នុងឆ្នាំបន្ទាប់។

**(h) សេវាកម្មទីប្រឹក្សាសម្រាប់គាំទ្រផ្នែកបច្ចេកទេស និងផ្នែកគ្រប់គ្រងគម្រោង**

- ✓ កិច្ចសន្យាការងាររបស់ទីប្រឹក្សាថ្នាក់ខេត្ត (PPMAs, LGFSAs and PAEAs) បានបន្តរួចហើយ ហើយករណីដូចគ្នានេះដែរ ក៏បានធ្វើសម្រាប់ទីប្រឹក្សាថ្នាក់ជាតិទាំងពីរ ប្រចាំការនៅ NCDDS។ នឹងមានទីប្រឹក្សាពេញម៉ោងម្នាក់ទៀត ជ្រើសរើសដោយ NCDDS ដែលនឹងទទួលខុសត្រូវរៀបចំបង្កើត និង ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យ (ជាតាបេស) សម្រាប់គ្រប់សកម្មភាពក្រោមមូលនិធិ CDF ទាំងអស់ (គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ, សកម្មភាពកែលម្អជីវភាពរបស់ក្រុមមានចំណាប់អារម្មណ៍ដូចគ្នា និង ទុនបង្វិលក្រុម។ លក្ខខ័ណ្ឌយោងការងារ សម្រាប់តំណែងនេះ នឹងត្រូវបានរៀបចំដោយ NCDDS ហើយដាក់សុំការយល់ព្រមពី ADB មុនចាប់ផ្តើមដំណើរការជ្រើសរើស។
- ✓ ទីប្រឹក្សាបច្ចេកទេសអន្តរជាតិសម្រាប់ការងារ GAP នឹងមកបំពេញការងារពីរដងទៀត ក្នុងត្រីមាសទី 1 ដើម្បីបញ្ចប់ការងាររបស់គាត់។ កម្មវិធីការងារនេះ ត្រូវបានរៀបចំអនុលោមតាមជំហ៊ាន និងវឌ្ឍនភាពរបស់សាលារៀនស្រែ-ចំការកសិករចំនួនបួន ដែលកំពុងបានអនុវត្តសម្រាប់ក្រុមកសិករចំនួនបួន ក្នុងខេត្តសៀមរាប។
- ✓ នឹងមានទីប្រឹក្សាអន្តរជាតិ និង ជាតិ (ម្នាក់ៗ មានពេល បួនខែ) ជ្រើសរើសដោយ MAFF/DCU ដើម្បីគាំទ្រដល់ MAFF-GDA ក្នុងការរៀបចំទស្សនវិស័យផលិតកម្មដំណាំនៅកម្ពុជា នៅឆ្នាំ 2030។ លក្ខខ័ណ្ឌយោងការងារលម្អិតសម្រាប់តំណែងទាំងពីរ នឹងត្រូវរៀបចំ ដោយមានជំនួយពីក្រុមទីប្រឹក្សា PIC និងដាក់ជូនសុំការយល់ព្រមជាមុនពី ADB មុននឹងដំណើរការជ្រើសរើស ។ ទីប្រឹក្សាទាំងពីរ គ្រោងនឹងចាប់ដំណើរការងារនៅត្រីមាសទី 2។[18]
- ✓ នឹងមានទីប្រឹក្សារហូតដល់បីនាក់ ត្រូវបានជ្រើសរើសជាលក្ខណៈបុគ្គលដាច់ៗគ្នាដោយ NCDDS សម្រាប់ពេលវេលាសរុបចំនួន 15 នាក់-ខែ ធ្វើការក្រោមការណែនាំរបស់ទីប្រឹក្សា PIC-RCLIE ដើម្បីដឹកនាំការរៀបចំ និងអនុវត្តផែនការធុរកិច្ចតេលេស៊ិនធ័រ។
- ✓ ក្រុមទីប្រឹក្សា PIC នឹងបន្តជួយគាំទ្រក្នុងឆ្នាំនេះ សម្រាប់គ្រប់សមាសភាគទាំងអស់របស់គម្រោង និង សម្រាប់ភ្នាក់ងារអនុវត្តនិមួយៗ។

## D. ការរៀបចំចាត់ចែងផ្នែកស្ថាប័ន

24. ក្នុងអំឡុងឆ្នាំ 2013, បុគ្គលិកបន្ថែមត្រូវបានជ្រើសរើស ដើម្បីជួយក្នុងការអនុវត្តគម្រោង។ បុគ្គលិកទាំងនេះ រួមមានបុគ្គលិកឃុំបន្ថែម រួមមាន ជំនួយការបច្ចេកទេសឃុំ សង្កាត់ចំនួន 21 នាក់ និងអ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់/ ជំនួយការរដ្ឋបាលឃុំ សង្កាត់សម្រាប់ឃុំ សង្កាត់ថ្មីចំនួន 92 ហើយនិង ជំនួយការរដ្ឋបាល-ហិរញ្ញវត្ថុ ធ្វើការជាមួយអ្នកសម្របសម្រួល

[18] ការពិភាក្សាថែមទៀត នឹងត្រូវធ្វើដោយ DCU ជាមួយនឹង ADB ដើម្បីបញ្ជាក់ពីថវិកាដែលមានសម្រាប់ទីប្រឹក្សាទាំងពីរនេះ។

កសិកម្មខេត្ត។ ក្រុម NiDA នឹងបញ្ចប់ការងារជាមួយគម្រោងនៅចុងត្រីមាសទី 1 ហើយការគាំទ្រសម្រាប់លទ្ធផល 2.3 នឹងត្រូវផ្តល់ឲ្យតាមរយៈ NCDDS។ ភ្នាក់ងារប្រតិបត្តិ និង ភ្នាក់ងារអនុវត្ត នឹងជួយរៀបចំបេសកកម្មពិនិត្យវាយតម្លៃវឌ្ឍនភាពរបស់ ADB ដែលគ្រោងជាបណ្តោះអាសន្ននៅដើម-ពាក់កណ្តាលខែកុម្ភៈ ឆ្នាំ 2014 ដែលនឹងពិនិត្យមើលពីតម្រូវការបុគ្គលិករដ្ឋាភិបាល និង ទីប្រឹក្សាជំនួយបច្ចេកទេស។

25. ភ្នាក់ងារអនុវត្តនិមួយៗ នឹងរក្សានូវក្រុមបុគ្គលិកមានស្រាប់សម្រាប់ចូលរួមអនុវត្តគម្រោង ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ។ យ៉ាងណាក្តី សម្រាប់ក្រុមមន្ត្រី DCU នឹងមានការពិចារណាបន្ថែមទៀតលើការរើសបុគ្គលិកបន្ថែមចំនួនពីររូបសម្រាប់ទទួលខុសត្រូវថែរក្សា(ជួសជុស និងធ្វើបច្ចុប្បន្នភាព)វេបសាយរបស់គម្រោង TSSD។[19] ចំណុចនេះ នឹងត្រូវបានប៉ាន់ ប្រមាណក្នុងអំឡុងពេលបេសកកម្មពិនិត្យវឌ្ឍនភាពគម្រោងរៀងរាល់ឆមាស ដែលគ្រោងនៅខែ កុម្ភៈ ឆ្នាំ 2014 ខាងមុននេះ។

## E. លទ្ធកម្ម

26. ប្រភេទកិច្ចសន្យាខាងក្រោមនេះ នឹងត្រូវធ្វើក្នុងអំឡុងឆ្នាំ 2014 នេះ។ ប្រភេទកិច្ចសន្យាទាំងនេះ អាចសង្ខេបបានដូចខាងក្រោម៖[20]

- **សេវាកម្មទីប្រឹក្សា**
  - ជ្រើសរើសសេវាករ សម្រាប់គាំទ្រការពង្រឹងសមត្ថភាព និងការណែនាំដល់ក្រុម LIGs (SSP2).
  - ជ្រើសរើសសេវាករសម្រាប់កម្មវិធីសុខភាព និងផលិតកម្មសត្វ (SSP3).
  - ជ្រើសរើសសេវាករដោយ NCDDS សម្រាប់ផ្តល់ការបណ្តុះបណ្តាលជំនាញ/បំនិនបច្ចេកទេស (ការសម្របសម្រួល; ការប្រាស្រ័យទាក់ទង; វិធីសាស្ត្រផ្សព្វផ្សាយ; ផលិតកម្មដំណាំ សត្វ និង វារីវប្បកម្ម) សម្រាប់អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់។
  - ជ្រើសរើសទីប្រឹក្សាឯកត្តជនថ្នាក់ជាតិ 01រូប សម្រាប់ធ្វើអង្កេតទីផ្សារ/GAP សម្រាប់បន្លែ និងផ្លែឈើ នៅខេត្តសៀមរាប - ក្នុងត្រីមាសទី 1 (ដោយ MAFF/DCU)។
  - ជ្រើសរើសទីប្រឹក្សាអន្តរជាតិ និងជាតិ ដោយ MAFF/DCU សម្រាប់ជួយ GDA រៀបចំទស្សនវិស័យផលិតកម្មដំណាំកម្ពុជា នៅឆ្នាំ 2030។
  - ជ្រើសរើសសេវាករសម្រាប់ផលិតខ្សែវីដេអូបណ្តុះបណ្តាល និង ខ្លឹមសារពហុ-មេដ្យានានា - ដោយ NCDDS.
  - ជ្រើសរើសទីប្រឹក្សាជាតិឯកត្តជន 01រូប ដោយ NCDDS ដើម្បីដឹកនាំការរៀបចំ និងអនុវត្តផែនការធុរកិច្ចរបស់តេលេស៊ិនធ័រ។

---

[19] ចំនួនបុគ្គលិកសហការរបស់រដ្ឋាភិបាល មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងមិនកើនឡើងទេ ប៉ុន្តែនឹងការកែប្រែ/ផ្លាស់ប្តូរមុខតំណែងចំនួនពីរ ក្នុងចំណោមមុខតំណែងដែលមានស្រាប់។

[20] ផែនការលទ្ធកម្មលម្អិត មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ 4

- បន្តកិច្ចសន្យាទីប្រឹក្សាថ្នាក់ជាតិ និងថ្នាក់ខេត្ត ដែលជ្រើសរើសដោយ MAFF/DCU និង NCDDS និងជ្រើសរើសជំនាញការជាតិឯកត្តជន 01រូប ផ្នែក IT/Database or MIS - ដោយ NCDDS.

- **ទំនិញ/សម្ភារៈ និងការងារសាងសង់ មានតម្លៃតិចជាង 1 លានដុល្លារសហរដ្ឋអាមេរិក.**[21]
  - គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ (ក្រោមមូលនិធិ CDF) នឹងរួមបញ្ចូលនូវចំនួនកិច្ចសន្យាមួយៗ ជាច្រើន ដែលចុះកិច្ចសន្យាដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយអនុវត្តតាមសៀវភៅ C/S PIM (version 2009) ដោយរួមបញ្ចូល/អនុវត្តតាមខ្លឹមសារធ្វើវិសោធនកម្ម បន្តបន្ទាប់មក។
  - ជួសជុសស្ថានីយ៍ស្រាវជ្រាវ បល្ល័ង្ក និង ស្ថានីយ៍ស្រាវជ្រាវ ទឹកវិល នឹងធ្វើតាមរយៈការចុះកិច្ចសន្យាដោយ MAFF/DCU ដោយប្រើនិតិវិធីលទ្ធកម្ម NCB បន្ទាប់ពីទទួលបានការយល់ព្រមជាមុនដោយ ADB លើផែនការធុរកិច្ច និង គ្រោងការ/ថវិកាប៉ាន់ស្មាន សម្រាប់ស្ថានីយ៍និមួយៗ។ កិច្ចសន្យា បានធ្វើសម្រាប់ស្ថានីយ៍បល្ល័ង្ក ហើយការសាងសង់ នឹងចាប់ផ្តើមនៅដើមត្រីមាសទី 1។ ការដេញថ្លៃឡើងវិញ នឹងត្រូវធ្វើសម្រាប់ស្ថានីយ៍ ទឹកវិល បន្ទាប់ពីការកែសម្រួលតម្លៃប៉ាន់ស្មាន ដោយ ADB។
  - លទ្ធកម្ម កុំព្យូទ័រ desktop សម្រាប់ CARD - ដោយ MAFF/DCU។
  - បោះពុម្ពសៀវភៅបណ្តុះបណ្តាលស្តីពី GAP - ដោយ MAFF/DCU។
  - សាងសង់បរិក្ខារស្តុក/ទុកដាក់គ្រាប់ពូជស្រូវ សម្រាប់ក្រុមកសិករផលិតពូជស្រូវ នឹងត្រូវធ្វើតាមរយៈកិច្ចសន្យារួម (សម្រាប់គ្រប់ក្រុម) ដែលផ្តល់ឲ្យដោយ MAFF/DCU បន្ទាប់ពីមានការយល់ព្រមជាមុនលើគ្រោងរចនាឃ្លាំង (បន្តមកពីឆ្នាំ 2013) - ក្នុងត្រីមាសទី 1 (ដោយ MAFF/DCU).
  - លទ្ធកម្មគ្រាប់ពូជស្រូវអនុញ្ញាតិ សម្រាប់ផ្តល់ជាគ្រាប់ពូជធ្វើដើមទុន សម្រាប់ក្រុមកសិករផលិតពូជស្រូវបានជ្រើសរើសឆ្នាំ 2013 សម្រាប់ឲ្យកសិករបានចូលរួមក្នុងកម្មវិធីសាលារៀនស្រែកសិករផលិតពូជស្រូវ - ទិញពីស្ថានីយ៍ស្រាវជ្រាវ។
  - លទ្ធកម្មឧបករណ៍វាស់សំណើមគ្រាប់ដំណាំ និង ឧបករណ៍វាស់ប៉េហាស់ដី សម្រាប់ក្រុម DST - ដោយ MAFF/DCU.
  - បោះពុម្ពឯកសារផ្សព្វផ្សាយស្តីពីការចិញ្ចឹមជ្រូកមេ និង វិធីសាស្រ្តផ្សព្វផ្សាយ - ដោយ NAFF/DCU.
  - លទ្ធកម្មផ្ទាំងកញ្ចក់អគ្គិសនីស្រូបពន្លឺព្រះអាទិត្យ (សូល៉ែរ) សម្រាប់សាលាឃុំ សង្កាត់ក្នុងតំបន់គ្មានភ្លើងអគ្គិសនី - ដោយ NCDDS.

---

[21] បន្ទាប់ពីទទួលបានអនុលោមភាពលើផែនការសកម្មភាព និងថវិកាឆ្នាំហើយ ភ្នាក់ងារប្រតិបត្តិ នឹងរៀបចំផែនការលទ្ធកម្មបានធ្វើបច្ចុប្បន្នភាពមួយ ដោយប្រើទម្រង់ស្តង់ដារ ដើម្បីដាក់ជូន ADB សម្រាប់សកម្មភាពត្រូវការធ្វើបន្តទៀត។

- លទ្ធកម្មឧបករណ៍អាយស៊ីធី សម្រាប់ការិយាល័យក្រុមប្រឹក្សាឃុំ សង្កាត់ (laptop computer, printer, UPS និង Modem) - ដោយ NCDDS.
- លទ្ធកម្មតុ កៅ-អី សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ សម្រាប់ប្រើប្រាស់ដោយ CEW/CAA - ដោយ NCDDS.
- លទ្ធកម្មឧបករណ៍ផ្តល់ព័ត៌មានចល័ត សម្រាប់អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ (បន្តពីឆ្នាំ 2013) - ដោយ NiDA.

## ឧបសម្ព័ន្ធ 21: ក្របខ័ណ្ឌតាមដាន និងត្រួតពិនិត្យគម្រោង

Design and Monitoring Framework (DMF)

| សង្ខេបពីគ្រោងការរបស់គម្រោង | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | ការសន្មត់ / ហានិភ័យ |
|---|---|---|---|
| **ផលប៉ះពាល់** | | | |
| **កម្រិតជីវភាពរបស់កសិករប្រមាណ 630.000 គ្រួសារក្នុងខេត្តបួន ក្នុងតំបន់អាងបឹងទន្លេសាប នឹងត្រូវបានកែលម្អនៅឆ្នាំ 2020** | - ចំនួនខែខ្វះខាតស្បៀងក្នុងមួយឆ្នាំ នៅតាមឃុំគោលដៅនឹងត្រូវកាត់បន្ថយពី 3 ខែ ក្នុងឆ្នាំ 2008 មកត្រឹម 1ខែ ក្នុងឆ្នាំ 2020 ។<br>- ចំនួនគ្រួសារក្រីក្រកម្រិត-2 នឹងត្រូវកាត់បន្ថយ 50% ក្នុងឃុំគោលដៅ នៅឆ្នាំ 2020។ | ស្ថិតិប្រចាំឆ្នាំរបស់ឃុំ<br><br>ការអង្កេតតាមរយៈសំណាក | **ការសន្មត់**<br><br>ស្ថេរភាពនយោបាយ និង ការអនុវត្តគម្រោងនៅមានបន្តទៀត ហើយពិសេសទៀត ត្រូវមានផ្លូវដឹកជញ្ជូន និងបណ្ដាញ អគ្គិសនី |
| **ផលប្រែប្រួល** | | | |
| បង្កើនផលិតភាពកសិកម្ម និងកែលម្អលទ្ធភាពអាចលក់កសិផលរបស់កសិករ ពីឃុំគោលដៅចំនួន196 ក្នុងខេត្តទាំងបួន ក្នុងតំបន់អាងបឹងទន្លេសាប | - ជាមធ្យមទិន្នផលស្រូវក្នុងឃុំគោលដៅ នឹងកើនឡើងលើសពី 3,5 តោន/ហត នៅឆ្នាំ 2017 (ទិន្នផលជាមធ្យមនៅ កម្ពុជា ឡាវ ថៃ និងវៀតណាម គឺ 3,4 តោន/ហត ឆ្នាំ 2007)<br>- ការអនុវត្តប្រព័ន្ធផលិតកម្មពិពិធកម្ម/ចម្រុះ កាត់បន្ថយចំណូលគ្រួសារបានពីស្រូវចំនួន 20%។<br><br>- កសិផល និង ផលិតផលកសិដ្ឋានលក់បាន បាន | ការស្ទង់ទិនិន្នផល តាមការយកសំណាកផលស្រូវតាមវិធីសាស្ត្ររបស់ អង្គការ FAO<br><br>ស្ថិតិមន្ទីរកសិកម្មខេត្ត<br><br>អង្កេតតាមគ្រួសារ និងតាមឃុំ | **ការសន្មត់**<br><br>មានការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការគាំទ្រគម្រោង<br><br>រដ្ឋាភិបាលកម្ពុជា ADB, IFAD, GOF |

| សង្ខេបពីគ្រោងការរបស់គម្រោង | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | ការសន្មត់ / ហានិភ័យ |
|---|---|---|---|
| | កើនឡើង 25%<br>- ការចូលរួមក្នុងសកម្មភាពកែលម្អជីវភាពរបស់ក្រុមគ្រួសារក្រីក្រ និងក្រីក្របំផុត ដោយរួមទាំងគ្រួសារដែលមានស្ត្រីជាមេគ្រួសារផង បានកើនឡើងយ៉ាងតិច 10% ខ្ពស់ជាងភាគរយរបស់គេក្នុងប្រជាករ ក្នុងឃុំគោលដៅ ។<br>- សមាជិកក្រុម LIG ច្រើនជាង 70% បានរៀនចប់បច្ចេកទេសកែលម្អជីវភាព ហើយមានលក្ខណៈ សមស្រប អាចមានសិទ្ធិទទួលបានសេវាកម្មឥណទានជាផ្លូវការបាន | សង្កាត់<br><br>កំណត់ត្រាក្រុម LIG ក្នុងឃុំសង្កាត់គោលដៅរបស់គម្រោង | ផ្តល់មូលនិធិ ឲ្យទាន់ពេល ដូចដែលបានគ្រោងទុក សម្រាប់បញ្ចប់គម្រោង<br><br>**ហានិភ័យ**<br><br>អាកាសធាតុមិនអំណោយផល និងការកើតមានជម្ងឺ។ |
| **សមាសភាគ/លទ្ធផល** | | | |
| 1. **ការអភិវឌ្ឍឃុំ-សង្កាត់ តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ (កញ្ចប់ថវិកាជំនួយឥតសំណងឃុំ)** | | | |
| ការអភិវឌ្ឍសហគមន៍តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ (កញ្ចប់ថវិកាឃុំ)<br><br>1.1. កែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ<br><br>1.2. បង្កើនសមត្ថភាពកសិករខ្នាតតូច | - កញ្ចប់ថវិកាឃុំ នឹងត្រូវបានផ្តល់ឲ្យ ទាំង 196 ឃុំសង្កាត់ហើយអាចប្រតិបត្តិការ នៅត្រីមាសទី 1 ឆ្នាំ 2013<br>- កែលម្អផ្លូវលំជនបទប្រវែង 90គីឡូម៉ែត្រ និងប្រព័ន្ធស្រោចស្រពដែលអាចគ្របដណ្តប់ផ្ទៃដីដាំដុះបាន 2.500 ហិចតា នៅតាមឃុំ សង្កាត់គោលដៅ<br>- បង្កើតក្រុម LIG ចំនួន 1.200 ដែលក្រុមទាំងនេះអាចទទួលបានសេវាកម្មផ្សព្វផ្សាយ គ្រាប់ពូជមាន | របាយការណ៍ក្រុមប្រឹក្សាឃុំសង្កាត់<br><br>របាយការណ៍វឌ្ឍនភាពត្រីមាស<br><br>របាយការណ៍ឃុំ សង្កាត់ | **ការសន្មត់**<br><br>បន្តកំណែទម្រង់គោលនយោបាយវិមជ្ឈការ និង សហវិមជ្ឈការ ដើម្បីគាំទ្រផែនការអភិវឌ្ឍន៍ និងវិនិយោគឃុំសង្កាត់ |

| សង្ខេបពីគ្រោងការរបស់គម្រោង | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | ការសន្មត់ / ហានិភ័យ |
|---|---|---|---|
| 1.3. បង្កើនសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ លើការគ្រប់គ្រងគម្រោង | គុណភាពល្អ និងហិរញ្ញវត្ថុ (តាមរយៈទុនបង្វិល និង/ឬ ខ្ចីឥណទានពីមីក្រូហិរញ្ញវត្ថុ)<br>- 70% នៃក្រុម LIG ទាំងអស់ អាចដំណើរការបានពេញលេញ ហើយ 50%នៃប្រាក់កម្ចីជនបទ ត្រូវបានខ្ចីដោយស្ត្រី នៅឆ្នាំ 2014<br>- កិច្ចប្រជុំប្រចាំសប្តាហ៍ថ្នាក់ក្រុង ស្រុក និងប្រចាំខែថ្នាក់ខេត្ត បានរៀបចំដើម្បីផ្តល់ការគាំទ្រ និងតាមដានបានទាន់ពេល ដើម្បីជៀសវាង ការយឺតយ៉ាវក្នុងការអនុវត្តគម្រោង និង/ឬ លំហូរថវិកា | របាយការណ៍វឌ្ឍនភាពត្រីមាស<br><br>របាយការណ៍អង្កេត<br><br>របាយការណ៍វឌ្ឍនភាពត្រីមាស | **ហានិភ័យ**<br><br>ឃុំ សង្កាត់អនុវត្តការងារមិនបានល្អ នឹងធ្វើឲ្យប៉ះពាល់មិនល្អ ដល់ផលប្រែប្រួលរបស់គម្រោង។<br><br>ការផ្លាស់ប្តូរតួនាទីនៅថ្នាក់ក្រោមជាតិ |
| 2. **ការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម** | | | |
| 2.1. បរិយាកាសគោលនយោបាយកសិកម្ម មានភាពល្អប្រសើរឡើង<br><br>2.2. បង្កើនលទ្ធភាពកសិករ ឲ្យអាចទទួលបានគ្រាប់ពូជមានគុណភាពល្អ | - រៀបចំឯកសារស្តីពីផលិតកម្មពូជស្រូវ និងបន្លែ ស្រូវ និង ផលិតកម្មសត្វ<br><br>- ផលិតស្រូវពូជសុទ្ធអនុញ្ញាតិចំនួន 100 តោន និងពូជបន្លែ 2 តោន<br>- ផលិតពូជស្រូវចំនួន 2.500 តោន និងពូជបន្លែចំនួន 15 តោន សម្រាប់ផ្គត់ផ្គង់/លក់<br>- ក្រុមកសិករចំនួន 40 នឹងក្លាយជាក្រុមផលិត និងផ្គត់ផ្គង់ពូជដំណាំមានគុណភាព<br>- អ្នកផ្សព្វផ្សាយឃុំចំនួន 196នាក់ បានបំពាក់បរិក្ខារ | | **ការសន្មត់**<br><br>ការគាំទ្ររបស់រដ្ឋាភិបាលក្នុងការ គាំទ្រគោលនយោបាយលើកកម្ពស់ផលិតភាពកសិកម្ម<br><br>**ហានិភ័យ**<br><br>ឥទ្ធិពលអាកាសធាតុមិនអំណោយ |

| សង្ខេបពីគ្រោងការរបស់គម្រោង | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | ការសន្មត់ / ហានិភ័យ |
|---|---|---|---|
| 2.3. ជួយកសិករ ឲ្យទទួលបាននូវ ព័ត៌មានកសិកម្ម និង ទិន្នន័យទីផ្សារ | ផ្តល់ព័ត៌មានចល័ត សម្រាប់ផ្សព្វផ្សាយ/ផ្តល់ព័ត៌មានកសិកម្ម និងទិន្នន័យទីផ្សារ។<br>- យ៉ាងតិចមាន មណ្ឌលព័ត៌មានកសិករជនបទ (តេលេស៊ិនធ័រ) ចំនួន 10 មានប្រតិបត្តិការប្រកបដោយនិរន្តរភាព។<br>- សមាជិកក្រុម DST/DFT ចំនួន 224នាក់ មានជំនាញប្រើកុំព្យូទ័រ ដើម្បីគាំទ្រអ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់<br>- ឯកសារវីដេអូ សម្រាប់បណ្តុះបណ្តាលស្តីពីបច្ចេកវិទ្យាកសិកម្មបានកែលម្អ ចំនួន 20 ប្រធានបទត្រូវបានផលិត។ | | ផល និងការផ្ទុះឡើងនៃជម្ងឺ |
| 3. **ការគ្រប់គ្រងគម្រោង ប្រកបដោយប្រសិទ្ធិភាព** | | | |
| | បញ្ចប់គម្រោងឲ្យទាន់ពេលវេលាក្នុងរង្វង់ថវិកាដែលបានកំណត់ | របាយការណ៍វឌ្ឍនភាពត្រីមាស<br><br>របាយការណ៍បេសកកម្មត្រួតពិនិត្យមើលវឌ្ឍនភាពគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី | **ការសន្មត់**<br><br>បុគ្គលិករដ្ឋដែលត្រូវបានចាត់តាំងឲ្យមកបំពេញការងារជាមួយគម្រោង មានសមត្ថភាព និង មានទឹកចិត្តធ្វើការងារ |

| សង្ខេបពីគ្រោងការរបស់គម្រោង | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | ការសន្មត់ / ហានិភ័យ |
|---|---|---|---|
| គោលសកម្មភាព | | | |
| <u>សមាសភាគទី 1</u>- **ការអភិវឌ្ឍឃុំ-សង្កាត់ តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ -សង្កាត់** | | | |
| **លទ្ធផល 1.1- កែលម្អហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់ផលិតភាពកសិកម្ម** | - កំណត់ និងបញ្ចូលគម្រោងហេដ្ឋារចនាសម្ព័ន្ធ ទៅក្នុងផែនការវិនិយោគឃុំ សង្កាត់<br>- ធ្វើការជាមួយស្ថាប័នពាក់ព័ន្ធថ្នាក់ខេត្ត ដើម្បីរៀបចំគំនូរប្លង់បច្ចេកទេស និងរៀបចំឯកសារសម្រាប់ដាក់ដេញថ្លៃ<br>- ពិនិត្យមើលសំណើដាក់ដេញថ្លៃ និង រៀបចំកិច្ចសន្យា<br>- ពិនិត្យតាមដាន និងត្រួតពិនិត្យការអនុវត្តការងាររបស់អ្នកម៉ៅការ និងរៀបចំទូទាត់ថវិកាផ្អែកលើលទ្ធផលការងារអនុវត្តបាន<br>- វាយតម្លៃគុណភាពការងារសាងសង់ ដែលបានបញ្ចប់<br>- រៀបចំទូទាត់ថវិកា(ដល់អ្នកទទួលការ) សម្រាប់គម្រោងដែលបានបញ្ចប់ដោយជោគជ័យ | | |
| **លទ្ធផល 1.2- បង្កើនសមត្ថភាពរបស់កសិករខ្នាតតូច** | - ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំង 196 អំពីការគ្រប់គ្រងគម្រោងសកម្មភាពកែលម្អជីវភាព<br>- ធ្វើការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន សម្រាប់តម្រង់ទិសការកំណត់សកម្មភាពជាអាទិភាពសម្រាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ (CDP/CIP)។<br>- ធ្វើការជាមួយកសិកម្មក្រុង ស្រុក ដើម្បីកំណត់ក្រុមកែលម្អជីភាព និង រៀបចំកម្មវិធីផ្សព្វផ្សាយចាំបាច់សម្រាប់ពួកគាត់<br>- កំណត់រកអង្គការក្រៅរដ្ឋាភិបាល និង/ឬ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសមស្រប និង រៀបចំអនុស្សារណៈយោគយល់គ្នាសម្រាប់ផ្តល់ការបណ្តុះបណ្តាល និង សេវាកម្ម។<br>- ពិនិត្យតាមដាន និងផ្តល់ការគាំទ្រ | | |
| **លទ្ធផល 1.3 - បង្កើនសមត្ថភាពឃុំ សង្កាត់លើការគ្រប់គ្រងគម្រោង** | - ឯកសារអនុវត្តគម្រោង (**ភីម**) ត្រូវបានបង្កើត ហើយកែសម្រួលចុងក្រោយ នៅខែតុលា ឆ្នាំ 2011<br>- កញ្ចប់ថវិកាឃុំ សង្កាត់ ត្រូវបានបង្កើតឡើង ហើយអ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ និងជំនួយការរដ្ឋបាលឃុំ សង្កាត់ត្រូវបានជ្រើសរើស នៅទូទាំង 196ឃុំ សង្កាត់នៅខែធ្នូ ឆ្នាំ 2012<br>- ផ្តល់ការបណ្តុះបណ្តាលអំពីភីម ដល់ឃុំ សង្កាត់ទាំង196 ត្រឹមខែធ្នូ ឆ្នាំ 2012<br>- សម្រួលជាប្រចាំជាមួយបុគ្គលិករដ្ឋពាក់ព័ន្ធ<br>- ពិនិត្យមើល/ណែនាំសកម្មភាពដែលអនុវត្តដោយក្រុមកែលម្អជីវភាព និងសេវាករ | | |

| សង្ខេបពីគ្រោងការរបស់គម្រោង | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | ការសន្មត់ / ហានិភ័យ |
|---|---|---|---|
| | - រៀបចំរបាយការណ៍វឌ្ឍនភាពគម្រោង | | |
| <u>សមាសភាគទី 2</u>- **បរិយាកាសអំណោយផលដល់ការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម** | | | |
| **លទ្ធផល 2.1- ធ្វើឲ្យគោលនយោបាយកសិកម្ម មានភាពល្អប្រសើរឡើង** | - កំណត់ពីវិសាលភាពការងារគោលនយោបាយ ដោយការសិក្សា-ពិនិត្យមើលពីសេចក្តីព្រាងឯកសារ ឬ គោលនយោបាយកសិកម្ម ដែលពាក់ព័ន្ធមានស្រាប់។<br>- រៀបចំចងក្រងឯកសារប្រតិបត្តិការការងារ ពាក់ព័ន្ធនានា។<br>- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីបញ្ចូលគំនិត/យោបល់ទទួលបានពីក្រសួង/ស្ថាប័ន និង អ្នកពាក់ព័ន្ធផ្សេងៗ សម្រាប់រៀបចំបញ្ចប់នូវឯកសារប្រតិបត្តិការការងារ របស់គម្រោង។ | | |
| **លទ្ធផល 2.2- បង្កើនលទ្ធភាពឲ្យកសិករទទួលបាននូវគ្រាប់ពូជប្រកបដោយគុណភាពល្អ** | - ប៉ាន់ប្រមាណ និងកំណត់ជ្រើសរើសក្រុមកសិករផលិតពូជ នៅខែមីនា ឆ្នាំ 2012<br>- ចាប់ដៃគូជាមួយស្ថានីយ៍ស្រាវជ្រាវ ដើម្បីផលិត និងផ្គត់ផ្គង់គ្រាប់ពូជដំណាំ<br>- ជ្រើសរើសពូជសមស្រប មានតម្រូវការទីផ្សារ ហើយបង្កើតយុទ្ធសាស្ត្រទីផ្សារ (រួមទាំង ការទុកដាក់ក្រោយប្រមូលផល និងការលក់)<br>- បង្កើនសមត្ថភាពដល់ក្រុមកសិករផលិតពូជ សម្រាប់ផលិត និងផ្គត់ផ្គង់ពូជ (រួមបញ្ចូលទាំងបច្ចេកទេសក្រោយប្រមូលផល)<br>- រៀបចំការធ្វើបង្ហាញបច្ចេកទេសកសិកម្ម ដើម្បីបង្កើនការយល់ដឹង/តម្រូវការពីពូជ និងធ្វើការអង្កេតមុន និងក្រោយប្រមូលផល ដើម្បីវាយតម្លៃពីកំណើនទិន្នផល<br>- ធ្វើលទ្ធកម្ម និងចែកចាយគ្រាប់ពូជដែលមានគុណភាពល្អ | | |
| **លទ្ធផល 2.3- ជួយឲ្យកសិករទទួលបានព័ត៌មានកសិកម្ម និង ទិន្នន័យទីផ្សារ** | - គាំទ្រកម្មវិធីផ្តល់ព័ត៌មានចល័តថ្នាក់ឃុំ សង្កាត់(MCA) តាមរយៈការធ្វើលទ្ធកម្មបរិក្ខារអាយស៊ីធីចល័ត និង ការបណ្តុះបណ្តាលអ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់។<br>- ផ្តល់ការបណ្តុះបណ្តាលជំនាញប្រើកុំព្យូទ័រជាមូលដ្ឋាន ដល់បុគ្គលិកថ្នាក់ក្រុង ស្រុកទាំងអស់។<br>- ផ្តល់ការបណ្តុះបណ្តាលដល់ប្រតិបត្តិករតេលេស៊ិនធ័រ ដើម្បីបង្កើនសមត្ថភាពប្រតិបត្តិការតេលេស៊ិនធ័ររបស់គេ | | |

| សង្ខេបពីគ្រោងការរបស់គម្រោង | សូចនាករ | មធ្យោបាយផ្ទៀងផ្ទាត់ | ការសន្មត់ / ហានិភ័យ |
|---|---|---|---|
| <u>សមាសភាគទី 3</u>- ការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធិភាព | | | |
| | - គាំទ្រដល់មុខនាទីមានប្រសិទ្ធភាពរបស់គណកម្មការតម្រង់ទិសគម្រោង។<br>- គាំទ្រក្រុមសម្របសម្រួលថ្នាក់ខេត្ត និងក្រុង ស្រុក និង មន្ទីរកសិកម្មខេត្ត ដើម្បីសម្របសម្រួល និងការពិនិត្យណែនាំសកម្មភាពគម្រោង<br>- បង្កើត និងគាំទ្រប្រព័ន្ធពិនិត្យតាមដានគុណផលអនុវត្តគម្រោង (PPMS)<br>- សេវាកម្មទីប្រឹក្សា ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងគ្រប់គ្រង | | |

## ឧបសម្ព័ន្ធ 2: ផែនការសកម្មភាពប្រចាំឆ្នាំ 2014 - លេខាធិការដ្ឋាន គ.ជ.អ.ប (NCDDS)

| បរិយាយពីសកម្មភាពសម្រាប់ឆ្នាំ 2014 | ពេលវេលា | ខេត្តគោលដៅ | | | | | | | ការទទួលខុសត្រូវ | |
|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ប.មានជ័យ | សៀមរាប | កំពង់ធំ | កំពង់ចាម | ថ្នាក់ជាតិ | សរុប | ដឹកនាំ | គាំទ្រ |
| សមាសភាគទី1 ៖ការអភិវឌ្ឍឃុំ សង្កាត់ តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ | | | | | | | | | | |
| លទ្ធផល 1.1 ៖កែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដែលគាំទ្រដល់ផលិតភាពកសិកម្ម | | | | | | | | | | |
| សកម្មភាព 1.1.1 ៖កំណត់គម្រោងហេដ្ឋារចនាសម្ព័ន្ធជាអាទិភាពដែលមាននៅក្នុង CDP/CIP | | | | | | | | | | |
| ដឹកនាំកិច្ចប្រជុំក្នុងឃុំ សង្កាត់គោលដៅដើម្បីបញ្ជាក់ពីគម្រោងហេដ្ឋារចនាសម្ព័ន្ធជាអាទិភាពដែលបានជ្រើសរើស។ | ត្រីមាសទី 1 | ឃុំ សង្កាត់ | 32 | 58 | 45 | 61 | 0 | 196 | ក្រុមប្រឹក្សាឃុំ សង្កាត់ | PFT/DFT |
| ការដាក់បញ្ជីគម្រោងជាអាទិភាពជូនក្រុមគាំទ្រគម្រោងថ្នាក់ខេត្ត | ត្រីមាសទី 1 | គម្រោង | 64 | 116 | 65 | 122 | 0 | 367 | មេឃុំ ចៅសង្កាត់ | DFT |
| សកម្មភាព 1.1.2 ៖រៀបចំសិក្សាគម្រោង | | | | | | | | | | |
| ជ្រើសរើសជំនួយការបច្ចេកទេសសម្រាប់សិក្សាលទ្ធភាព និងគ្រោងការគម្រោង | ត្រីមាសទី 1 | នាក់ | 5 | 9 | 6 | 8 | 0 | 28 | មេឃុំ ចៅសង្កាត់ | PFT/DFT |
| ចុះសិក្សាវាស់វែង និងប្រមូលទិន្នន័យ | ត្រីមាសទី 1 | គម្រោង | 64 | 116 | 65 | 122 | 0 | 367 | ជំនួយការបច្ចេកទេស | CC/DFT |
| សិក្សា និងរៀបចំរបាយការណ៍កិច្ចការពារសុវត្ថិភាព | ត្រីមាសទី 1 | គម្រោង | 64 | 116 | 65 | 122 | 0 | 367 | ក្រុមប្រឹក្សាឃុំ សង្កាត់ | DFT |
| រៀបចំគ្រោងការគម្រោង និងតម្លៃប៉ាន់ស្មាន | ត្រីមាសទី 1 | គម្រោង | 64 | 116 | 65 | 122 | 0 | 367 | ជំនួយការបច្ចេកទេស | ទីប្រឹក្សាវិស្វករ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| អនុម័តគ្រោងការគម្រោងដោយឃុំ សង្កាត់ និងដាក់ជូនក្រុមគាំទ្រថ្នាក់ខេត្តសម្រាប់ពិនិត្យបញ្ជាក់បច្ចេកទេស | ត្រីមាសទី 1 | គម្រោង | 64 | 116 | 65 | 122 | 0 | 367 | ក្រុមប្រឹក្សាឃុំ សង្កាត់ | DFT |
| **សកម្មភាព 1.1.3 ៖ពិនិត្យ និងរៀបចំឯកសារគ្រោងការបច្ចេកទេស ឯកសារដេញថ្លៃ និងកិច្ចសន្យា** | | | | | | | | | | |
| រៀបចំឯកសារដេញថ្លៃ និងសេចក្ដីជូនដំណឹងស្ដីពីការដេញថ្លៃ | ត្រីមាសទី 1 - 2 | គម្រោង | 64 | 116 | 65 | 122 | 0 | 367 | ក្រុមប្រឹក្សាឃុំ សង្កាត់ | PFT/DFT, CTA |
